ក

មាតិកា

I. ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

១៧-៨-២០០២	- ព្រះរាជក្រឹត្យ នស/រកត/០៨០២/២៤៦ ស្តីពី ការតែងតាំងឯកឧត្តម **សាំង សារ៉ែន** ជាទីប្រឹក្សាសម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ទទួលបន្ទុកការងារអភិវឌ្ឍន៍ជនបទ	២៣៥៩
១៧-៨-២០០២	- ព្រះរាជក្រឹត្យ នស/រកត/០៨០២/២៤៧ ស្តីពី ការតែងតាំងលោកជំទាវ **កែវ ម៉ាលី** ជាទីប្រឹក្សាសម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ទទួលបន្ទុកការងារពាណិជ្ជកម្ម	២៣៦០
១៧-៨-២០០២	- ព្រះរាជក្រឹត្យ នស/រកត/០៨០២/២៤៨ ស្តីពី ការដកហូតតួនាទី និងមុខតំណែង ឯកឧត្តម **ស ណូត** ពីទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា	២៣៦១
១៧-៨-២០០២	-ព្រះរាជក្រឹត្យ នស/រកត/០៨០២/២៤៩ ស្តីពី ការតែងតាំងឯកឧត្តម **កែវសុខសិទ្ធីនី** ជាទីប្រឹក្សាក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា	២៣៦២
២១-៨-២០០២	ព្រះរាជក្រឹត្យ នស/រកត/០៨០២/២៥០ ស្តីពី ការផ្តល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្ម ដល់លោក **វ៉ាង ចៅ** (WANG JOAO) សញ្ជាតិដើមចិន	២៣៦៣
២៦-៨-២០០២	- ព្រះរាជក្រឹត្យ នស/រកត/០៨០២/២៥៤ ស្តីពី ការផ្តល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្ម ដល់លោក **គួង ហាន់ឈាន** (KUNG HAN CHUAN) សញ្ជាតិដើមចិន	២៣៦៥

II. រាជរដ្ឋាភិបាល

១. អនុក្រឹត្យ

២៦-៨-២០០២	- អនុក្រឹត្យលេខ ៨៩ អនក្រ.បក ស្តីពី ការបង្កើតសភាពាណិជ្ជកម្មកម្ពុជា	២៣៦៦
២៦-៨-២០០២	- អនុក្រឹត្យលេខ ៩០ អនក្រ.បក ស្តីពី ការចេញផ្សាយ ក្រដាសប្រាក់ប្រភេទ ៥០ រៀល	២៣៦៧
២៦-៨-២០០២	- អនុក្រឹត្យលេខ ៩១ អនក្រ.បក ស្តីពី ការទទួលស្គាល់វិទ្យាស្ថានឯកទេសកម្ពុជា	២៣៦៨
២៣-៨-២០០២	-អនុក្រឹត្យលេខ ៤១៩ អនក្រ.តត ស្តីពី ការមុខតំណែងមន្ត្រីនគរបាលជាតិជាន់ខ្ពស់	២៣៧១
២៣-៨-២០០២	-អនុក្រឹត្យលេខ ៤២០ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ	២៣៧៣
២៦-៨-២០០២	-អនុក្រឹត្យលេខ ៤២១ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ	២៣៧៤
២៦-៨-២០០២	-អនុក្រឹត្យលេខ ៤២២ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ	២៣៧៦
២៦-៨-២០០២	-អនុក្រឹត្យលេខ ៤២៣ អនក្រ.តត ស្តីពី ការទទួលស្គាល់សមាជិក ជ្រើសតាំង នៃសមាសភាពការិយាល័យប្រតិបត្តិសំរាប់សភាពាណិជ្ជកម្មរាជធានីភ្នំពេញ អាណត្តិទី ២	២៣៧៨
២៦-៨-២០០២	-អនុក្រឹត្យលេខ ៤២៤ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ	២៣៨២
២៧-៨-២០០២	-អនុក្រឹត្យលេខ ៤២៥ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ	២៣៨៣

២៧-៨-២០០២ - អនុក្រឹត្យលេខ ៤២៦ អនក្រ តត ស្ដីពីការផ្ទេរភារកិច្ច និងតែងតាំង មុខតំណែងនាយនគរបាលជាតិ ២៣៨៤

២៧-៨-២០០២ - អនុក្រឹត្យលេខ ៤២៧ អនក្រ.តត ស្ដីពីការជូនមេដាយការងារ ២៣៨៦

២៧-៨-២០០២ - អនុក្រឹត្យលេខ ៤២៨ អនក្រ.តត ស្ដីពីការជូនមេដាយសហមេត្រី ២៣៨៨

២៩-៨-២០០២ - អនុក្រឹត្យលេខ ៤២៩ អនក្រ.តត ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ ២៣៩០

២៩-៨-២០០២ - អនុក្រឹត្យលេខ ៤៣០ អនក្រ.តត ស្ដីពីការជូនមេដាយសហមេត្រី ២៣៩២

២៩-៨-២០០២ - អនុក្រឹត្យលេខ ៤៣១ អនក្រ.តត ស្ដីពីការជូនមេដាយសហមេត្រី ២៣៩៣

២. សេចក្ដីសំរេច

១៦-៨-២០០២ - សេចក្ដីសំរេចលេខ ៤២ សសរ ស្ដីពីការបង្កើតគណៈកម្មការបច្ចេកទេសផ្ដល់យោបល់លើគំរោងស្ដីពីការពង្រឹងសមត្ថភាព ផ្នែកសេដ្ឋកិច្ច និងរដ្ឋបាលសាធារណៈ ២៣៩៤

២៨-៨-២០០២ - សេចក្ដីសំរេចលេខ ៤៣ សសរ ស្ដីពីការបង្កើតគណៈកម្មាធិការការពារតំបន់ទំនប់ទឹកប្រៃព្រៃនប់ ខ័ណ្ឌព្រៃនប់ ក្រុងព្រះសីហនុ ២៣៩៧

III- ការងារបណ្ដាក្រសួង

១. ទីស្ដីការរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

២១-៨-២០០២ -ប្រកាសលេខ ១១២ ដនស.ប្រក ស្ដីពីគោលការណ៍ណែនាំ និងនីតិវិធីរបស់ គណៈកម្មការសុរិយោដី ២៤០០

២. ទីស្ដីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

១២-៨-២០០២ - សេចក្ដីប្រកាសលេខ ២៦០ សប្រក.កសក ស្ដីពីតំបន់អភិរក្សចំរុះ " **សីមា** " ក្នុងព្រៃសម្បទាន ក្រុមហ៊ុនសាមលិញអន្តរជាតិ នៅខេត្តមណ្ឌលគីរី - ក្រចេះ ២៤៥០

៣.ទីស្ដីការរដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

២៨-៨-២០០២ - សេចក្ដីណែនាំលេខ ០៣ កធស.សណន ស្ដីពីការរៀបចំពិធីបុណ្យកាន់បិណ្ឌ ភ្ជុំបិណ្ឌ និងកឋិនទាន ២៤៥៣

២៩-៨-២០០២ -សេចក្ដីសំរេចលេខ ២៣៦ កធស.សរ ស្ដីពីការអនុញ្ញាតឱ្យកសាងវត្តថ្មី ឈ្មោះថា " **មង្គលសុវណ្ណគីរី** " នៃគណៈមហានិកាយ ភូមិតាមៅ ឃុំស្រេក ស្រុកកំពង់សៀម ខេត្តកំពង់ចាម ២៤៥៥

៤.ទីស្ដីការរដ្ឋមន្ត្រីក្រសួងកិច្ចការនារី និង អតីតយុទ្ធជន

២០-៨-២០០២ - ប្រកាសលេខ ២៨១ កកនអ /ប្រក ស្ដីពីការទទួលយកទីតាំងមជ្ឈមណ្ឌលស្ដារលទ្ធភាពពលកម្ម ព្យាបាលដោយចលនា ភ្នំពេញ មណ្ឌលម៉ាស្សាដៃទេព និងក្របខ័ណ្ឌមន្ត្រីរាជការ ២៤៥៦

ព្រះរាជក្រឹត្យ

នស / រកត / ០៨០២/២៤៦

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែមីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- យោងតាមសំណូមពរចាំបាច់នៃការងារ

ត្រាស់បង្គាប់

មាត្រា១: តែងតាំងឯកឧត្តម សាំង សារ៉ាវះ ជាទីប្រឹក្សាសម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា ទទួលបន្ទុកការងារអភិវឌ្ឍន៍ជនបទ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ដោយពុំទទួលប្រាក់បៀវត្ស ។

មាត្រា២: ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ ។

មាត្រា៣: ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០២
ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

លេខៈ ១៧៥ ច.ល

ហត្ថលេខា

៣.ល-០៧.០៩.០០៧៦០ ដើម្បីចម្លងចែក

ជា ស៊ីម

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ីវ តាន់

ព្រះរាជក្រឹត្យ

យើង

នស / រកត / ០៨០២/ ២៤៧

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែមីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- យោងតាមតម្រូវការចាំបាច់នៃការងារ

ត្រាស់បង្គាប់

មាត្រា១: តែងតាំងលោកជំទាវ ង៉ែត ឆារី ជាទីប្រឹក្សាសម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា ទទួលបន្ទុកការងារពាណិជ្ជកម្ម មានឋានៈស្មើ អនុរដ្ឋលេខាធិការ ដោយពុំទទួលប្រាក់បៀវត្ស ។

មាត្រា២: ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ ។

មាត្រា៣: ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០២
ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

លេខ:១៧៧ ច.ល

ហត្ថលេខា

ចរល.០២.០៨.០០២៦១ ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ២០០២ **ជា ស៊ីម**

អគ្គលេខាធិការរាជរដ្ឋាភិបាល

ណាំ តាន់

ព្រះរាជក្រឹត្យ

យើង

នស/រកត/០៨០២/២៤៨

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ទ្រង់ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានដកហូតតួនាទី និង មុខតំណែង ឯកឧត្តម ស ឈុត ពីទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែសីហា ឆ្នាំ ២០០២

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

ព្រ.ស.១២.០៨.០០២៦២ លេខ:១៧៨ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាវ តាន់

ព្រះរាជក្រឹត្យ

នស / រកត / ០៨០២/២៤៩

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាល វិជ្ជាជីវៈ និង យុវនីតិសម្បទា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងឯកឧត្តម កែវ សុខសិទ្ធិនី ជាទីប្រឹក្សាក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាល វិជ្ជាជីវៈ និង យុវនីតិសម្បទា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ៕

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០២

ក្នុងព្រះបរមនាម និង តាមព្រះរាជបង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

លេខ:១៧៦ ច.ល

៣៤.៥២.០៤.០០២៦៣ ដើម្បីចម្លងចែក

រាជធានីភ្នំពេញ,ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

សាន់ ... (ហត្ថលេខា)

ព្រះរាជក្រឹត្យ

នស/រកត/០៨០២/២៥០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **វ៉ាង ចៅ** (WANG JOAO) សញ្ជាតិដើមចិន កើតថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៣៧ នៅក្រុងម៉ាកាវ ប្រទេសចិន ។

មាត្រា ២ : នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០២

ក្នុងព្រះបរមនាមនិងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

លេខ:១៧៤ ច.ល

ដើម្បីចម្លងចែក

៣៧ល.០២.០៩.០០២៦៤

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

សារី តាន់

ព្រះរាជក្រឹត្យ

នស / រកត / ០៨០២ / ២៥៤

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១៖ ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **គុង ហាន់ឈាន** (KUNG HAN CHUAN) (នៅលីវ) សញ្ជាតិដើមចិន កើតថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ១៩៨៤ នៅកោះតៃវ៉ាន់ ប្រទេសចិន ។

មាត្រា ២៖ នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣៖ ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០២

ក្នុងព្រះបរមនាមនិងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

៣/ស.៩២.០៤.០០២៦៨

លេខៈ ៦៧៩ចិ.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ.ថ្ងៃទី២៩ ខែ សីហា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

ណារី តាន់

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៨៩ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការបង្កើតសភាពាណិជ្ជកម្មកម្ពុជា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ /នស/រតក/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ /០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ /នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៣ ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីសភាពាណិជ្ជកម្ម
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងការចាំបាច់នៃសភាពការណ៍

សំរេច

មាត្រា១ .-

បង្កើតសភាពាណិជ្ជកម្មកម្ពុជា ដែលព្រំដែនមណ្ឌលសភាពាណិជ្ជកម្មកម្ពុជានេះ គឺ លាតសន្ធឹងទៅគ្រប់ខេត្ត -ក្រុង ទូទាំងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា២ .-

ត្រូវបានប្រគល់ភារកិច្ចជូនសភាពាណិជ្ជកម្មរាជធានីភ្នំពេញ ឱ្យទទួលបន្ទុកដឹកនាំ និងគ្រប់គ្រងសភាពាណិជ្ជកម្មកម្ពុជា បន្ថែមលើភារកិច្ចរបស់ខ្លួន ក្នុងរយៈពេលពុំទាន់មានយន្តការសំរាប់ដឹកនាំ និងគ្រប់គ្រងសភាពាណិជ្ជកម្មកម្ពុជានេះ ។

មាត្រា៣ .-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៤ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលខេត្ត-ក្រុង និងប្រធានសភាពាណិជ្ជកម្មរាជធានីភ្នំពេញ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី២៦ ខែ សីហា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៩០ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការចេញផ្សាយក្រដាសប្រាក់

ប្រភេទ ៥០ រៀល

✧✧✧✧✧

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- តាមសំណើរបស់អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

សំរេច

មាត្រា ១ : អនុញ្ញាតឲ្យចេញផ្សាយ ធ្វើចរាចរនិងប្រើប្រាស់ក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា នូវក្រដាសប្រាក់ប្រភេទ ៥០រៀល ទន្ទឹមនឹងបណ្តាប្រភេទប្រាក់ដែលមានចេញផ្សាយរួចមកហើយ ។

មាត្រា ២ : ធនាគារជាតិនៃកម្ពុជា មានភារកិច្ចចេញសេចក្តីប្រកាសមួយ ដើម្បីផ្សព្វផ្សាយពីលក្ខណៈសំគាល់នៃក្រដាសប្រាក់ប្រភេទ ៥០រៀលនេះ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន និងអភិបាលខេត្ត-ក្រុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ដែលចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែ សីហា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចក្នុងមាត្រា ៣*
- *រាជកិច្ច*
- *កាលប្បវត្តិ-ឯកសារ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧១ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការទទួលស្គាល់ វិទ្យាស្ថានឯកទេសនៃកម្ពុជា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨.៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០២៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពី ការបង្កើត ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អន.ក្រ ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពី ការបង្កើត និង ការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញលិខិតស្នើសុំរបស់ លោក ស្តើង សុខុម ចុះថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០០១
- បានឃើញយោបល់របស់ក្រសួងអប់រំ យុវជន និង កីឡា

សំ រេ ច

មាត្រា ១ : ទទួលស្គាល់គ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា "**វិទ្យាស្ថានឯកទេសនៃកម្ពុជា**"

(Cambodian Institute for Specialties) ហៅកាត់ជាភាសាខ្មែរ "វ.ឯ.ក" និង ហៅកាត់ជាភាសាអង់គ្លេស "**CIS**" ។ វិទ្យាស្ថាននេះ ស្ថិតនៅក្រោមឱវាទ របស់ក្រសួងអប់រំ យុវជន និង កីឡា និងមានទីតាំង ស្ថិតនៅអាគារលេខ ៥៨ ផ្លូវលេខ ២៣០ សង្កាត់ ផ្សារដើមគរ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ។

មាត្រា ២ : វិទ្យាស្ថានឯកទេសនៃកម្ពុជា ធ្វើការបណ្តុះបណ្តាល ថ្នាក់បរិញ្ញាប័ត្រ ដែលមានរយៈពេលសិក្សាយ៉ាងតិច ៤ ឆ្នាំ ត្រូវនឹង ១៦៨ ក្រេឌីត ជាមធ្យម ។

មាត្រា ៣ : វិទ្យាស្ថានឯកទេសនៃកម្ពុជា មានមហាវិទ្យាល័យ :

- មហាវិទ្យាល័យគ្រប់គ្រង និង ទេសចរណ៍
- មហាវិទ្យាល័យ នីតិសាស្ត្រ និង សេដ្ឋកិច្ច
- មហាវិទ្យាល័យពត៌មានវិទ្យា
- មហាវិទ្យាល័យអប់រំភាសាអង់គ្លេស

ទៅអនាគត វិទ្យាស្ថាននេះ អាចបើកមហាវិទ្យាល័យ ឬ សាខា ឬ ឯកទេស ដទៃទៀត ដោយរៀបចំសំណុំបែបបទ សុំការអនុញ្ញាត ពីក្រសួងអប់រំ យុវជន និង កីឡា ។

មាត្រា ៤ : វិទ្យាស្ថានឯកទេសនៃកម្ពុជា មានក្រុមប្រឹក្សាភិបាលមួយ ទទួលបន្ទុកការងារ ពិនិត្យ និង សំរេច លើគោលនយោបាយ និង ផែនការអភិវឌ្ឍរបស់វិទ្យាស្ថាន និងមានក្រុមប្រឹក្សាសិក្សាមួយសំរាប់ពិនិត្យលើការអភិវឌ្ឍកម្មវិធីសិក្សា និង ការងារបច្ចេកទេសពាក់ព័ន្ធ ។

មាត្រា ៥ : នាយកវិទ្យាស្ថានឯកទេសនៃកម្ពុជា មានភារកិច្ច :

- ទទួលខុសត្រូវចំពោះមុខច្បាប់ក្នុងការគ្រប់គ្រងវិទ្យាស្ថាន ។
- ជ្រើសរើសនិស្សិតអោយចូលរៀន ជ្រើសរើសសាស្ត្រាចារ្យមកបង្រៀន និង បុគ្គលិកបំរើការងារ ។
- គ្រប់គ្រងអោយបានល្អនូវ ការងារនិស្សិត ការងារសិក្សា ការងារបង្រៀន ការងារស្រាវជ្រាវ និង ការប្រគល់សញ្ញាប័ត្រ ។
- គោរព និង អនុវត្ត តាមសារាចរ និង សេចក្តីណែនាំ របស់រាជរដ្ឋាភិបាល ។
- ធានាអោយបាន នូវសុវត្ថិភាព និង សណ្តាប់ធ្នាប់សង្គម ។
- ធ្វើរបាយការណ៍ រាល់សកម្មភាពសិក្សា ជូនក្រសួងអប់រំ យុវជន និង កីឡា អោយបានទៀងទាត់ តាមការកំណត់ ។

មាត្រា ៦ : និស្សិត ដែលរៀនចប់កម្មវិធីសិក្សារបស់វិទ្យាស្ថានឯកទេសនៃកម្ពុជា និងទទួលបានជោគជ័យក្នុងការប្រលងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាប័ត្រថ្នាក់បរិញ្ញា ដែលផ្តល់អោយដោយវិទ្យាស្ថានឯកទេសនៃកម្ពុជា ហើយត្រូវបានទទួលស្គាល់ពី ក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណីវិទ្យាស្ថាននេះបំពេញ និងអនុវត្តបានតាមគោលការណ៍កំណត់របស់ ក្រសួងអប់រំ យុវជន និង កីឡា ។

មាត្រា ៧ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា អគ្គនាយកដ្ឋាន

អង្គភាពពាក់ព័ន្ធ និង វិទ្យាស្ថានឯកទេសនៃកម្ពុជា មានភារកិច្ចរៀងៗ ខ្លួន ដើម្បីអនុវត្ត និង ប្រតិបត្តិតាមអនុក្រឹត្យនេះ ។

មាត្រា ៨ : អនុក្រឹត្យនេះ មានប្រសិទ្ធិភាព និង គតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

ភ្នំពេញ ថ្ងៃទី២៦ ខែ សីហា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលាក្រុងភ្នំពេញ

  " ដើម្បីមុខការ "
- ដូចមាត្រា ៧ "ដើម្បីអនុវត្ត"
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...៤១៩...អនក្រ..តត

អនុក្រឹត្យ

ស្តីពី

ការតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិជាន់ខ្ពស់

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ០៨ អនក្រ.បក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមអ្នកច្បាប់ និងនាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងអាស៊ាន
- បានឃើញអនុក្រឹត្យលេខ ៥០ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០២ ស្តីពីការកែសំរួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យក្រសួងមហាផ្ទៃ មកជាអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានតែងតាំងជា ប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងអាស៊ាន ចំណុះអគ្គលេខាធិការដ្ឋាន លោកវរៈសេនីយ៍ឯក **លីវ ម៉ូវ** អត្តលេខ ០៤០១ បច្ចុប្បន្នជា អនុប្រធាននាយកដ្ឋាននគរបាលស្ថិតិ និងលិខិតឆ្លងដែន ចំណុះអគ្គស្នងការដ្ឋាននគរបាលជាតិ ។

មាត្រា ២ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចម្លងជូន :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *សាមីខ្លួន*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤២០ អនក្រ.តត

អនុក្រឹត្យ

ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ

&&&&&

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់គណៈកម្មាធិការនាយកនៃសមាគមបុគ្គលិកសិក្សាខ្មែរ

សំរេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា** ជាកិច្ចបច្ឆាមរណៈជូនសពលោក **យ៉ង់ ធី** ប្រធានសមាគមបុគ្គលិកសិក្សាខ្មែរ ដែលបានបូជាអាយុជីវិត ចំណេះវិជ្ជា និង ប្រាជ្ញា ស្មារតី របស់លោកទាំងស្រុង បំរើដល់បុព្វហេតុការងារអប់រំ និង សិក្សាធិការជាតិ ។

មាត្រា ២ : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា និង គណៈកម្មាធិការនាយកនៃសមាគមបុគ្គលិកសិក្សាខ្មែរ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

P3

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៤១ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការតែងតាំងមន្ត្រីរាជការ

* * * * * * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ.បក ចុះថ្ងៃទី ០៤ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

សំរេច

មាត្រា ១ : ត្រូវបានតែងតាំងមន្ត្រីរាជការនៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដូចមានរាយនាមខាងក្រោម ÷

១-លោក **ស៊ឹង ម៉ុន** ជាអគ្គាធិការរង នៃអគ្គាធិការដ្ឋាន ។

២-លោក **ឃួត ចាន់ធី** ជាប្រធាននាយកដ្ឋានអធិការកិច្ចការងារ នៃអគ្គនាយកដ្ឋានការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

P3

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី២៦ ខែសីហា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ - កាលប្បវត្តិ

4

p.doc

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៧៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការតែងតាំងមន្ត្រីរាជការ

* * * * * * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

សំ រេ ច

មាត្រា ១ : ត្រូវបានតែងតាំងមន្ត្រីរាជការនៃក្រសួងសុខាភិបាល ដូចមានរាយនាមខាងក្រោម ÷

១-លោកវេជ្ជ. អ៊ឹុំ សុផល ជាអគ្គនាយករង បច្ចេកទេសសុខាភិបាល ។

២-លោកវេជ្ជ. អ៊ុច សំអាន ជាប្រធានវិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសាធារណៈ ជំនួសលោកវេជ្ជ.អ៊ឹុំ សុផល ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋលេខាធិការនៃ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី

p.doc

រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែសីហា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៤២៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការទទួលស្គាល់សមាជិកជ្រើសតាំង និង សមាសភាពការិយាល័យប្រតិបត្តិ សំរាប់សភាពាណិជ្ជកម្មរាជធានីភ្នំពេញ អាណត្តិទី ២

****

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស រកម / ០១៩៦ / ១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស រកម / ០៦៩៥ / ០៣ ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីសភាពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៦១ អនក្រ. បក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតសភាពាណិជ្ជកម្មរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ. បក ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ១៩៩៨ ស្តីពីការកែប្រែមាត្រា២ នៃអនុក្រឹត្យស្តីពីការបង្កើតសភាពាណិជ្ជកម្មរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ៤២អនក្រ.បក ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីរបៀបរបប និងការរៀបចំការបោះឆ្នោតសភាពាណិជ្ជកម្ម
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សំរេច

មាត្រា១ .-

ទទួលស្គាល់សមាជិកជ្រើសតាំងនៃសភាពាណិជ្ជកម្មរាជធានីភ្នំពេញ ចំនួន ៣៦រូប ដែលបែងចែកប្រភេទ អាជីវកម្មមានដូចខាងក្រោម :

ប្រភេទពាណិជ្ជកម្ម

១- អ្នកឧកញ៉ា	ស៊ុខ គង់	៧- លោក	ជា ខួន
២- លោកឧកញ៉ា	អ៊ឹង ប៊ុនហ៊ាវ	៨- លោក	ហោ ម៉េន
៣- លោកជំទាវ	កែវ ម៉ាលី	៩- លោក	ទី ហួរ
៤- លោកឧកញ៉ា	តែ តាំងប៉រ	១០-លោកឧកញ៉ា	លី យ៉ុងផាត់
៥- លោកឧកញ៉ា	ម៉ែន សារុន	១១-លោកឧកញ៉ា	គង់ ទ្រីវ
៦- លោកឧកញ៉ា	ភុក អាន	១២- លោក	ហ៊ី ហេង

ប្រភេទឧស្សាហកម្ម-សិប្បកម្ម

១- លោកឧកញ៉ា	ស៊ីន សុខណា	៧- លោកស្រីឧកញ៉ា	ចាន់ សុផ្លា
២- លោកឧកញ៉ា	ឡូច សារ៉េត	៨- លោក	គង់ សាង
៣- លោកឧកញ៉ា	ហាន់ ឃៀង	៩- លោក	ចាន់ ភាយ
៤- លោកឧកញ៉ា	ឡាវ ម៉េងឃីន	១០- លោក	ចេន ជីវាង
៥- លោកឧកញ៉ា	ស៊ូ សុវណ្ណ	១១-លោក	តាំង ម៉េងហ៊ុយ
៦- លោកឧកញ៉ា	សេង ឆាយអ៊ឹះ	១២- លោក	ឡាយ ម៉េងស៊ុន

ប្រភេទសេវាកម្ម និង វិជ្ជាជីវៈសេរី

១- លោកឧកញ៉ា	គិត ម៉េង	៤- លោកឧកញ៉ា	ខេន សុភា
២- លោក	ស្វាយ ទុឡ្លី	៥- លោក	ទីវ ម៉េងហ៊ុយ
៣- លោកឧកញ៉ា	ទី ពិសិដ្ឋ	៦- លោក	ថៃ អ៊ុយ

ប្រភេទកសិកម្ម

១-	លោកឧកញ៉ា	**ម៉ុង ឫទ្ធី**	៤-	លោក	**ឈាង សុធី**
២-	លោក	**លី គួយ**	៥-	លោក	**យៀប សេងហួរ**
៣-	លោក	**ហាន ឧុទ្ធី**	៦-	លោកស្រី	**ជុង ចាន់សោភា**

មាត្រា២ ._

ទទួលស្គាល់ការបង្កើតការិយាល័យប្រតិបត្តិមួយ របស់សភាពាណិជ្ជកម្មរាជធានីភ្នំពេញ ដែលមានសមាស ភាពសំរាប់ដឹកនាំ និង គ្រប់គ្រងដូចខាងក្រោម :

១-	អ្នកឧកញ៉ា	**សុខ គង់**	ប្រធាន
២-	លោកឧកញ៉ា	**គង់ ទ្រីវ**	អនុប្រធាន
៣-	លោកឧកញ៉ា	**ម៉ែន សារុន**	អនុប្រធាន
៤-	លោកឧកញ៉ា	**ស៊ិន សុខណា**	អនុប្រធាន
៥-	លោកឧកញ៉ា	**លី យ៉ុងផាត់**	អនុប្រធាន
៦-	លោកឧកញ៉ា	**ហាន់ ឃៀង**	ហិរញ្ញិក
៧	លោក	**ថៃ អ៊ុយ**	ហិរញ្ញិករង
៨-	លោកស្រីឧកញ៉ា	**ចាន់ សុខ្ខា**	ហិរញ្ញិករង
៩-	លោកឧកញ៉ា	**តែ តាំងប៉ះ**	លេខាធិការ
១០-	លោក	**ឈាង សុធី**	លេខាធិការរង

មាត្រា៣ ._

ទទួលស្គាល់ លោកឧកញ៉ា **សូ សុវណ្ណ** និងលោកឧកញ៉ា **ឡាវ ម៉េងឃីន** ជាទីប្រឹក្សារបស់ប្រធានសភាពាណិជ្ជកម្មរាជធានីភ្នំពេញ ។

មាត្រា៤ ._

អនុក្រឹត្យលេខ ៩២អនក្រ.តត ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការទទួលស្គាល់ សមាជិកជ្រើសតាំង នៃសភាពាណិជ្ជកម្មរាជធានីភ្នំពេញ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៥ ._

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ អភិបាលខេត្ត-ក្រុង ប្រធានសភាពាណិជ្ជកម្មរាជធានីភ្នំពេញ និងសាមីខ្លួន ដែលមានចែងក្នុងមាត្រា ១ មាត្រា ២ និង មាត្រា ៣ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី២៦ ខែ សីហា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>**កន្លែងទទួល**</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៤៧៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

&&&&&

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូន **ក្រុមហ៊ុនភាហ្វេជូធំរ** នៅប្រទេសជប៉ុន ដែលបានផ្តល់ថវិកាចំនួន ២៨.000 USD សំរាប់កសាងអាគារសិក្សា ០១ ខ្នង រួមទាំងសង្ហារឹមសិក្សាគ្រប់គ្រាន់ ជូនសាលាបឋមសិក្សាព្រៃបែន ក្នុងឃុំសត្វពង ស្រុកឈូក ខេត្តកំពត ។

មាត្រា ២ : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៤៧៥ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/ ១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្រុមមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ម្រេ ច

មាត្រា១ : ត្រូវបានតម្លើងឋានន្តរសក្តិថ្នាក់ **វរៈសេនីយ៍ឯក** ជូននាយនគរបាលជាតិ នៃសាលាភូមិន្ទនគរបាល ក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម ៖

១- លោកវរៈសេនីយ៍ទោ **ឯក ឆោម** អត្តលេខ ០៦៨១ អនុប្រធានមន្ទីរចាត់ការ ។
២- លោកវរៈសេនីយ៍ទោ **ណុប ហេង** អត្តលេខ ០៦៩៧ អនុប្រធានមន្ទីរចាត់ការ ។
៣- លោកវរៈសេនីយ៍ទោ **ម៉ែន ចាន់ថុល** អត្តលេខ ០៨១៨ អនុប្រធានមជ្ឈមណ្ឌល - បណ្តុះបណ្តាលដំបូង ។

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ សីហា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៤៧៦ អនក្រ.តត

អនុក្រឹត្យ

ស្តីពី

ការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងនាយនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស/៩៤ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/ ១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានផ្ទេរភារកិច្ច និង តែងតាំងមុខតំណែងនាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម :

១-លោកឧត្តមសេនីយ៍ត្រី **ហ៊ុល សគ្គា** អត្តលេខ ០០២៥ បច្ចុប្បន្នអនុប្រធានទី ១ នាយកដ្ឋានកណ្តាលមធ្យោបាយ ទៅជាទីប្រឹក្សារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

២-លោកឧត្តមសេនីយ៍ត្រី **គឹម សំណាង** អត្តលេខ ០០៦១ បច្ចុប្បន្នអនុប្រធាននាយកដ្ឋានកណ្តាលមធ្យោបាយ ទៅជាអនុប្រធានទី ១ នាយកដ្ឋានកណ្តាលមធ្យោបាយ ។

៣-លោកឧត្តមសេនីយ៍ត្រី **ហ៊ុយ ហឿន** អត្តលេខ ០០៤៦ ជាអនុប្រធាននាយកដ្ឋានកណ្តាលមធ្យោបាយ ។

មាត្រា ២ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយ នឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

uc

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និង សាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ. ថ្ងៃទី២៧ ខែសីហា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u>
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ៤៤៧ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

&&&&&

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើររបស់ប្រធានគណៈកម្មាធិការនាយកប្រតិបត្តិ នៃ សមាគម " ស្ថាប័នវិស្វកម្មកម្ពុជា "

សំរេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រី ១០ រូប នៃសមាគម " ស្ថាប័នវិស្វកម្មកម្ពុជា " (EIC) ដែលមានស្នាដៃល្អ ក្នុងការបំពេញការងារបំរើជាតិមាតុភូមិ ដូចមាននាមខាងក្រោម ÷

ក_មេដាយមាសការងារ

១-លោកសាស្ត្រាចារ្យ **មាស សុខុម** ប្រធានអង្គការសហព័ន្ធវិស្វកម្មអាស៊ាន និងជាប្រធាននៃ EIC
២-លោក **ថ្នាក់ មឹន** អនុប្រធាននៃEIC និងជាប្រធានគណៈកម្មាធិការវិស្វករអាជីព
៣-លោក **ម៉ែន ដែន** អនុប្រធាន នៃ EIC
៤-លោក **ច័ន្ទ តារារិទ្ធ** អនុប្រធាន នៃ EIC
៥-លោក **ឌី ជាប៉ុក** អគ្គលេខាធិការ នៃ EIC
៦-លោក **កោ ជុន** អគ្គហិរញ្ញិក នៃ EIC
៧-លោក **សុទ្ធ សុបញ្ញា** អគ្គលេខាធិការរង នៃ EIC

ខ_មេធាវីប្រចាំការងារ

១-លោក	**លឹម**	**សុខាវ**	អគ្គហិរញ្ញិករង នៃ EIC
២-លោក	**ម៉ែន**	**ពណ្ណរាយ**	អគ្គលេខាធិការរង នៃ EIC
៣-លោក	**លាង**	**ឆាលី**	អគ្គលេខាធិការរង នៃ EIC

មាត្រា ២ : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មាធិការនាយកប្រតិបត្តិ នៃ សមាគម " ស្ថាប័នវិស្វកម្មកម្ពុជា " ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

រាជធានីភ្នំពេញ.ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៤២៨...អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយសហមេត្រី

៚៚៚៚៚

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ប្រធានគណៈកម្មាធិការនាយកប្រតិបត្តិ នៃសមាគម " ស្ថាប័នវិស្វកម្មកម្ពុជា " (EIC)

សំរេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយសហមេត្រី** តាមលំដាប់ថ្នាក់ ជូនឥស្សរជន ១១ រូប ជាសមាជិកអង្គការ សហព័ន្ធវិស្វកម្មអាស៊ាន (AFEO) ដែលមានស្នាដៃល្អក្នុងការធ្វើសហប្រតិបត្តិការ ជួយដល់ស្ថាប័នវិស្វកម្មកម្ពុជា ដូចមាននាមខាងក្រោម ÷

ក - **មេដាយសហមេត្រី** ថ្នាក់ **សេនា** :

១- លោក **Choo Kok Beng** ប្រធាន **AER** នៃ **AFEO**
២- លោក **Chitr Lilavivat** សមាជិកគណៈកម្មការ **AER** នៃ **AFEO**
៣- លោកបណ្ឌិត **Gue See Sew** ប្រធាន **IEM** នៃវិស្វកម្មម៉ាឡេស៊ី

ខ - **មេដាយសហមេត្រី** ថ្នាក់ **អស្សឫទ្ធិ** :

១- លោក **Dato Zakaria Noordin** ប្រធាន **PUJA** នៃវិស្វកម្មប្រ៊ុយណេ
២- លោក **Ir. A Qoyum Tjandranegara** ប្រធាន **PII** នៃវិស្វកម្មឥណ្ឌូណេស៊ី
៣- លោក **U Than Myint** ប្រធាន **MES** នៃវិស្វកម្មភូមា
៤- លោក **Engr. Augusto C Soliman** ប្រធាន **PTC** នៃវិស្វកម្មភីលីពីន
៥- លោក **Er. Dr. Lock Kai Sang** ប្រធាន **IES** នៃវិស្វកម្មសឹង្ហបូរី
៦- លោក **Dr. Karoon Chandrangsa** ប្រធាន **EIT** នៃវិស្វកម្មថៃ

៧- លោក **Prof. Acad. Vu Tuyen Hoang** ប្រធាន **VUSTA** នៃវិស្វកម្មវៀតណាម

៨- លោក **Khamphong PHANVONGSA** អនុប្រធាន **LUSEA** នៃវិស្វកម្មឡាវ

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មាធិការនាយកប្រតិបត្តិ នៃ សមាគម " ស្ថាប័នវិស្វកម្មកម្ពុជា " ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

រាជធានីភ្នំពេញ , ថ្ងៃទី២៧ ខែ សីហា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...៤៧៩ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភណ្ឌ

*****

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១ ៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើប្រាស់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/ ០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសឱ្យប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ .

សំរេច

<u>មាត្រា ១</u> : ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ**តាមលំដាប់ថ្នាក់ ជូនលោកស្រី អស់លោក ជាសប្បុរសជនស្ថាបនិកអង្គការស្ពាន កម្ពុជា-ហុល្លង់ ដែលបានរួមចំណែកយ៉ាងសកម្ម ក្នុងការស្តារឡើងវិញ លើវិស័យសិក្សាធិការ និង សង្គមកិច្ចនៅក្នុងប្រទេសកម្ពុជា ពីឆ្នាំ ១៩៩១ ដល់ឆ្នាំ ២០០២ សរុបទឹកប្រាក់ចំនួន ១.៣៧៩.៥៣៤ ដុល្លា អាមេរិកដូចមានរាយនាមខាងក្រោម :

ក.មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ធិបឌិន្ទ :

- លោកស្រីវេជ្ជបណ្ឌិត **ឌីនី វ៉ាន់ឬវ្គ៉ែន**

ខ.មេដាយមុនីសារាភ័ណ្ឌ ថ្នាក់សេនា :

- លោក សាស្ត្រាចារ្យ **ខួន ផាន**
- លោកគ្រូគង្វាល **ហ៊ាខ កុយ**

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ . ថ្ងៃទី [illegible] ខែ សីហា ឆ្នាំ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច ✓
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៤៣០ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយសហមេត្រី

&&&&&

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

សំរេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **អស្សឫទ្ធិ** ជូនលោកបណ្ឌិត **Fernand TEXIER** នាយកវិទ្យាស្ថានបច្ចេកទេសកម្ពុជា និងជាអ្នកទទួលបន្ទុកលើគំរោងកម្មវិធី Fond Solidarité Prioritaire ដែលបានចូលរួមចំណែកបណ្តុះបណ្តាលយុវិស្វករ និង អ្នកបច្ចេកទេសជាន់ខ្ពស់កម្ពុជា នៅវិទ្យាស្ថានបច្ចេកទេសកម្ពុជា និង ជួយដល់ការពង្រឹងចំណងសាមគ្គីភាពរវាងប្រទេសទាំងពីរកម្ពុជា-បារាំង ។

មាត្រា ២ : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួង អប់រំយុវជន និង កីឡា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៣១ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយសហមេត្រី

***

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អគ្គលេខាធិការនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

ស ម្រេ ច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **សេនា** ជូនលោក **RYOJI SUZUKI** ជំនាញការជប៉ុនប្រចាំអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលបានធ្វើសហប្រតិបត្តិការជួយផ្តល់បទពិសោធន៍និងចំណេះដឹង ព្រមទាំងស្វែងរកជំនួយបានចំនួន ៦៨.១៦៩ USD ជួយដល់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ,ថ្ងៃទី២៩ខែ សីហា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា ១ និងមាត្រា២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៧ សសរ

សេចក្តីសំរេច

ស្តីពី ការបង្កើតគណៈកម្មការបច្ចេកទេសផ្តល់យោបល់ លើគំរោងស្តីពីការពង្រឹងសមត្ថភាព ផ្នែកសេដ្ឋកិច្ច និងរដ្ឋបាលសាធារណៈ

រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពី ការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- បានឃើញ អនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
- បានឃើញ អនុក្រឹត្យលេខ ៨៣ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
- បានឃើញ កំណត់ហេតុនៃការចរចារលើគំរោងស្តីពី ការពង្រឹងសមត្ថភាព ផ្នែកសេដ្ឋកិច្ច និង រដ្ឋបាលសាធារណៈ ចុះថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០០២ រវាងព្រះរាជាណាចក្រកម្ពុជា និង សមាគមអភិវឌ្ឍន៍អន្តរជាតិ

សំរេច

ប្រការ ១.- ត្រូវបានបង្កើតគណៈកម្មការបច្ចេកទេសមួយ នៅអមអ្នកសំរបសំរួលគំរោង ដើម្បីផ្តល់យោបល់បច្ចេកទេស លើគំរោងស្តីពីការពង្រឹងសមត្ថភាព ផ្នែកសេដ្ឋកិច្ច និងរដ្ឋបាលសាធារណៈ របស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ។

ប្រការ ២.- សមាសភាពគណៈកម្មការបច្ចេកទេសនេះ មានដូចខាងក្រោម :

១- អគ្គលេខាធិការ ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល	ប្រធាន
២- តំណាង ទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
៣- តំណាង ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
៤- តំណាង ក្រសួង ផែនការ	សមាជិក
៥- តំណាង ក្រសួងអប់រំ យុវជន និង កីឡា	សមាជិក
៦- តំណាង ក្រសួង សង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងនីតិសម្បទា	សមាជិក
៧- តំណាង រដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ	សមាជិក
៨- តំណាង សាលាភូមិន្ទរដ្ឋបាល	សមាជិក
៩- តំណាង វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
១០- តំណាង រាជបណ្ឌិតសភាកម្ពុជា	សមាជិក

ប្រការ ៣.- គណៈកម្មការបច្ចេកទេស ដឹកនាំដោយប្រធានមួយរូប ។ គណៈកម្មការបច្ចេកទេសដំណើរការការងារ ក្រោមការដឹកនាំរបស់ប្រធាន និង ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ។ ប្រធានគណៈកម្មការបច្ចេកទេស កោះប្រជុំសមាជិកតាមតំរូវការចាំបាច់ ។

ប្រការ ៤.- គណៈកម្មការបច្ចេកទេសមានភារកិច្ចផ្តល់យោបល់ជូនអ្នកសំរបសំរួលគំរោង លើការអនុវត្តន៍គំរោងស្តីពីការពង្រឹងសមត្ថភាព ផ្នែកសេដ្ឋកិច្ច និង រដ្ឋបាលសាធារណៈ ជាពិសេស ការរៀបចំកម្មវិធី និងសកម្មភាពបណ្តុះបណ្តាលមន្ត្រីរាជការស៊ីវិល ការពង្រីកបន្ថែមចំនួនមន្ត្រីរាជការចូលរួមបណ្តុះបណ្តាល និង សកម្មភាពថ្មីៗផ្សេងទៀត ដូចជា ការរៀបចំសិក្ខាសាលាបន្ថែមទៀត ។

ប្រការ ៥.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រុមប្រឹក្សា អាជ្ញាធរជាតិ គ្រប់ក្រសួង-ស្ថាប័ន ត្រូវអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែ ៧ ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ប្រធានឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

ហ៊ុន សែន

បានយកសេចក្តីជំរាបជូន

សម្តេច នាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

និងជា ប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

សុខ អាន

កន្លែងទទួល :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៥*
- *កាលប្បវត្តិ-ឯកសារ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៤៣ អនក្រ

អនុក្រឹត្យ

ស្តីពី

ការបង្កើតគណៈកម្មាធិការការពារតំបន់ទំនប់ការពារ ទឹកប្រៃព្រែនប់ ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមតម្រូវការចាំបាច់

សំរេច

ប្រការ ១.-

ត្រូវបានបង្កើតគណៈកម្មាធិការការពារតំបន់ទំនប់ការពារទឹកប្រៃព្រែនប់ ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ ដែលមាន

សមាសភាពដូចតទៅ :

១. ឯកឧត្តម លឹម គានហោ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ប្រធាន

២. ឯកឧត្តម ឆាន់ សារ៉ាវ៉ាន់ រដ្ឋលេខាធិការក្រសួងបរិស្ថាន អនុប្រធាន

៣. ឯកឧត្តម ស៊ូ ស៊ូរ៉ាត់ អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុប្រធាន

៤. ឯកឧត្តម វ៉ន្ត សារិន អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ អនុប្រធាន

៥. ឯកឧត្តម ឈុន ស៊ីរុន អភិបាលរងទី ១ក្រុងព្រះសីហនុ អនុប្រធាន

៦. លោក ពេជ្រ គឹមសាន្ត ប្រធានមន្ទីរធនធានទឹក និងឧតុនិយមក្រុងព្រះសីហនុ សមាជិក

៧. លោក ហែម សារឿន ប្រធានមន្ទីរបរិស្ថានក្រុងព្រះសីហនុ សមាជិក

៨. លោក នៅ វេនា ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក្រុងព្រះសីហនុ សមាជិក

៩. លោក សូ សុខ ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់និងសុរិយោដីក្រុងព្រះសីហនុ សមាជិក

១០. លោក មាស វុឌ្ឍី អភិបាលខណ្ឌព្រៃនប់ សមាជិក

ប្រការ ២.–

គណៈកម្មាធិការនេះមានភារកិច្ចដូចតទៅ :

- ចុះស្រាវជ្រាវកំណត់តំបន់តាមបណ្ដោយទំនប់ការពារទឹកប្រៃព្រៃនប់ ដោយកំណត់ច្បាស់លាស់លើស្ថានភាពជាក់ស្តែង ដែលគណៈកម្មាធិការនេះមានភារកិច្ចត្រួតពិនិត្យ និងការពារ ដើម្បីស្នើទៅរាជរដ្ឋាភិបាលធ្វើការបង្កកដោយអនុក្រឹត្យ ។

- ចូលរួមសហការជាមួយអាជ្ញាធរដែនដី ទប់ស្កាត់ការកាប់បំផ្លាញព្រៃតាមបណ្ដោយតំបន់ទំនប់ ធានាបាននូវស្ថានភាពបរិស្ថាន ប្រកបដោយនិរន្តរភាព ដើម្បីអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ស្តីពីគោលនយោបាយដីធ្លីតំបន់ហាមឃាត់អោយបានល្អប្រសើរ ។

- ចលនាប្រជាពលរដ្ឋចូលរួមថែរក្សា ការពារព្រៃ និងដាំដើមឈើឡើងវិញក្នុងតំបន់នេះ ដោយគូសបញ្ជាក់អំពីសារៈសំខាន់របស់ព្រៃឈើ ដើម្បីការពារទំនប់ និងមច្ឆជាតិ ។

ប្រការ ៣.–

គណៈកម្មាធិការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន និងមានសិទ្ធិអញ្ជើញអ្នកបច្ចេកទេសចូលរួមតាមការចាំបាច់ ហើយត្រូវរាយការណ៍ពីលទ្ធផលការងាររបស់ខ្លួនជូនទៅរាជរដ្ឋាភិបាល ។ គណៈកម្មាធិការនេះ មានទីស្នាក់ការនៅក្រសួងធនធានទឹក និងឧតុនិយម និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងធនធានទឹក និងឧតុនិយម ។

ប្រការ ៤.–

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អភិបាលក្រុងព្រះសីហនុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័ន ពាក់ព័ន្ធ និងឯកឧត្តម អស់លោក ដូចមានចែងក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។ ៚

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ៧ ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័ននៃរាជរដ្ឋាភិបាល
- ដូចប្រការ ៤
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

លេខ : ១១២ ដនស/ប្រក

ប្រកាស

ស្តីពី

គោលការណ៍ណែនាំ និង នីតិវិធី

របស់គណៈកម្មការសុរិយោដី

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យ លេខ ៦២ អនក្រ/បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញអនុក្រឹត្យ លេខ ៤៦ អនក្រ/បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និង សៀវភៅគោលបញ្ជីដីធ្លី
- បានឃើញអនុក្រឹត្យ លេខ ៤៧ អនក្រ/បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី
- បានឃើញអនុក្រឹត្យ លេខ ៤៨ អនក្រ/បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ
- បានឃើញប្រកាស លេខ ៧៦ ប្រក/ដនស ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ១៩៩៩ ស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ...

របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង និង តួនាទីភារកិច្ចរបស់បណ្ណាការិយាល័យក្រោមឱវាទ

- តាមការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

សំ រេ ច

១. និយមន័យ

ប្រការ ១ :-

ប្រកាសនេះកំណត់នីតិវិធីនៃការដាក់ពាក្យប្តឹង ការសម្រុះសម្រួល និង ការសំរេចលើបញ្ហាវិវាទដីធ្លីដែលបានប្តឹងទៅគណៈកម្មការសុរិយោដីគ្រប់ថ្នាក់ ។

ប្រការ ២ :-

គណៈកម្មការសុរិយោដីថ្នាក់ស្រុកខណ្ឌ (គសសខ) គឺជាគណៈកម្មការដែលបានបង្កើតឡើងដោយអនុលោមតាមមាត្រា៤ និង មាត្រា ៥ នៃអនុក្រឹត្យ លេខ ៤៧ អនក្រ/បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី ។

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង (គសខក) គឺជាគណៈកម្មការដែលបានបង្កើតឡើងដោយអនុលោមតាមមាត្រា៣ និង មាត្រា ១២ នៃអនុក្រឹត្យលេខ ៤៧ អនក្រ/បក ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី។

គណៈកម្មការសុរិយោដីថ្នាក់ជាតិ (គសជ) គឺជាគណៈកម្មការដែលបានបង្កើតឡើងដោយអនុលោមតាមមាត្រា៣ និងមាត្រា១៧ នៃអនុក្រឹត្យលេខ ៤៧ អនក្រ/បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី។

" គណៈកម្មការរដ្ឋបាល " គឺជាគណៈកម្មការដែលបានបង្កើតឡើងដើម្បីដឹកនាំការចុះបញ្ជីដីធ្លីជាប្រព័ន្ធនៅក្នុងតំបន់វិនិច្ឆ័យ ។ ភារកិច្ចមួយនៃគណៈកម្មការនេះ គឺធ្វើការដោះស្រាយវិវាទដីធ្លីដែលកើតមាននៅក្នុងអំឡុងពេលនៃការចុះបញ្ជី

មានលក្ខណៈជាប្រព័ន្ធស្របតាមមាត្រា ៣ នៃអនុក្រឹត្យ លេខ ៤៦ អនក្រ/បក ស្តីពីនីតិវិធីនៃការកសាងបលង់សុរិយោដី និង សៀវភៅគោលបញ្ជីដីធ្លី ។

" ដីដែលមិនទាន់បានចុះបញ្ជីសុរិយោដី " គឺជាក្បាលដីទាំងឡាយដែលមិនទាន់បានចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធ ឬ មានលក្ខណៈដាច់ដោយដុំស្របតាមច្បាប់ភូមិបាលឆ្នាំ២០០១ ។

"បុគ្គល" រួមមាន រូបវន្តបុគ្គល ឬ នីតិបុគ្គល ។

" ដើមបណ្តឹង" គឺជាជនដែលធ្វើការប្តឹងទាមទារអោយមានការដោះស្រាយវិវាទដោយអនុលោមតាមប្រកាសនេះ ។

" ចុងបណ្តឹង" គឺបុគ្គលដែលជំទាស់ទៅនឹងដើមបណ្តឹង ។

២. ការចាប់ផ្តើមដំណើរការដោះស្រាយវិវាទ

ប្រការ ៣ :-

បុគ្គលទាំងឡាយដែលទាមទារកម្មសិទ្ធិ (ឬ សិទ្ធិកម្មសិទ្ធិ) ឬភោគៈ (ឬ សិទ្ធិភោគៈ) លើដីមិនទាន់បានចុះបញ្ជីសុរិយោដី ហើយដីនោះមានបុគ្គលម្នាក់ ឬច្រើននាក់ផ្សេងទៀតបានទាមទារមួយផ្នែកឬទាំងមូលដែរ អាចដាក់ពាក្យបណ្តឹងទៅគណៈកម្មការ សុរយោដីថ្នាក់ស្រុក ឬ ខណ្ឌ ដែលដីនោះស្ថិតនៅ ។

ប្រការ ៤ :-

បុគ្គលដែលប្តឹងទាមទារធ្វើជាកម្មសិទ្ធិករ ឬ ភោគីនៃដីត្រូវដាក់ពាក្យបណ្តឹង លើកលែងតែក្នុងករណីដែលជននោះជាអសមត្ថជន ។ ក្នុងករណីនេះ អ្នកតំណាងស្របច្បាប់របស់ជននោះ អាចដាក់ពាក្យបណ្តឹងក្នុងនាមជននោះបាន ។

ប្រការ ៥ :-

បណ្តឹងទាមទារ ត្រូវធ្វើតាមទម្រង់បែបបទនៃពាក្យបណ្តឹង ដូចមាននៅក្នុងឧបសម្ព័ន្ធទី ១នៃប្រកាសនេះ ។ ដើមបណ្តឹង អាចទទួលយកទម្រង់បែបបទនៃពាក្យបណ្តឹងនេះពីគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ឬអាចធ្វើទម្រង់បែបបទនៃពាក្យបណ្តឹងរបស់ខ្លួនបាន អោយតែទម្រង់បែបបទនោះមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងទម្រង់បែប បទនៃពាក្យបណ្តឹង ដូចមាន កំណត់នៅក្នុងឧបសម្ព័ន្ធទី ១ ។

ពាក្យបណ្តឹង ត្រូវបញ្ចូលពត៌មានស្តីពីដើមបណ្តឹងដូចតទៅ : ឈ្មោះ សញ្ជាតិ ថ្ងៃខែឆ្នាំកំណើត ភេទ ឈ្មោះសហព័ទ្ធ (ប្តី-ប្រពន្ធ) កូន ឃុំ ស្រុក ខេត្ត មុខរបរ អាស័យដ្ឋានបច្ចុប្បន្ន ទីតាំងដីវិវាទ សេចក្តីពណ៌នាពីវិវាទដោយមានភាពជាក់លាក់តាមដែលអាចធ្វើទៅបាន ឯកសារពាក់ព័ន្ធនានា ឈ្មោះ និង អាស័យដ្ឋានរបស់ចុងបណ្តឹង ។ ដើមបណ្តឹងត្រូវផ្តល់រាល់ពត៌មានដូចបានតំរូវនៅក្នុងទម្រង់បែបបទបណ្តឹងហើយត្រូវចុះកាលបរិច្ឆេទ និង ចុះហត្ថលេខា ឬ ផ្តិតមេដៃលើពាក្យបណ្តឹងនោះ ។

ដើមបណ្តឹងត្រូវ ផ្តល់បែបបទបណ្តឹងដែលបំពេញរួចយ៉ាងហោចចំនួន ០៤ ច្បាប់ ដែលមួយច្បាប់សំរាប់រក្សាទុកក្នុងសំណុំឯកសាររបស់គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌមួយច្បាប់សំរាប់បិទផ្សាយ មួយច្បាប់សំរាប់បញ្ជូនទៅអោយដើមបណ្តឹងវិញ និងមួយច្បាប់ទៀតសំរាប់ចុងបណ្តឹង ។ ក្នុងករណីមានចុងបណ្តឹងច្រើននាក់មានឈ្មោះនៅក្នុងពាក្យបណ្តឹងនោះដើមបណ្តឹងត្រូវផ្តល់ឯកសារពាក្យបណ្តឹងមួយច្បាប់ៗដល់ចុងបណ្តឹងម្នាក់ៗដែលមានឈ្មោះ ។

ប្រការ ៦ :-

នៅពេលទទួលពាក្យបណ្តឹង គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវបើកសំណុំរឿង ហើយត្រូវកំណត់លេខដើម្បី ឯការរលំអោយសំណុំរឿងវិវាទតាម ខេត្ត និងស្រុក ដែលដីវិវាទនោះស្ថិតនៅ ។

មន្ត្រីទទួលពាក្យបណ្តឹង ត្រូវចុះលេខសំគាល់សំណុំរឿងវិវាទ ចុះហត្ថលេខា និង បោះត្រាផ្លូវការលើទម្រង់បែបបទនៃពាក្យបណ្តឹងច្បាប់ដើម ហើយផ្តល់ឯកសារដែលបានចុះបញ្ជីមួយច្បាប់ទៅដើមបណ្តឹងវិញ ។ ឯកសារនេះគឺជាភស្តុតាងនៃការដាក់ ពាក្យបណ្តឹងរបស់ដើមបណ្តឹង ។

មន្ត្រីទទួលពាក្យបណ្តឹង ត្រូវថតចម្លងឯកសារនានាដែលបានភ្ជាប់មកជាមួយពាក្យបណ្តឹងហើយត្រូវបញ្ចូលឯកសារថតចម្លងទាំងនេះទៅក្នុងសំណុំរឿងផ្លូវការ ។ មន្ត្រីទទួលពាក្យបណ្តឹង ត្រូវបង្វិលឯកសារច្បាប់ដើមទៅអោយដើមបណ្តឹងវិញ ។

ប្រការ ៧ :-

ក្នុងរយៈពេលប្រាំថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីបានទទួលពាក្យបណ្តឹង គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌត្រូវបិទផ្សាយពាក្យបណ្តឹងនោះរួមជាមួយនិងសេចក្តីជូនដំណឹងអំពីបណ្តឹងរៀបចំឡើងដោយគណៈកម្មការសុរិយោដីថ្នាក់ស្រុកខណ្ឌដែលបញ្ជាក់ថាពាក្យបណ្តឹងនោះបានចុះបញ្ជីហើយ ។ សេចក្តីជូនដំណឹងពីបណ្តឹងត្រូវធ្វើឡើងតាមទម្រង់បែបបទដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី ២ ។ សេចក្តីជូនដំណឹងនោះ ត្រូវអញ្ជើញបុគ្គលគ្រប់រូបដែលមានផលប្រយោជន៍នៅក្នុងដីវិវាទអោយឆ្លើយតបចំពោះពាក្យបណ្តឹងក្នុងរយៈពេល៣០ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការបិទផ្សាយសេចក្តីជូនដំណឹង និង(ពាក្យបណ្តឹងនោះ ។

ពាក្យបណ្តឹង និង សេចក្តីជូនដំណឹងអំពីពាក្យបណ្តឹងមួយច្បាប់ត្រូវបិទផ្សាយនៅការិយាល័យរៀបចំដែនដី នគរូប-នីយកម្ម សំណង់ និង ភូមិបាលស្រុក ខណ្ឌ ហើយសាធារណជនអាចចូលមើលបានដោយសេរីក្នុងអំឡុងពេលម៉ោងធ្វើការធម្មតា ។ ត្រូវអនុញ្ញាតឱ្យជនគ្រប់រូបមើលសេចក្តីជូនដំណឹងដែលបាន បិទផ្សាយនោះដើម្បីអោយដឹងថា តើខ្លួនមានផលប្រយោជន៍នៅក្នុងវិវាទនោះឬទេ ។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវបិទសេចក្តីជូនដំណឹងមួយច្បាប់នៅលើទីតាំងដីដែលមានវិវាទ ។

ក្នុងរយៈពេលប្រាំថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលពាក្យបណ្តឹងគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវជូនដំណឹងដល់ចុងបណ្តឹងដែលមានឈ្មោះនៅក្នុងពាក្យបណ្តឹងអំពីការប្តឹងទាមទារនោះ តាមរយៈការផ្តល់ដល់ចុងបណ្តឹង នូវពាក្យបណ្តឹងដែលបំពេញរួចម្នាក់មួយច្បាប់ ។ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវជូនដំណឹងដល់ចុងបណ្តឹងអំពីសិទ្ធិរបស់ខ្លួនក្នុងការឆ្លើយតបចំពោះបណ្តឹងទាមទារនោះ ហើយត្រូវជូនដំណឹងដល់ចុងបណ្តឹងអំពីសិទ្ធិចូលរួមប្រជុំជាមួយគណៈកម្មការសុរិយោដី ថ្នាក់ស្រុក ខណ្ឌ ដើម្បីពិគ្រោះយោបល់អំពីបណ្តឹង ។ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវផ្តល់អោយចុងបណ្តឹងនូវសេចក្តីសង្ខេបអំពីរបៀបសម្រុះសម្រួល ។

ប្រការ ៨ ៈ-

ចុងបណ្តឹងដែលមានឈ្មោះក្នុងពាក្យបណ្តឹង អាចឆ្លើយតបចំពោះបណ្តឹងតាមរយៈការដាក់សំណុំបែបបទឆ្លើយតបចំពោះបណ្តឹងដែលមានកំណត់ក្នុងឧបសម្ព័ន្ធទី ៤ ទៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ក្នុងរយៈពេល ៣០ថ្ងៃបន្ទាប់ពីបានទទួលឯកសារចម្លងនៃពាក្យបណ្តឹងពីគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ។ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវផ្តល់ដល់ចុងបណ្តឹងនូវឯកសារថតចម្លងមួយច្បាប់នៃពាក្យបណ្តឹង និង សេចក្តីសង្ខេបអំពីរបៀប សម្រុះសម្រួល ។

រាល់បុគ្គលផ្សេងទៀតដែលមានផលប្រយោជន៍នៅក្នុងដីវិវាទនេះ ត្រូវដាក់បែបបទឆ្លើយតបចំពោះបណ្តឹងក្នុងរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីពេលដែលសេចក្តីជូនដំណឹងអំពីបណ្តឹងត្រូវបានបិទផ្សាយនៅការិយាល័យគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ និង នៅលើទីតាំងដីវិវាទដោយគិតតាមកាលបរិច្ឆេទនៃសេចក្តីជូនដំណឹងមួយណាដែលបិទក្រោយគេ ។

ចុងបណ្តឹង អាចទទួលបានទម្រង់បែបបទឆ្លើយតបចំពោះបណ្តឹងពីគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ឬអាចដាក់ទម្រង់បែបបទរបស់ខ្លួនផ្ទាល់បាន អោយតែទម្រង់បែបបទនោះមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងទម្រង់បែបបទដូចមាន កំណត់ក្នុងឧបសម្ព័ន្ធទី ៤ ។

ចុងបណ្តឹងនោះ ត្រូវផ្តល់ទម្រង់បែបបទឆ្លើយតបចំពោះបណ្តឹងដែលបំពេញរួចយ៉ាងហោចចំនួន០៤ច្បាប់ ដែលមួយច្បាប់សំរាប់រក្សាទុកក្នុងសំណុំរឿងរបស់គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ មួយច្បាប់សំរាប់បិទផ្សាយ មួយច្បាប់សំរាប់បញ្ជូនទៅអោយដើមបណ្តឹងវិញ និងមួយច្បាប់ទៀតសំរាប់ចុងបណ្តឹង ។ ក្នុងករណីមានចុងបណ្តឹង ឬ ដើមបណ្តឹងច្រើននាក់មានឈ្មោះនៅក្នុងពាក្យបណ្តឹង នោះចុងបណ្តឹងត្រូវផ្តល់ឯកសារចម្លងឆ្លើយតបចំពោះបណ្តឹងដល់ចុងបណ្តឹង និង/ឬ ដើមបណ្តឹង ដែលមានឈ្មោះ ម្នាក់ៗមួយច្បាប់ ។

ចុងបណ្តឹង ត្រូវបង្ហាញឯកសារពាក់ព័ន្ធនៅពេលដាក់ពាក្យឆ្លើយតបចំពោះបណ្តឹង ។ មន្ត្រីទទួលពាក្យត្រូវថតចម្លងឯកសារដែលបានដាក់ភ្ជាប់មកជាមួយនោះ រួចហើយបង្វិលឯកសារច្បាប់ដើមទាំងនោះទៅអោយចុងបណ្តឹងវិញ ។

ពាក្យឆ្លើយតប និង ឯកសារដែលបានភ្ជាប់មកជាមួយនោះ ត្រូវបញ្ចូលទៅក្នុងសំណុំរឿងវិវាទផ្លូវការ ។

ប្រការ ៩ :-

គ្មានករណីណាមួយដែលដើមបណ្តឹង ឬ ចុងបណ្តឹងណាម្នាក់ត្រូវបានគេសុំ ឬតម្រូវអោយបង់ថ្លៃដាក់ពាក្យបណ្តឹង ឬ ពាក្យឆ្លើយតបឡើយ ។

៣ . ការស៊ើបអង្កេត

ប្រការ ១០ :-

រដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ត្រូវចាត់មន្ត្រីសុរិយោដីចុះទៅធ្វើការស៊ើបអង្កេតបណ្តឹង ។ អ្នកស៊ើបអង្កេតត្រូវចុះទៅជួបភាគីទាំងអស់ កត់ត្រាសេចក្តីអះអាងរបស់ភាគី និងប្រមូលរាល់ពត៌មានទាក់ទងផ្សេងៗ និង ភស្តុតាងផ្សេងៗ ទាក់ទងនឹងវិវាទនោះ រួមទាំងពត៌មានដែលចាំបាច់ដើម្បីកំណត់ថា តើភាគីពាក់ព័ន្ធទាំងអស់ក្នុងវិវាទដីធ្លីនេះមានឈ្មោះនៅក្នុងសំណុំរឿងវិវាទដែលបានដាក់ជូនគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ហើយឬនៅ ថាជាភាគីនៃវិវាទឬ អត់ ។ ការស៊ើបអង្កេតត្រូវចាប់ផ្តើមអោយបានឆាប់បំផុតតាមដែលអាចធ្វើទៅបានបន្ទាប់ពីគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ បានទទួលពាក្យបណ្តឹង ។

ប្រការ ១១ :-

រដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ត្រូវវាស់វែង និងកំណត់ព្រំដីដែលមានវិវាទ ស្របតាមនីតិវិធីដូចមានចែងនៅក្នុងអនុក្រឹត្យស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ ។ ប្រសិនបើរដ្ឋបាលសុរិយោដីស្រុក ខណ្ឌ មិនអាចបំពេញការ៤/..

ទទួលខុសត្រូវនេះបានដោយសារតែខ្លួនពុំមានសមត្ថភាពបច្ចេកទេសគ្រប់គ្រាន់ រដ្ឋបាលសុរិយោដីស្រុក ខណ្ឌ នោះអាចស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាល សុរិយោដីខេត្ត ក្រុង ។

ប្រការ ១២ :-

អ្នកស៊ើបអង្កេតមានសិទ្ធិជួបបុគ្គលណាម្នាក់ ឬ មានសិទ្ធិមើលឯកសារដែលកំណត់ថាចាំបាច់សំរាប់ការស៊ើបអង្កេតឱ្យបានពេញលេញ ។

បុគ្គលទាំងឡាយរួមទាំងសាក្សីរបស់ភាគី និង សាក្សីឯទៀតត្រូវជួបជាមួយអ្នកស៊ើបអង្កេត ប្រសិនបើខ្លួនត្រូវបានស្នើសុំដោយអ្នកស៊ើបអង្កេត ហើយអ្នកស៊ើបអង្កេតត្រូវកំណត់ការប្រជុំតាមពេលវេលា និង ទីកន្លែងដែលងាយស្រួលចំពោះអ្នកពាក់ព័ន្ធ ទាំងឡាយ ។

ឯកសារច្បាប់ដើមទាំងឡាយត្រូវបង្វិលទៅអោយអ្នកដែលផ្តល់ឯកសារនោះវិញ ហើយច្បាប់ថតចម្លងនៃឯកសារនោះត្រូវរក្សាទុកនៅក្នុងកំណត់ហេតុផ្លូវការនៃវិវាទ ។

ប្រការ ១៣ :-

ភាគីវិវាទនីមួយៗ ត្រូវមានវត្តមានក្នុងពេលធ្វើការស៊ើបអង្កេតដល់ទីកន្លែង និងត្រូវប៉ាន់ស្មានសោហ៊ុយដែលទាក់ទងទៅនឹងការស៊ើបអង្កេតបន្ថែមទៀតក្នុងករណីដែលមានភាគីណាមួយអវត្តមាន ។ បើអវត្តមានរបស់ភាគីមួយបង្កឡើងដោយសារទង្វើមិនសមរម្យរបស់ភាគីឯទៀត នោះភាគីដែលមានកំហុសត្រូវចេញសោហ៊ុយសំរាប់ថ្លៃការស៊ើបអង្កេតជាថ្មីនោះ ។

ប្រការ ១៤ :-

ភាគីវិវាទ អាចផ្តល់ភស្តុតាង និងសាក្សីបាន ហើយរាល់ភស្តុតាង និងចម្លើយរបស់សាក្សីទាំងនោះត្រូវក្លាយជាផ្នែកមួយនៃកំណត់ហេតុផ្លូវការនៃវិវាទ ។

អ្នកស៊ើបអង្កេត ត្រូវទទួលយក និង បញ្ចូលជាផ្នែកមួយនៃកំណត់ហេតុផ្លូវការនៃវិវាទនូវរាល់ភស្តុតាងដែលត្រូវបានផ្តល់ដោយភាគី ឬ ដែលត្រូវបានប្រមូលក្នុងអំឡុងពេលធ្វើការស៊ើបអង្កេត ។ ភស្តុតាងទាំងនោះមានជាអាទិ៍ :

- ផែនទី ឬ កំណត់ហេតុអង្កេតវាស់វែង
- ឯកសារសំគាល់ការកាន់កាប់ដី
- រូបថត របស់ភាគីកាន់កាប់ដី

- សំបុត្រស្នាមផ្សេងៗដែលបានធ្វើដោយមានចុះអាស័យដ្ឋាននៃដីនោះ សំបុត្រកំណើត ឬ ប័ណ្ណគ្រួសារ ដែលបង្ហាញពីវត្តមានយូរអង្វែងនៅលើដីនោះ ឬសៀវភៅសម្រង់ស្ថិតិរបស់ប្រធានភូមិ
- ចម្លើយរបស់អ្នកជិតខាងថា តើនរណាដែលបានរស់នៅលើដីនោះ
- បង្កាន់ដៃទទួលប្រាក់ ឬ ឯកសារផ្សេងៗទាក់ទងទៅនឹងការទិញដី ឬ ការផ្ទេរសិទ្ធិនៃដីនោះ ។

ប្រការ ១៥ :-

អ្នកស៊ើបអង្កេត ត្រូវសម្ភាសន៍សាក្សីទាំងឡាយដែលផ្តល់ដោយភាគីវិវាទ ឬ ដែលអ្នកស៊ើបអង្កេតចាត់ទុកថាចាំបាច់ដើម្បីបញ្ជាក់អង្គហេតុនៃវិវាទ ។ សាក្សីនីមួយៗត្រូវធ្វើសម្បថ ថានឹងនិយាយតែការពិតហើយរាយការណ៍រាល់ព្រឹត្តិការណ៍ និង អង្គហេតុទាំងឡាយដែលសាក្សីយល់ និងជឿថាត្រឹមត្រូវ ។

អ្នកស៊ើបអង្កេត ត្រូវពិនិត្យសាក្សីនីមួយៗដើម្បីកំណត់អំពីភាពគួរអោយជឿបាននៅក្នុងចម្លើយរបស់សាក្សី តើសាក្សីដឹងក៏រតណា ការដឹងរបស់សាក្សីផ្អែកលើព្រឹត្តិការណ៍ទាំងឡាយដែលបានសង្កេតឃើញដោយខ្លួនឯងផ្ទាល់ ឬដោយគ្រាន់តែបានឮពីអ្នកណាម្នាក់ផ្សេងទៀត ។ ចម្លើយសាក្សី និង ការសម្ភាសន៍សាក្សីត្រូវទុកជាផ្នែកមួយនៃកំណត់ហេតុផ្លូវការនៃវិវាទ ។

ប្រការ ១៦ :-

អ្នកស៊ើបអង្កេត ត្រូវរៀបចំរបាយការណ៍ជាលាយលក្ខណ៍អក្សរអំពីលទ្ធផលនៃការស៊ើបអង្កេតដោយអនុលោមតាមទំរង់នៃស្តង់ដារដូចមានចែងនៅក្នុងឧបសម្ព័ន្ធទី ៥។ លទ្ធផលទាំងនេះត្រូវរួមបញ្ចូលនូវ ព្រំដីវិវាទ ផែនទី ឬ គំនូសតាងពាក់ព័ន្ធ សេចក្តីសង្ខេបអំពីចម្លើយរបស់សាក្សី និងចម្លើយលាយលក្ខណ៍អក្សរ សេចក្តីសង្ខេបនៃរាល់ឯកសារពាក់ព័ន្ធទៅនឹងដីវិវាទដែលមានការអះអាងដោយអ្នកស៊ើបអង្កេត ឬ ដែលបានទទួលពីភាគីវិវាទ។

៤. ការកំណត់អំពីសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដី ថ្នាក់ស្រុក ខណ្ឌ ក្នុងការសម្រុះសម្រួលវិវាទ

ប្រការ ១៧ :-

បន្ទាប់ពីការស៊ើបអង្កេតត្រូវបានបញ្ចប់ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវកំណត់ថាតើគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ មានសមត្ថកិច្ចធ្វើការសម្រុះសម្រួលវិវាទនោះដែរឬទេ ។

វិវាទទាំងឡាយត្រូវ សម្រុះសម្រួលដោយគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ លើកលែងតែប្រធានគណៈកម្ម-

ការសុរិយោដីថ្នាក់ស្រុក ខណ្ឌ កំណត់ថាវិវាទនោះមិនស្ថិតនៅក្នុងសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ដោយសំអាងលើហេតុផលនានាដូចមានចែងនៅក្នុងប្រការ ១៨ នៃប្រកាសនេះ ឬ ដោយវិវាទនោះកើតឡើងដោយសារភាគីមួយ ឬច្រើនប្តឹងផ្អែកលើមូលដ្ឋានមិនច្បាស់លាស់ដូចមានចែងក្នុងប្រការ ១៩ នៃប្រកាសនេះ ។

ប្រការ ១៨ :-

ប្រសិនបើវិវាទមិនអាចដោះស្រាយបានដោយសមធម៌នៅថ្នាក់ស្រុក ខណ្ឌ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវដាក់សំណុំរឿងវិវាទនោះដោយផ្ទាល់ជូនទៅគណៈកម្មសុរិយោដីថ្នាក់ខេត្ត ក្រុង តាមការយល់ឃើញផ្ទាល់របស់ប្រធាន ឬ តាមសំណើរបស់ភាគីវិវាទទាំងសងខាងដូចមានចែងនៅក្នុងមាត្រា ១០ នៃអនុក្រឹត្យលេខ ៤៧ អនក្រ/បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី ។

ប្រសិនបើមានភាគីតែម្ខាង ស្នើអោយបញ្ជូនករណីវិវាទនោះទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង វិវាទនោះត្រូវបញ្ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុងលើកលែងតែប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ យល់ឃើញថាសំណើនោះមិនសមហេតុផល ។ ហេតុផលនៃការបដិសេធសំណើនោះរួមមានការកំណត់របស់ប្រធានគណៈកម្ម-ការដែលយល់ថាសំណើនោះធ្វើឡើងគ្រាន់តែដើម្បីឱ្យមានការយឺតយ៉ាវដល់ការដោះស្រាយវិវាទ ឬ បង្កអោយមានការលំបាកដល់ភាគីម្ខាងទៀត និងអាច មានហេតុផលផ្សេងទៀត ។

ប្រសិនបើប្រធានគណៈកម្មការ បដិសេធមិនបញ្ជូនវិវាទនោះដោយផ្ទាល់ទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង តាមសំណើរបស់ភាគីម្ខាង ប្រធានគណៈកម្មការត្រូវពន្យល់ជាលាយលក្ខណ៍អក្សរអំពីមូលហេតុនៃការបដិសេធសំណើនោះ ហើយការពន្យល់នេះត្រូវតែជាផ្នែកមួយនៃកំណត់ហេតុផ្លូវការនៃវិវាទនោះ ។ ការសម្រុះសម្រួលដែលតម្រូវឱ្យមានការបញ្ជូនករណីវិវាទ ទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង រួមមាន :

- ជនម្នាក់ទាមទារដីច្រើនក្បាល ដែលជាកម្មវត្ថុនៃការប្តឹងទាមទាររបស់ភាគីតូចតាចមួយចំនួនដែរ
- ភាគីម្ខាងនៃវិវាទគឺជាអាជ្ញាធរមានឋានៈខ្ពស់
- ករណីមានវិវាទពាក់ព័ន្ធទៅនឹងផលប្រយោជន៍របស់ប្រធានគណៈកម្មការថ្នាក់ស្រុក ខណ្ឌ
- វិវាទពាក់ព័ន្ធនឹងដីសាធារណៈរបស់រដ្ឋ ។

ក្នុងករណីណាក៏ដោយ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ មិនមានសិទ្ធិអំណាចសម្រុះសម្រួលវិវាទដែលទាក់ទងទៅ នឹងដីសាធារណៈរបស់រដ្ឋឡើយ ។

ប្រការ ១៩ :-

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវច្រានចោលបណ្តឹងទាមទារណាដែលមិនត្រឹមត្រូវ ឬ គ្មានមូលដ្ឋាន ឬ ដែលធ្វើឡើងដើម្បីយាយី ឬ បំភិតបំភ័យភាគីម្ខាង ។ ការច្រានចោលបណ្តឹងមិនមែនជាប្រការគួរលើកទឹកចិត្តអោយធ្វើនោះទេលើកលែងតែក្នុងករណីចាំបាច់ដើម្បីរារាំងភាពអយុត្តិធម៌តែប៉ុណ្ណោះ ។

បណ្តឹងមិនត្រឹមត្រូវ គឺបណ្តឹងដែលខ្វះមូលដ្ឋានអង្គហេតុសមហេតុផលឬទាក់ទងទៅនឹងវិវាទដែលស្ថិតនៅក្រៅវង្វង់សមត្ថកិច្ចនៃច្បាប់ភូមិបាលឆ្នាំ ២០០១ ។ លក្ខខណ្ឌនៃបណ្តឹងដែលមិនមានមូលដ្ឋានអង្គហេតុគ្រប់គ្រាន់ មានជាអាទិ៍ :

- សាក្សី ឬ ភស្តុតាងរបស់ភាគីម្ខាង បង្ហាញថាមានលក្ខណៈក្លែងបន្លំ ឬ ខុស ដូចជា សាក្សីរបស់ភាគីម្ខាងដកពាក្យចម្លើយរបស់ខ្លួនវិញ ឬ ផ្តល់ចម្លើយដែលប្រឆាំងដោយត្រង់ទៅនឹងការទាមទាររបស់ភាគីម្ខាង
- ការស៊ើបអង្កេត និងពត៌មានផ្សេងទៀតដែលភាគីស្នើឡើងមិនបង្ហាញភស្តុតាងណាមួយដែលគាំទ្រដល់ការទាមទាររបស់ភាគីដូចមានក្នុងពាក្យបណ្តឹង ។

ក្នុងករណីបណ្តឹងត្រូវបានច្រានចោល ភាគីអាចប្តឹងតវ៉ាទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ។

ភាគីណាមួយដែលធ្វើការទាមទារដោយគ្មានមូលដ្ឋាន ឬ មិនមានលក្ខណៈច្បាប់ ត្រូវចេញសោហ៊ុយថ្លៃដំណើរការវិវាទដែលបានចំណាយមកដល់ពេលនោះ និង ត្រូវទទួលទោសព្រហ្មទណ្ឌបន្ថែមទៀតដោយអនុលោមតាមច្បាប់ភូមិបាល ២០០១ និង ច្បាប់ផ្សេងៗទៀត ។ ត្រូវរារាំងមិនអោយភាគីដែលដាក់ពាក្យបណ្តឹងមិនត្រឹមត្រូវ ប្តឹងទាមទារជាថ្មីម្តងទៀត ។

ភាគីណាដែលបង្ហាញភស្តុតាងក្លែងបន្លំ ត្រូវដកចេញពីដំណើរការវិវាទ ហើយភស្តុតាងត្រូវដកចេញពីកំណត់ហេតុផ្លូវការនៃវិវាទ និងត្រូវទទួលទោសព្រហ្មទណ្ឌបន្ថែមទៀតដូចមានចែងនៅក្នុងច្បាប់ភូមិបាល ២០០១ និងច្បាប់ផ្សេងៗទៀត។ ភាគីណាដែលត្រូវបានរកឃើញថា បានធ្វើការក្លែងបន្លំភស្តុតាង ឬឯកសារអាចទទួលទោសព្រហ្មទណ្ឌដូចមានចែងនៅក្នុងច្បាប់ភូមិបាល ឆ្នាំ ២០០១ និង ច្បាប់ផ្សេងៗទៀត។

៥. ការសម្រុះសម្រួលរបស់គណៈកម្មការ សុរិយោដីថ្នាក់ស្រុក ខណ្ឌ

ប្រការ ២០ :-

បន្ទាប់ពីបញ្ចប់ការស៊ើបអង្កេត មិនតិចជាង ៣០ ថ្ងៃបន្ទាប់ពីសេចក្តីជូនដំណឹងពីបណ្តឹងត្រូវបានបិទផ្សាយដូចមានចែងក្នុងប្រការ ៧នៃប្រកាសនេះប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវរៀបចំប្រជុំគណៈកម្មការសុរិយោដី...

ថ្នាក់ស្រុក ខណ្ឌដើម្បីសំរេចលើដំណើរការសម្រុះសម្រួលវិវាទ ។ កិច្ចប្រជុំត្រូវធ្វើឡើងនៅលើដីវិវាទ ឬកន្លែងដែលនៅជិតដីវិវាទតាមដែលអាចធ្វើទៅបាន ។

ប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវអញ្ជើញតំណាងអាជ្ញាធរដែនដីស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិ និង/ឬ ចាស់ព្រឹទ្ធាចារ្យនៅក្នុងមូលដ្ឋានឱ្យចូលរួមជាសមាជិកអាដហុករបស់គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ដើម្បីសម្រុះសម្រួលវិវាទ ។ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ គប្បីយកចិត្តទុកដាក់បញ្ចូលស្ត្រីជាសមាជិកគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវអញ្ជើញភាគីវិវាទមកចូលរួមការប្រជុំរដ្ឋបាលយ៉ាងហោច ៥ ថ្ងៃនៃថ្ងៃធ្វើការមុនថ្ងៃប្រជុំនេះ ។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវផ្តល់ដល់ភាគីទាំងអស់នូវសេចក្តីសង្ខេបអំពីរបៀបសម្រុះសម្រួល និងត្រូវពន្យល់អំពីពត៌មាននេះដល់ភាគីទាំងអស់ ។

នៅពេលប្រជុំរដ្ឋបាលនេះ ភាគីត្រូវជូនដំណឹងដល់គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ អំពីការស្នើសុំរបស់ខ្លួនឱ្យបញ្ជូនសំណុំរឿងវិវាទនេះទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវធ្វើការជំទាស់ចំពោះវិវាទអំពីផលប្រយោជន៍នានា និង ធ្វើការព្រមព្រៀងជាឯកច្ឆ័ន្ទលើសមាសភាពអ្នកសម្រុះសម្រួលដូចមានចែងក្នុង ប្រការ ២២ នៃប្រកាសនេះ ។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌត្រូវដោះស្រាយរាល់វិវាទអំពីផលប្រយោជន៍ និងកំណត់អ្នកសម្រុះសម្រួលវិវាទ ។ បន្ទាប់មក អ្នកសម្រុះសម្រួលត្រូវជួបជាមួយភាគីទាំងឡាយ និង កំណត់ពេលវេលាសំរាប់ការសម្រុះសម្រួលវិវាទ ។

ប្រការ ២១ :-

ប្រសិនបើ មានសមាជិកណាម្នាក់នៃគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ មានផលប្រយោជន៍នៅក្នុងវិវាទ សមាជិករូបនោះត្រូវដកខ្លួនចេញពីការដោះស្រាយវិវាទនោះហើយគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវតែងតាំងសមាជិកថ្មីជំនួសវិញ ។

ប្រសិនបើ មានវិវាទអំពីផលប្រយោជន៍ជាមួយប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ វិវាទនោះត្រូវដាក់ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ។

ភាគីអាចប្តឹងជំទាស់ជាលាយលក្ខណ៍អក្សរចំពោះការចូលរួមរបស់សមាជិកណាម្នាក់នៃគណៈកម្មការសុរិយោដីថ្នាក់ស្រុកខណ្ឌដោយផ្អែកលើមូលដ្ឋាននៃវិវាទអំពីផលប្រយោជន៍របស់សមាជិក ។ សមាជិកដទៃទៀតនៃគណៈកម្មការត្រូវសំរេចថាតើ សមាជិករូបនោះមានវិវាទអំពីផលប្រយោជន៍ដែលរារាំងមិនឱ្យសមាជិករូបនោះចូលរួមនៅក្នុងការដោះស្រាយវិវាទ ឬទេ ។ វិវាទអំពីផលប្រយោជន៍ដែលចោទប្រកាន់ចំពោះប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវដោះស្រាយតាមនីតិវិធីដូចមានកំណត់ក្នុងប្រការ ១៨ នៃប្រកាសនេះ ។

ប្រការ ២២ :-

ភាគីវិវាទ អាចជ្រើសរើសអ្នកសម្រុះសម្រួលក្នុងចំណោមសមាជិកអាជហុក និងសមាជិកអចិន្ត្រៃយ៍នៃគណៈ-កម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ នៅក្នុងលក្ខខណ្ឌតែមួយគត់គឺភាគីទាំងអស់ព្រមព្រៀងគ្នាជាលាយលក្ខណ៍អក្សរក្នុងការប្រើអ្នកសម្រុះសម្រួលជាក់លាក់នោះ ។

ក្នុងករណីភាគីវិវាទមិនអាចព្រមព្រៀងគ្នាលើសមាសភាពអ្នកសម្រុះសម្រួលជាក់លាក់ណាមួយមកពីគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌទេនោះ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវចាត់តាំងអ្នកសម្រុះសម្រួលចេញពីសមាជិកអាជហុក និង សមាជិកអចិន្ត្រៃយ៍នៃគណៈកម្មការ ។

ក្រុមអ្នកសម្រុះសម្រួលមានសមាជិក ៣ រូប ដែលមានម្នាក់ជាប្រធាន ត្រូវសម្រុះសម្រួលវិវាទ ។

សមាជិកទាំងឡាយនៃក្រុមអ្នកសម្រុះសម្រួល យ៉ាងហោចណាស់ត្រូវមានសមាជិកម្នាក់ដែលបានទទួលការបណ្តុះបណ្តាល ឬមានបទពិសោធន៍នៅក្នុងការសម្រុះសម្រួលវិវាទ និង មានសមាជិកម្នាក់ជាអ្នកដឹងអំពីស្ថានភាព និងសភាពការណ៍នៅក្នុង មូលដ្ឋាន ។

ប្រសិនបើ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ កំណត់ថាគ្មានសមាជិកណាម្នាក់នៃសមាជិកក្រុមអ្នកសម្រុះសម្រួលមានបទពិសោធន៍ ឬ ការបណ្តុះបណ្តាលនៅក្នុងដំណើរការសម្រុះសម្រួលទេនោះ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ អាចស្នើសុំឱ្យគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ចាត់តាំងអ្នកសម្រុះសម្រួលដែលបានទទួលការបណ្តុះបណ្តាលអោយចូលរួមនៅក្នុងក្រុមអ្នកសម្រុះសម្រួល ។

ប្រការ ២៣ :-

ភាគីវិវាទអាចជ្រើសរើសបុគ្គលម្នាក់តាមជំរើសរបស់ខ្លួនផ្ទាល់ឱ្យជួយខ្លួននៅគ្រប់ថ្នាក់នៃដំណើរការសម្រុះសម្រួល ។ បុគ្គលរូបនេះហៅថាអ្នកជំនួយការភាគី ឬអ្នកជំនួយការមិនអាចតំណាងឱ្យភាគីបានទេ ប៉ុន្តែអាចផ្តល់យោបល់ដល់ភាគីវិវាទបាន ។ អ្នកជំនួយការភាគី អាចបំភ្លឺយោបល់របស់ភាគី និងអាចចូលរួមនៅក្នុងកិច្ចប្រជុំទាំងឡាយជាមួយអ្នក

សម្រុះសម្រួល និងជាមួយភាគីបាន ប៉ុន្តែមិនអាចនិយាយជំនួសភាគីទៅកាន់អ្នកសម្រុះសម្រួល ឬ ភាគីផ្សេងទៀតបានទេ ឬ មិនអាចធ្វើសេចក្តីសំរេចក្នុងនាមភាគីបានឡើយ ។

ប្រសិនបើអ្នកជំនួយការភាគីនោះបំពានវិធាននៃដំណើរការវិវាទ ក្រុមអ្នកសម្រុះសម្រួលត្រូវផ្តល់ការក្រើនរំលឹក និងការព្រមានជាឯកជនម្តងដល់អ្នកជំនួយការនោះ ។ ប្រសិនបើអ្នកជំនួយការនោះបន្តបំពានទៀតក្រុមអ្នកសម្រុះសម្រួលត្រូវហាមឃាត់អ្នកជំនួយការនោះមិនឱ្យចូលរួមនៅក្នុងដំណើរការវិវាទតទៅទៀតឡើយ ។ ប្រសិនបើអ្នកជំនួយការត្រូវបានរារាំង ដំណើរការសម្រុះសម្រួលត្រូវផ្អាកមួយរយៈរហូតដល់ភាគីវិវាទជ្រើសរើសអ្នកជំនួយការថ្មីបាន ឬ ព្រមព្រៀងបន្តដំណើរការដោយពុំចាំបាច់មានអ្នកជំនួយការ ។ អ្នកសម្រុះសម្រួលត្រូវផ្តល់អោយភាគីម្ខាងៗនូវឱកាសគ្រប់គ្រាន់ដើម្បីពិគ្រោះយោបល់ជាមួយអ្នកជំនួយការដែលត្រូវបានហាមឃាត់នៅខាងក្រៅកន្លែងធ្វើការសម្រុះសម្រួល ។

ប្រការ ២៤ :-

អ្នកសម្រុះសម្រួលត្រូវជួបជាមួយភាគីទាំងឡាយរួមគ្នា ឬ ដាច់ដោយឡែកពីគ្នាប្រសិនបើមានការស្នើសុំដើម្បីពិភាក្សាពីបញ្ហារបស់ភាគី ពន្យល់ករណីវិវាទដល់ភាគីវិវាទដោយផ្អែកលើភស្តុតាង និងពិគ្រោះអំពីលទ្ធភាពដំណោះ-ស្រាយនានាដែលអាចមានចំពោះវិវាទ ។ ការពិគ្រោះត្រូវធ្វើឡើងដោយរក្សាការសំងាត់ក្នុងចំណោមភាគីវិវាទអ្នកជំនួយការរបស់ភាគី និង អ្នកសម្រុះសម្រួលហើយមិនត្រូវយកការពិគ្រោះនេះទៅធ្វើជាផ្អែកមួយនៃកំណត់ហេតុផ្លូវការនៃវិវាទឡើយ ។

អ្នកសម្រុះសម្រួល អាចស្នើដំណោះស្រាយដោយផ្អែកលើការយល់ដឹងរបស់ខ្លួនអំពីបំណងរបស់ភាគីវិវាទលើភស្តុតាងដែលមាន និងផ្អែកលើច្បាប់ពាក់ព័ន្ធប៉ុន្តែអ្នកសម្រុះសម្រួលមិនត្រូវបង្ខំឱ្យអនុវត្តតាមសំណើរបស់ខ្លួន ឬ មិនត្រូវធ្វើសេចក្តីសំរេចលើ វិវាទនោះឡើយ ។ មានតែភាគីវិវាទទេដែលមានសិទ្ធិសំរេច ឬបដិសេធដំណោះស្រាយបាន ។

ប្រការ ២៥ :-

អ្នកសម្រុះសម្រួលត្រូវវិភាគភស្តុតាង ដែលប្រមូលបាននៅក្នុងពេលស៊ើបអង្កេតដើម្បីយល់អោយបានពេញលេញអំពីស្ថានភាពនៃវិវាទ ប៉ុន្តែអ្នកសម្រុះសម្រួលមិនត្រូវវាយតំលៃភស្តុតាងក្នុងសមត្ថភាពជាផ្លូវការណាមួយឡើយ ។

អ្នកសម្រុះសម្រួលអាចផ្តល់យោបល់ដល់ភាគីវិវាទ អំពីរបៀបបកស្រាយភស្តុតាងវិវាទ ឬ តំលៃនៃភស្តុតាងអាចត្រូវបានបកស្រាយយ៉ាងណា ប៉ុន្តែយោបល់ទាំងនោះពុំមានតំលៃខាងផ្លូវច្បាប់ និង មិនអាចក្លាយជាលំអានសំរាប់អនុវត្តនៅក្នុងដំណើរការសម្រុះសម្រួល ឬ ការវិនិច្ឆ័យណាមួយឡើយ ។

ការវាយតម្លៃភស្តុតាង អាចបញ្ចូលជាផ្នែកមួយនៃរបាយការណ៍សម្រុះសម្រួលដែលត្រូវបញ្ចូលទៅក្នុងកំណត់ហេតុផ្លូវការ នៃវិវាទ ។

ប្រការ ២៦ :-

ប្រសិនបើភាគីទាំងឡាយ អាចឈានដល់ការព្រមព្រៀងក្នុងពេលសម្រុះសម្រួលដោយគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ អ្នកសម្រុះសម្រួលត្រូវបំពេញបែបបទបញ្ចប់វិវាទដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី ៦ ដែលមានរៀបរាប់អំពីដំណើរការដំណោះស្រាយដោយបញ្ជាក់ច្បាស់លាស់ពីការព្រមព្រៀងដោះស្រាយនោះ ។ រាល់ឯកសារឬផែនទីនានាដែលអាចបំភ្លឺកិច្ចដំណោះស្រាយនោះត្រូវតម្កល់ជាមួយបែបបទបញ្ចប់វិវាទ ។

អ្នកសម្រុះសម្រួល ត្រូវអានដំណោះស្រាយព្រមព្រៀងអោយភាគីទាំងអស់ស្តាប់ ។ ភាគីវិវាទត្រូវចុះហត្ថលេខា ឬផ្តិតមេដៃលើកិច្ចព្រមព្រៀងតែក្នុងករណីដែលភាគីនោះយល់ព្រមលើរាល់ចំណុចនៃកិច្ចព្រមព្រៀង ។ កិច្ចព្រមព្រៀងនឹងមានសុពលភាពក្នុងករណីដែលភាគីវិវាទទាំងអស់បានព្រមព្រៀង និងបានចុះហត្ថលេខា ឬ បានផ្តិតមេដៃ ។ ភាគីវិវាទត្រូវចុះហត្ថលេខា ឬផ្តិតមេដៃលើបែបបទបញ្ចប់រឿងក្តីរួចតម្កល់បែបបទនោះនៅគណៈកម្មការសុរិយោដីថ្នាក់ស្រុកខណ្ឌ។ មន្ត្រីទទួលទម្រង់បែបបទបញ្ចប់រឿងក្តីត្រូវចុះហត្ថលេខា និង បោះត្រាផ្លូវការលើទម្រង់បែបបទនេះហើយត្រូវផ្តល់ដល់ភាគីវិវាទនីមួយៗនូវឯកសារថតចម្លងនៃបែបបទនេះ ។ ច្បាប់ថតចម្លងនៃបែបបទបញ្ចប់រឿងក្តីនេះគឺជាភស្តុតាងនៃការដាក់តម្កល់កិច្ចដំណោះស្រាយ ។

រាល់ឯកសារទាក់ទងទៅនឹងលទ្ធផលនៃការដោះស្រាយវិវាទរួមទាំងបែបបទបញ្ចប់រឿងក្តី សេចក្តីពណ៌នានៃកិច្ចដំណោះស្រាយ និង ផែនទី ឬ គំនូសតាងនានាដែលអាចបំភ្លឺកិច្ចដំណោះស្រាយ ត្រូវបិទផ្សាយជាសាធារណៈដែលមានរយៈពេលមិនតិចជាង ១៤ ថ្ងៃ ។ បុគ្គលណាក៏ដោយក៏អាចបញ្ចេញមតិលើឯកសារបញ្ចប់រឿងក្តីនេះក្នុងអំឡុងពេលប្រកាសផ្សាយជាសាធារណៈ ។

ក្រុមអ្នកសម្រុះសម្រួល ត្រូវរាយការណ៍អំពីកិច្ចដំណោះស្រាយរបស់គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ទៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និង ភូមិបាលស្រុក ខណ្ឌ និងគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ។ បន្ទាប់មកការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ ត្រូវចាប់ផ្តើមនីតិវិធីចុះបញ្ជីក្បាលដីដែលបានដោះស្រាយរួចនោះ ។

ប្រការ ២៧ :-

ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ ត្រូវបញ្ជាក់អំពីដំណោះស្រាយជាមួយភាគីវិវាទ និងត្រូវចាប់ផ្តើមអនុវត្តនីតិវិធីចុះបញ្ជីក្បាលដីដែលបានដោះស្រាយរួចនោះនៅពេលទទួលបានការបញ្ជាក់ថា ដំណោះស្រាយបានសំរេចដោយស្ម័គ្រចិត្ត និង ថាភាគីវិវាទយល់ពីកិច្ចព្រមព្រៀង ។

ប្រការ ២៨ :-

ប្រសិនបើភាគីមិនអាចឈានដល់ដំណោះស្រាយ ក្រុមអ្នកសម្រុះសម្រួលត្រូវរៀបចំរបាយការណ៍ស្តីពីដំណើរការសម្រុះសម្រួលអនុលោមតាមបែបបទស្តង់ដារដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី៧ ។ របាយការណ៍ត្រូវរួមបញ្ចូលពតិមានជាមូលដ្ឋានស្តីពីភាគីវិវាទ សេចក្តីសង្ខេបជំហររបស់ភាគីវិវាទនិងសេចក្តីសង្ខេបអំពីដំណើរការសម្រុះសម្រួល។ របាយការណ៍នេះត្រូវក្លាយជាផ្នែកមួយនៃកំណត់ហេតុសាធារណៈផ្លូវការនៃវិវាទ និង ត្រូវបញ្ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ។

៦. ការសម្រុះសម្រួលរបស់គណៈកម្មការ សុរិយោដីថ្នាក់ខេត្ត ក្រុង

ប្រការ ២៩ :-

ករណីសម្រុះសម្រួលជំហានដំបូង រួមមានវិវាទដែលត្រូវបានបញ្ជូនទៅឱ្យគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ដើម្បីធ្វើការសម្រុះសម្រួលដោយផ្ទាល់ដោយអនុលោមតាមប្រការ១៨ និងប្រការ២១ នៃប្រកាសនេះ ។ ករណីសម្រុះ-សម្រួលជំហានដំបូង ត្រូវបានបញ្ជូនអមជាមួយកំណត់ហេតុផ្លូវការពេញលេញនៃវិវាទទៅអោយគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ។

ប្រការ ៣០ :-

ករណីសម្រុះសម្រួលជំហានទី២ រួមមានវិវាទដែលដោះស្រាយមិនបានសំរេចនៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ។ ករណីសម្រុះសម្រួលជំហានទី ២ត្រូវបញ្ជូនអមជាមួយកំណត់ហេតុផ្លូវការពេញលេញ និងរបាយការណ៍សម្រុះ-សម្រួលទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ។

ប្រការ ៣១ :-

ក្នុងរយៈពេល ៦០ថ្ងៃ បន្ទាប់ពីបានទទួលបណ្តឹងវិវាទសំរាប់ការសម្រុះសម្រួលជំហានដំបូង ឬ ការសម្រុះសម្រួលជំហានទី២ គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុងត្រូវរៀបចំកិច្ចប្រជុំរដ្ឋបាលរវាងគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង និងភាគីវិវាទ។

ប្រធានគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង អាចអញ្ជើញតំណាងរបស់អាជ្ញាធរដែនដី ស្រុក ខណ្ឌ ឃុំ សង្កាត់ ឬមន្ទីរជុំវិញខេត្តក្រុងពាក់ព័ន្ធនានាអោយចូលរួមជាសមាជិកអាដហុកដើម្បីសម្រុះសម្រួលវិវាទ ។ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង គប្បីយកចិត្តទុកដាក់បញ្ចូលស្ត្រីជាសមាជិកនៃគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ។

ក្នុងអំឡុងពេលនៃកិច្ចប្រជុំរដ្ឋបាលដំបូង ភាគីវិវាទត្រូវលើកសំណើ និង ការជំទាស់ចំពោះវិវាទអំពីផលប្រយោជន៍ ប្រសិនបើមាន ។ គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវដោះស្រាយរាល់វិវាទអំពីផលប្រយោជន៍ និងកំណត់អ្នកសម្រុះសម្រួលសំរាប់វិវាទនោះ ។ បន្ទាប់មក អ្នកសម្រុះសម្រួលត្រូវជួបជាមួយភាគីវិវាទ និងកំណត់ពេលវេលាសំរាប់អោយភាគីបង្ហាញភស្តុតាងបន្ថែមនានា និង ពេលវេលាសំរាប់សម្រុះសម្រួលវិវាទ ។

ប្រការ ៣២ :-

ប្រសិនបើសមាជិកណាម្នាក់នៃគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុងមានផលប្រយោជន៍ក្នុងវិវាទសមាជិករូបនោះត្រូវដកខ្លួនចេញពីការដោះស្រាយវិវាទនោះហើយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចតែងតាំងសមាជិកថ្មីជំនួសវិញ ។

ភាគី អាចដាក់ពាក្យបណ្តឹងជំទាស់ជាលាយលក្ខណ៍អក្សរចំពោះការចូលរួមរបស់សមាជិកគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុងណាម្នាក់រួមទាំងប្រធានគណៈកម្មការដោយផ្អែកលើមូលដ្ឋាននៃវិវាទអំពីផលប្រយោជន៍របស់សមាជិក ។ សមាជិកដទៃទៀតនៃគណៈកម្មការ ត្រូវសំរេចថាតើសមាជិកដែលត្រូវជំទាស់អំពីវិវាទផលប្រយោជន៍នោះត្រូវរារាំងមិនឱ្យសាមីខ្លួនចូលរួមក្នុង ការដោះស្រាយវិវាទឬទេ ។

ប្រការ ៣៣ :-

ភាគីទាំងឡាយ អាចជ្រើសរើសអ្នកសម្រុះសម្រួលក្នុងចំណោមសមាជិកអាដហុក និង សមាជិកអចិន្ត្រៃយ៍នៃគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង នៅក្នុងលក្ខខណ្ឌតែមួយគឺ ភាគីវិវាទទាំងអស់ព្រមព្រៀងជាលាយលក្ខណ៍អក្សរចំពោះការប្រើប្រាស់អ្នកសម្រុះសម្រួលនោះ ។ ក្នុងករណីភាគីវិវាទទាំងអស់មិនព្រមព្រៀងលើសមាសភាពអ្នកសម្រុះសម្រួលណាមួយដែលមកពីគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង នោះប្រធានគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុងត្រូវចាត់តាំងក្រុមអ្នកសម្រុះសម្រួលក្នុងចំណោមសមាជិកអាដហុក និង សមាជិកអចិន្ត្រៃយ៍នៃគណៈកម្មការ ។

ក្រុមអ្នកសម្រុះសម្រួលមានសមាជិក ៣រូប ដែលមានម្នាក់ជាប្រធានត្រូវសម្រុះសម្រួលវិវាទ ។ ក្រុមអ្នកសម្រុះសម្រួល យ៉ាងហោចណាស់ត្រូវរួមបញ្ចូលសមាជិកមួយរូបជាអ្នកបានទទួលការបណ្តុះបណ្តាល ឬ មានបទពិសោធន៍ក្នុងការសម្រុះសម្រួលវិវាទ និង សមាជិកមួយរូបជាអ្នកដឹងពីស្ថានភាព និង សភាពការណ៍នៅក្នុងមូលដ្ឋាន ។

ប្រការ ៣៤ :-

អ្នកសម្រុះសម្រួលត្រូវធ្វើការសម្រុះសម្រួលនៅលើទីតាំងដី ឬ នៅជិតដីវិវាទ លើកលែងតែមានហេតុផលបញ្ជាក់ថាមានការគំរាមកំហែងដល់សន្តិសុខរបស់មន្ត្រីគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ។ ក្នុងករណីអសន្តិសុខដំណើរការសម្រុះសម្រួល វិវាទត្រូវធ្វើឡើងនៅទីកន្លែងដែលមានសន្តិសុខដែលនៅជិតដីវិវាទបំផុត ។

នីតិវិធីរដ្ឋបាលសំរាប់សម្រុះសម្រួលរបស់គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវដូចគ្នានឹងនីតិវិធីទាំងឡាយរបស់គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ដែលមានចែងលំអិតនៅក្នុងប្រការ ២៤ នៃប្រកាសនេះ ។

ប្រការ ៣៥ :-

នីតិវិធីរដ្ឋបាលនៃដំណោះស្រាយរបស់គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុងត្រូវដូចគ្នានឹងនីតិវិធីទាំងឡាយសំរាប់កិច្ចដំណោះស្រាយនៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ដែលមានចែងលំអិតនៅក្នុង ប្រការ២៦ នៃប្រកាសនេះ ។

អ្នកសម្រុះសម្រួល ត្រូវបញ្ជូនកិច្ចដំណោះស្រាយរបស់គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ទៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និង ភូមិបាលស្រុក ខណ្ឌ ដើម្បីចុះបញ្ជីក្បាលដី ។

ប្រការ ៣៦ :-

នីតិវិធីរដ្ឋបាលសំរាប់បញ្ជាក់អំពីកិច្ចដំណោះស្រាយដែលសំរេចបាននៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវដូចគ្នានឹងនីតិវិធីទាំងឡាយនៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ដែលមានចែងលំអិតនៅក្នុងប្រការ ២៧ នៃប្រកាសនេះ ។

ប្រការ ៣៧ :-

នីតិវិធីរដ្ឋបាលសំរាប់ការធ្វើរបាយការណ៍សម្រុះសម្រួលនៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវដូចគ្នានឹងនីតិវិធីទាំងឡាយនៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ដែលមានចែងលំអិតនៅក្នុងប្រការ២៨ នៃ ប្រកាសនេះ ។

៧. ដំណើរការដោះស្រាយវិវាទរបស់ គណៈកម្មការសុរិយោដីថ្នាក់ជាតិ

ប្រការ ៣៨ :-

គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានសិទ្ធិសំរេចវិវាទទាំងឡាយដែលស្ថិតនៅក្រៅតំបន់វិនិច្ឆ័យ ហើយដែលមិនអាចដោះស្រាយបានដោយគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ និងគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង និងរាល់វិវាទដែលកើតមាននៅក្នុងតំបន់វិនិច្ឆ័យដែលមិនអាចដោះស្រាយបានដោយគណៈកម្មការរដ្ឋបាល ។

លើកលែងតែក្នុងករណីបន្ទាន់ដូចមានពណ៌នាក្នុងប្រការ៣៩នៃប្រកាសនេះ គណៈកម្មការសុរិយោដីថ្នាក់ជាតិមិនត្រូវពិនិត្យករណីទាំងឡាយក្នុងឋានៈជាក្រុមអ្នកសម្រុះសម្រួលជំហានដំបូងចំពោះករណីវិវាទណាមួយឡើយ ។

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ឬគណៈកម្មការរដ្ឋបាល ត្រូវបញ្ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិនូវករណីវិវាទអមជាមួយកំណត់ហេតុផ្លូវការទាំងមូល និងរបាយការណ៍សម្រុះសម្រួលដែលសង្ខេបដំណើរការវិវាទដែលបានធ្វើនៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ និងគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ឬ នៅគណៈកម្មការរដ្ឋបាលតាមករណីជាក់ស្តែង ។

ប្រការ ៣៩ :-

ក្នុងករណីវិវាទដែលតម្រូវឱ្យមានការសំរេច ឬ ដំណើរការដោះស្រាយជាបន្ទាន់ ដូចជាករណី មានការគំរាមកំហែង ឬការភ័យខ្លាចសមហេតុផលកើតឡើងពីការបង្កអគ្គីភ័យ ការប្រើកំលាំង ឬ ការបំភិតបំភ័យ ភាគីវិវាទអាចស្នើទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិអោយចាត់វិធានការបណ្តោះអាសន្នដើម្បីការពារផលប្រយោជន៍របស់ភាគីនៅពេលដែលវិវាទកំពុងធ្វើការដោះស្រាយ ។ ក្នុងស្ថានភាពនេះ ភាគីអាចប្តឹងដោយផ្ទាល់ទៅគណៈកម្មការសុរិយោដីថ្នាក់ ជាតិឱ្យចេញសេចក្តីសំរេចបណ្តោះអាសន្ន ដើម្បីធ្វើអោយស្ថានការណ៍មានស្ថេរភាពរហូតដល់មានការស៊ើបអង្កេត និង សេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ។ សេចក្តីសំរេចបណ្តោះអាសន្នត្រូវមានខ្លឹមសារជាការរក្សាស្ថានភាពដដែល ។

ប្រការ ៤០ :-

ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវកោះប្រជុំគណៈកម្មការសុរិយោដីថ្នាក់ជាតិ តាមតម្រូវការដើម្បីដោះស្រាយវិវាទ ។

ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ អាចអញ្ជើញតំណាងក្រសួង និង ស្ថាប័នពាក់ព័ន្ធអោយចូលរួមជាសមាជិកអាដហុកដើម្បីដោះស្រាយវិវាទ ។ ប្រធានគប្បីយកចិត្តទុកដាក់បញ្ចូលស្ត្រីជាសមាជិកនៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

ប្រការ ៤១ :-

បន្ទាប់ពីត្រួតពិនិត្យមើលកំណត់ហេតុផ្លូវការនៃវិវាទ ឬ នៅពេលផ្សេងទៀតក្នុងអំឡុងពេលធ្វើការពិនិត្យវិវាទដោយគណៈកម្មការសុរិយោដីថ្នាក់ជាតិ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិអាចសំរេចធ្វើការសម្រុះសម្រួលវិវាទបន្ថែមទៀត ។

នៅក្នុងស្ថានភាពនេះនីតិវិធីរដ្ឋបាលដើម្បីសម្រុះសម្រួលនៅថ្នាក់ជាតិត្រូវអនុវត្តដូចនីតិវិធីទាំងឡាយសំរាប់គណៈ-កម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ដូចមានចែងលំអិតក្នុងប្រការ ២៤ នៃប្រកាសនេះ ។

ប្រសិនបើការសម្រុះសម្រួលមិនបានសំរេច ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវកំណត់កាលបរិច្ឆេទសំរាប់ការធ្វើសវនាការដោយគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

ភាគីអាចស្នើសុំគណៈកម្មការសុរិយោដីថ្នាក់ជាតិឱ្យបញ្ជូនក្រុមអ្នកវិនិច្ឆ័យចល័តទៅកាន់ខេត្ត ក្រុង ស្រុក ខណ្ឌ ។ ក្នុងករណីដែលគ្មានការព្រមព្រៀងគ្នារវាងភាគី ទីកន្លែងធ្វើសវនាការត្រូវស្ថិតនៅជិតដីវិវាទបំផុត ។ នៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ គូវិវាទត្រូវកំណត់ពេលវេលាដើម្បីចុះទៅពិនិត្យមើលទីតាំងដីវិវាទ ឬ ព្រមព្រៀងលើកលែងការស៊ើបអង្កេតបន្ថែមទៀតបាន ។

ប្រការ ៤២ :-

ប្រសិនបើ សមាជិកណាម្នាក់នៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ មានផលប្រយោជន៍នៅក្នុងវិវាទ សមាជិកនោះត្រូវដកខ្លួនចេញពីការដោះស្រាយវិវាទ ហើយប្រសិនបើចាំបាច់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ អាចតែងតាំងសមាជិកថ្មីជំនួសវិញ ។

ភាគីអាច ដាក់ពាក្យបណ្តឹងជំទាស់ជាលាយលក្ខណ៍អក្សរចំពោះការចូលរួមរបស់សមាជិករួមទាំងប្រធានគណៈកម្ម-ការសុរិយោដីថ្នាក់ជាតិដោយផ្អែកលើវិវាទអំពីផលប្រយោជន៍របស់សមាជិកនោះ ។ សមាជិកដទៃទៀតនៃ គណៈកម្មការត្រូវសំរេចថា តើសមាជិកដែលត្រូវជំទាស់អំពីវិវាទអំពីផលប្រយោជន៍នោះត្រូវរារាំងមិនអោយចូលរួមក្នុងការដោះស្រាយវិវាទ ឬ ទេ ។

ប្រការ ៤៣ :-

រាល់កិច្ចប្រជុំ ឬសវនាការដែលគណៈកម្មការសុរិយោដីថ្នាក់ជាតិចាត់វិធានការផ្លូវការទាក់ទងទៅនឹងវិវាទត្រូវបើកចំហជាសាធារណៈ ។

សេចក្តីជូនដំណឹងជាមុនអំពីរាល់កិច្ចប្រជុំ ឬ សវនាការដែលជាការចាត់វិធានការផ្លូវការត្រូវជូនដល់សាធារណជន និង ប្រព័ន្ធសារពត៌មាន ។ លេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវរក្សាទុកកំណត់ហេតុនៃដំណើរការរឿងវិវាទទាំងអស់របស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ហើយបុគ្គលណាក៏មានសិទ្ធិមើលកំណត់ហេតុទាំងនោះទោះបីបុគ្គលនោះមាន ឬគ្មានផលប្រយោជន៍នៅក្នុងវិវាទនោះក្តី ។

ប្រការ ៤៤ :-

លើកលែង តែការប្រជុំសំរាប់ការសម្រុះសម្រួលដែលអាចធ្វើឡើងជាមួយភាគីវិវាទដោយឡែកពីគ្នា គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវអញ្ជើញភាគីដែលមានផលប្រយោជន៍ទាំងអស់ឱ្យចូលរួមរាល់កិច្ចប្រជុំ និងសវនាការទាក់ទងទៅនឹងវិវាទរបស់ពួកគេ ។ សេចក្តីអញ្ជើញ ត្រូវបញ្ជូនទៅអោយភាគី យ៉ាងហោច ១៥ ថ្ងៃនៃថ្ងៃធ្វើការមុនពេលបើកកិច្ចប្រជុំ ឬ សវនាការ ។

ប្រការ ៤៥ :-

ភាគី អាចជ្រើសរើសបុគ្គលម្នាក់តាមជំរើសរបស់ខ្លួនផ្ទាល់ អោយតំណាងខ្លួននៅក្នុងរាល់ដំណើរការ នៃរឿងវិវាទរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ។ បុគ្គលនេះហៅថាអ្នកការពារក្តី អាចផ្តល់ការណែនាំ ឬអាចតំណាងភាគីបាន។ អ្នកការពារក្តីអាចបញ្ជាក់ពីចម្លើយរបស់ភាគី និងអាចចូលរួមកិច្ចប្រជុំជាមួយគណៈកម្មការសុរិយោដីថ្នាក់ជាតិហើយតាមការយល់ព្រមរបស់ភាគីអាចនិយាយ និងអាចធ្វើសេចក្តីសំរេចក្នុងនាមភាគីបាន ។ ទោះបីជាយ៉ាងណាក្តីបើគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាក់លាក់របស់ភាគីទេនោះ អ្នកការពារក្តីមិនអាចដោះស្រាយវិវាទក្នុងនាមភាគីបានឡើយ ។

ប្រសិនបើ អ្នកការពារក្តីបំពានវិធាននៃដំណើរការរឿងវិវាទ គណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវផ្តល់ការក្រើនរំលឹក និងការព្រមានជាឯកជនម្តងដល់អ្នកការពារក្តី ។ ប្រសិនបើ អ្នកការពារក្តីនៅតែបន្តបំពានទៀតគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវហាមឃាត់អ្នកការពារក្តីនោះមិនឱ្យចូលរួមក្នុងដំណើរដោះស្រាយវិវាទទៀតឡើយ ។ ប្រសិនបើអ្នកការពារក្តីត្រូវបានហាមឃាត់មិនឱ្យចូលរួម ដំណើរការរឿងវិវាទនោះត្រូវផ្អាក រហូតដល់ភាគីជ្រើសរើសអ្នកការពារក្តីថ្មីបានឬយល់ព្រមឱ្យបន្តដំណើរការដោយមិនមានអ្នកការពារក្តី។ គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវផ្តល់ឱកាសគ្រប់គ្រាន់ដល់ភាគីដើម្បីពិគ្រោះយោបល់ជាមួយអ្នកការពារក្តីដែលត្រូវបានហាមឃាត់អោយនៅក្រៅកន្លែងដោះស្រាយ ។

ប្រការ ៤៦ :-

គណៈកម្មការសុរិយោដីថ្នាក់ជាតិ អាចធ្វើសវនាការវិវាទជាក្រុមវិនិច្ឆ័យ ឬ អាចតែងតាំងសមាជិកតែម្នាក់ ឬមន្ត្រីសវនា ការតែមួយរូបឱ្យធ្វើសវនាការបាន ។

រាល់សវនាការ សក្ខីកម្មផ្ទាល់មាត់ ឬ ជាលាយលក្ខណ៍អក្សរអាចទទួលយកបាន ។

គណៈកម្មការសុរិយោដីថ្នាក់ ជាតិ មិនត្រូវបានតម្រូវអោយគោរពតាមវិធានភស្តុតាង ឬនីតិវិធីផ្លូវការទេ ប៉ុន្តែត្រូវធានាឱ្យភាគីទាំងអស់មានឱកាសបង្ហាញសក្ខីកម្ម និង ភស្តុតាងរបស់ខ្លួនដោយយុត្តិធម៌ និង សមធម៌ ។

ភាគីនីមួយៗមានសិទ្ធិបង្ហាញសាក្សី និងបដិសេធភស្តុតាង ឬសាក្សីដែលផ្តល់ដោយភាគីផ្សេងទៀត ។ បុគ្គលដែលផ្តល់សក្ខីកម្មអាចត្រូវបានតម្រូវអោយឆ្លើយនឹងសំនួរបញ្ជាក់អំពីសក្ខីកម្មនោះ ។

ប្រការ ៤៧ :-

គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវស្តាប់ភស្តុតាងវិវាទ និង ត្រួតពិនិត្យឯកសារផ្លូវការនៃវិវាទដែលបានប្រមូលនៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ឬ គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ឬ ដោយគណៈកម្មការរដ្ឋបាល ហើយត្រូវចេញសេចក្តីសំរេចដែលមានប្រសិទ្ធភាពអនុវត្តដោយផ្អែកលើរបាយការណ៍នេះ ។

គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវចេញសេចក្តីសំរេចនៅពេលធ្វើការសរុបសន្និដ្ឋានការពិភាក្សារបស់ខ្លួនហើយ ត្រូវធ្វើកំណត់សំគាល់សេចក្តីសន្និដ្ឋានខាងផ្លូវច្បាប់ និង មូលដ្ឋានអង្គហេតុនៃសេចក្តីសំរេចរបស់ខ្លួន ។ សេចក្តីសំរេចស្ថាពរត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និង ចុះហត្ថលេខាដោយប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

សេចក្តីសំរេចជាលាយលក្ខណ៍អក្សររបស់ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវផ្ញើអោយភាគីទាំងឡាយតាមរយៈសំបុត្រប្រៃសណីយ៍ និងត្រូវបើកចំហសំរាប់ការពិនិត្យមើលជាសាធារណៈដល់បុគ្គលណាក៏ដោយទោះបីមាន ឬគ្មានផលប្រយោជន៍នៅក្នុងរឿងវិវាទនោះក្តី ។

សេចក្តីសំរេចជាលាយលក្ខណ៍អក្សរ ត្រូវអមជាមួយសេចក្តីជូនដំណឹងដែលជំរាបភាគីវិវាទអំពីសិទ្ធិរបស់ពួកគេក្នុងការប្តឹងតវ៉ាទៅតុលាការឱ្យពិនិត្យមើលឡើងវិញផ្នែកច្បាប់ ចំពោះសេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ហើយត្រូវផ្តល់ពត៌មានអំពីរបៀបប្តឹងទៅតុលាការផង ។

ប្រការ ៤៨ :-

សេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិក្លាយជាសេចក្តីសំរេចស្ថាពរនៅក្រោយ រយៈពេល ៣០ ថ្ងៃ បន្ទាប់ពីសេចក្តីសំរេចនោះត្រូវបានបញ្ជូនទៅដល់ភាគីវិវាទទាំងអស់ លើកលែងតែករណីមានការប្តឹងទៅតុលាការ ឬមានការស្នើសុំ ឱ្យធ្វើការពិនិត្យឡើងវិញដោយគណៈកម្មការសុរិយោដីថ្នាក់ជាតិ អនុលោមតាមប្រការ ៤៩ នៃប្រកាសនេះ។

ប្រសិនបើគ្មានការប្តឹងតវ៉ាទៅតុលាការ ឬ គ្មានការស្នើសុំអោយធ្វើសវនាការឡើងវិញត្រូវបានធ្វើឡើងតាមពេលវេលាត្រឹមត្រូវទេលេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវបញ្ជូនសេចក្តីសំរេចនោះទៅការិយាល័យរៀបចំដែនដីនគរូបនីយកម្ម សំណង់ និង ភូមិបាលស្រុក ខណ្ឌ។ បន្ទាប់មក ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និង ភូមិបាលស្រុក ខណ្ឌ ត្រូវចាប់ផ្តើមអនុវត្តនីតិវិធីចុះបញ្ជីក្បាលដីដែលត្រូវបានសំរេចនោះ។

ប្រការ ៤៩ :-

ការធ្វើសវនាការឡើងវិញពុំអាចធ្វើបានទេ លើកលែងតែមានសម្លេងយល់ព្រមពីសមាជិក ៣ រូប នៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ នៅពេលដែលមានភស្តុតាងថ្មីធំដុំត្រូវបានដាក់ជូនគណៈកម្មការ ។

សំណើសុំធ្វើសវនាការឡើងវិញ ត្រូវដាក់ជូនជាលាយលក្ខណ៍អក្សរក្នុងរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីសេចក្តីសំរេចជាលាយលក្ខណ៍អក្សរត្រូវបានបញ្ជូនទៅដល់ភាគី ហើយត្រូវបញ្ជាក់មូលហេតុនៃការស្នើសុំនោះដោយត្រូវអមដោយពត៌-មាននិងគំនូសតាងចាំបាច់នានា ។

ការធ្វើសវនាការឡើងវិញ ត្រូវអនុលោមតាមសេចក្តីជូនដំណឹង និង លក្ខខណ្ឌតម្រូវផ្នែកនីតិវិធីដូចសវនាការដើមដែរ ។

ប្រសិនបើមានការបដិសេធចំពោះសំណើសុំអោយមានសវនាការឡើងវិញ គណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការបដិសេធនោះដល់ភាគីវិវាទ ។ នៅក្នុងករណីនេះសេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ក្លាយជាស្ថាពរក្រោយបញ្ចប់រយៈពេល៣០ថ្ងៃ បន្ទាប់ពីសេចក្តីជូនដំណឹងពីការបដិសេធត្រូវបានបញ្ជូនទៅដល់ភាគីវិវាទលើកលែងតែភាគីម្ខាងនៃគូវិវាទជូនដំណឹងអំពីការប្តឹងជំទាស់ទៅតុលាការតាមពេលវេលាត្រឹមត្រូវ ។

ប្រការ ៥០ :-

ភាគីណាក៏ដោយអាចប្តឹងទៅតុលាការដោយរួមគ្នា ឬជាបុគ្គលអំពីសេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ។ បណ្តឹងជំទាស់ត្រូវដាក់ជូនទៅតុលាការក្នុងរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីសេចក្តីសំរេចជាលាយលក្ខណ៍អក្សររបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវបានបញ្ជូនដល់ភាគីវិវាទ ។

ភាគីណាមួយដែលធ្វើបណ្តឹងទៅតុលាការ ត្រូវដាក់តម្កល់ឯកសារថតចម្លងមួយច្បាប់នៃបណ្តឹងជំទាស់នៅលេខាធិការដ្ឋាន នៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

លេខាធិការដ្ឋាន ត្រូវធ្វើសេចក្តីបញ្ជាក់ជាបន្ទាន់នូវរបាយការណ៍ផ្លូវការដើម្បីបញ្ជូនទៅតុលាការ ។

៨. បទប្បញ្ញត្តិរដ្ឋបាល

ប្រការ ៥១ :-

ប្រធានគណៈកម្មការសុរិយោដីគ្រប់ថ្នាក់ ត្រូវធ្វើរបាយការណ៍ប្រចាំខែ ស្តីពីបណ្តឹងដែលបានទទួល និង ចំណាត់ការដែលបានធ្វើដោយគណៈកម្មការចំពោះបណ្តឹងនីមួយៗ ដែលគណៈកម្មការបានធ្វើ ។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវធ្វើរបាយការណ៍ប្រចាំខែទៅ គណៈកម្មការសុរិយោដីថ្នាក់ខេត្តក្រុង ។

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវធ្វើរបាយការណ៍ប្រចាំខែទៅ គណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវធ្វើរបាយការណ៍ប្រចាំខែទៅ រាជរដ្ឋាភិបាល ។

របាយការណ៍របស់គណៈកម្មការសុរិយោដី ត្រូវបើកចំហ និង អនុញ្ញាតឱ្យសាធារណជនមើលដោយសេរីក្នុងពេលម៉ោងធ្វើការធម្មតា ។

ប្រការ ៥២ :-

គណៈកម្មការសុរិយោដីគ្រប់ថ្នាក់ ត្រូវរក្សាទុកកំណត់ហេតុផ្លូវការនៃវិវាទនីមួយៗដែលបានប្តឹងនៅគណៈកម្មការនោះ ។

កំណត់ហេតុផ្លូវការ ត្រូវរួមបញ្ចូលរាល់ឯកសារទាំងអស់ សេចក្តីអះអាងភស្តុតាងផ្សេងៗ និងរបាយការណ៍ផ្សេងៗ ទាក់ទងទៅនឹងវិវាទ ។

ឯកសារផ្លូវការត្រូវបើកចំហជាសាធារណៈ និង អនុញ្ញាតឱ្យសាធារណជនចូលមើលដោយសេរីក្នុងពេលម៉ោងធ្វើការធម្មតា។

បុគ្គលទាំងឡាយដែលចង់ពិនិត្យមើលឯកសារ ត្រូវទៅមើលនៅការិយាល័យគណៈកម្មការសុរិយោដីនោះ និងត្រូវចុះហត្ថលេខាលើសៀវភៅភ្ញៀវ ។

នៅកន្លែងដែលមានសម្ភារៈបរិក្ខារថតចម្លង បុគ្គលទាំងឡាយអាចថតចម្លងឯកសារបាន ។

ប្រការ ៥៣ :-

នាយកខុទ្ទកាល័យ ប្រធានគណៈកម្មការសុរិយោដីគ្រប់ថ្នាក់ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង និង ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និង ភូមិបាលស្រុក ខណ្ឌ ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០២

រដ្ឋមន្ត្រី

អ៊ឹម ឈុនលឹម

កន្លែងទទួល :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់សាលាខេត្ត ក្រុង
- ដូចប្រការ ៥៣
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ ១/Annex 1: គំរូទម្រង់បែបបទនៃពាក្យបណ្ដឹង/Sample Complaint Form

កំណត់សំគាល់ /Note: ដើមបណ្ដឹងអាចប្រើប្រាស់ទម្រង់បែបបទផ្សេងៗទៀតបាន ប៉ុន្តែត្រូវដាក់បញ្ចូលពត៌មានខាងក្រោមនេះ/Claimants may use other form but must include the information below:

ពត៌មានអំពីដើមបណ្ដឹង Claimant Information			
ឈ្មោះ/Name:	អាយុ/Age:	សញ្ជាតិ/Nationality:	មុខរបរ/Occupation:
ប្ដី ឬ ប្រពន្ធ /Spouse:		កូន/Children:	
ខេត្ត ក្រុង/Province:	ស្រុក ខណ្ឌ/District:		ឃុំ សង្កាត់/Commune:
អាស័យដ្ឋានបច្ចុប្បន្ន/Current Address:			
អាស័យដ្ឋាននៃដីដែលមានវិវាទ/Disputed Property Address:			

ចុងបណ្ដឹងដែលបានកំណត់ឈ្មោះ/Named Respondents	
ឈ្មោះ/Name:	ពត៌មានសំរាប់ទំនាក់ទំនង/Contact Information (អាស័យដ្ឋាន/Address, លេខទូរស័ព្ទ/Telephone...)

សេចក្ដីអធិប្បាយទូទៅអំពីវិវាទ/General Description of Dispute (ដើមបណ្ដឹង/Claimant)

ឯកសារសំណុំសំអាង/Supporting Documents (ដើមបណ្ដឹង/Claimant) (ថតចម្លងដើម្បីដាក់បញ្ចូលទៅក្នុងសំណុំរឿងវិវាទ/Copies to be included in case file)	
១.	៤.
២.	៥.
៣.	៦.

សាក្សីរបស់ដើមបណ្ដឹង/Supporting Witnesses (Claimant) (ចម្លើយទាំងឡាយត្រូវបញ្ចូលទៅក្នុងសំណុំរឿងវិវាទ/Statements to be included in case file)	
ឈ្មោះ/Name:	ពត៌មានសំរាប់ទំនាក់ទំនង/Contact Information (អាស័យដ្ឋាន/Address, លេខទូរស័ព្ទ/Telephone...)

ស្នាមម្រាមដៃរបស់ដើមបណ្ដឹង /Claimant's Fingerprints:

ហត្ថលេខារបស់ដើមបណ្ដឹង/Claimant's Signature:

____

ត្រាផ្លូវការ/Offical Seal

ទទួលដោយ/Received by: ________________________

ករណីវិវាទលេខ/Case No.: ________________________

កាលបរិច្ឆេទ/Date: ______ / ______ / ______

ឧបសម្ព័ន្ធ ២/Annex 2: គំរូនៃសេចក្តីជូនដំណឹងអំពីការប្តឹងតវ៉ា/Sample Notice of Complaint Form

(ត្រូវបិទប្រកាសនៅទីសាធារណៈ/To be posted in public areas)

ពត៌មានអំពីដើមបណ្តឹង/Claimant Information		
ឈ្មោះរបស់ដើមបណ្តឹង/Name of Claimant:		ករណីវិវាទលេខ/Case No.:
ខេត្ត ក្រុង/Province:	ស្រុក ខណ្ឌ/District:	ឃុំ សង្កាត់/Commune:
អាស័យដ្ឋានបច្ចុប្បន្ន/Current Address:		
អាស័យដ្ឋាននៃដីដែលមានវិវាទ/Disputed Property Address:		
កាលបរិច្ឆេទនៃការដាក់ពាក្យបណ្តឹង/Date of Submission of Complaint: / /		កាលបរិច្ឆេទនៃការបិទសេចក្តីជូនដំណឹងជាសាធារណៈ/Date of Posting of Public Notice: / /

ចុងចោទដែលបានកំណត់ឈ្មោះ/Named Respondents	
ឈ្មោះ/Name:	ពត៌មានសំរាប់ទំនាក់ទំនង/Contact Information (អាស័យដ្ឋាន/Address, លេខទូរស័ព្ទ/Telephone...)

សេចក្តីអធិប្បាយទូទៅអំពីវិវាទ/General Description of Dispute

ភាគីដែលមានបំណងចង់ចូលរួមក្នុងវិវាទ ឬភាគីដែលបានកំណត់ឈ្មោះអាចដាក់ពាក្យឆ្លើយតបទៅនឹងបណ្តឹងបាន ។ សំរាប់ពត៌មានចាំបាច់ សូមមើលទំរង់ បែបបទដែលបានបិទប្រកាស។ សំរាប់ពត៌មានបន្ថែម សូមធ្វើការទាក់ទងជាមួយការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និង ភូមិបាល ស្រុក ខណ្ឌ។ / Parties wishing to join dispute or named parties may submit a response to the complaint. Please refer to the posted forms for the necessary information. Contact the District Land Management Office for further information.

ត្រាផ្លូវការ/Official Seal

ANNEX 3: SUMMARY OF THE CONCILIATION PROCESS

The new Land Law of 2001 protects the rights of citizens to own land. The Law provides for people to register their land with the Ministry of Land Management, Urban Planning and Construction.

Sometimes there are disputes about who owns the land. The Land Law creates a special commission, called the Cadastral Commission, to resolve these disputes. The Cadastral Commission is established at 3 levels: (1) at the district/khan level, called the DKCC; (2) at the provincial/ municipality level, called the PMCC; and (3) at the national level, called the NCC.

WHAT TO DO IF YOU HAVE A LAND DISPUTE

FILING A COMPLAINT

If you have a dispute with other people about the ownership of land, you may file a complaint at the DKCC. You must submit a Complaint Form. You may get a copy of the Complaint Form from the DKCC or you may supply your own form as long as it contains all the necessary information.

You must provide 4 copies of the completed complaint to the DKCC. The DKCC will assign a number to your complaint, sign and stamp your complaint, and give you one copy of the completed complaint. This copy shows that you filed a complaint. Keep your copy in a safe place.

NOTIFICATION OF OTHER PARTIES

You must provide information about the other people involved in the dispute. The DKCC will notify the other people of your complaint and give them an opportunity to provide information about the dispute. The DKCC will put up a notice on the land that is under dispute and a notice in a public place near the District/Khan Office of LMUPC so that all persons who may have interest in the land can know about the dispute.

PROVIDING COPIES OF YOUR DOCUMENTS

If you have any documents that show your rights to the land, you must provide these documents to the DKCC. The DKCC will make copies of the documents. but the DKCC must return the original documents to you. Be sure to keep all your original documents in a safe place.

INVESTIGATION OF LAND DISPUTES

An official from the District/Khan Cadastral Administration will conduct an investigation. He will talk to you and all the parties and other people who may know about the land. He will collect copies of any papers or other evidence that might help to show who owns the land. All parties and witnesses must meet with the investigator. If the investigator requests a meeting you will be required to meet him and give him all the information you have about the land. If you fail to appear for the meeting with the investigator, you may have to pay the costs of having another investigation.

ACTION BY THE DKCC

After the investigation is complete, the DKCC must decide how to conciliate the dispute. Usually, the DKCC will help the parties to conciliate their disputes. In the following cases, the DKCC must refer the dispute to the PMCC:

1. One of the parties is a high ranking authority;
2. There is a conflict of interest on the part of the head of the DKCC;
3. One of the parties claims many parcels occupied by more than one other person; or
4. The land under dispute is state public land.

SELECTING CONCILIATORS

The parties and the Chief of the DKCC will meet and select 3 conciliators. If the parties cannot agree on who the conciliators should be, the head of the DKCC will select them. The parties and the 3 conciliators will develop a schedule for the conciliation of the dispute.

CONCILIATION

The conciliators from the DKCC will meet with you and the other involved parties together and individually to discuss the dispute and hear each person's reasons for believing they own the land. You may also bring another person to help you during conciliation. This person is called a party assistant, cannot speak for you. The party assistant may only advise you.

The conciliators will NOT decide who is right in the dispute. Instead, the conciliators will try to help you and the other involved parties reach an agreement about who owns or has rights to the land. IN CONCILIATION, ONLY THE PARTIES HAVE THE RIGHT TO MAKE A DECISION OR AN AGREEMENT, AND THE CONCILIATORS CANNOT FORCE THE PARTIES TO MAKE AN AGREEMENT. Everything you and the other parties say in conciliation must be kept private and confidential and will NOT be part of the official record of the dispute.

MAKING AN AGREEMENT DURING DKCC CONCILIATION

If you make an agreement during conciliation, the conciliators will write the agreement down and you will sign or thumbprint the agreement. Then, the agreement will be sent to the District/Khan Office of LMUPC Administration, which will take appropriate actions based on the agreement. The office can only take action to implement the parties' agreement. The office cannot change or set aside the agreement.

IF YOU ARE NOT ABLE TO REACH AN AGREEMENT

If you and the other parties do not come to an agreement during the DKCC conciliation, your dispute will be sent to the PMCC for conciliation. If you and the other parties do not reach an agreement during PMCC conciliation, the dispute will be sent to the NCC. The NCC will either hold another conciliation or simply make a decision about who owns the land based on the information gathered during the investigation and a public hearing of the parties.

FOR FURTHER INFORMATION

If you would like more information about the Land Law or the conciliation process, ask the DKCC in your district or your District Land Management Office to see the guidelines.

ឧបសម្ព័ន្ធទី ៣ : ការសង្ខេបអំពីដំណើរការសម្រុះសម្រួល

ច្បាប់ភូមិបាលថ្មីឆ្នាំ ២០០១ ការពារសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការធ្វើជាម្ចាស់លើដីធ្លី។ ច្បាប់ភូមិបាលចែងតំរូវឱ្យប្រជាពលរដ្ឋធ្វើការចុះបញ្ជីដីធ្លីរបស់ខ្លួននៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

នៅពេលខ្លះ វិវាទកើតឡើងលើបញ្ហាថាតើអ្នកណាជាម្ចាស់លើដីធ្លី ។ ច្បាប់ភូមិបាលថ្មីបានបង្កើតគណៈកម្មការពិសេសមួយ ហៅថា គណៈកម្មការសុរិយោដី ដើម្បីដោះស្រាយវិវាទដីធ្លីទាំងនេះ ។ គណៈកម្មការសុរិយោដីមាន ៣ ថ្នាក់ : (១) នៅថ្នាក់ស្រុក ខណ្ឌ ហៅថាគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ DKCC (២) នៅថ្នាក់ខេត្ត ក្រុង ហៅថាគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង PMCC និង (៣) នៅថ្នាក់ជាតិហៅថាគណៈកម្មការសុរិយោដីថ្នាក់ជាតិ NCC ។

តើអ្នកត្រូវធ្វើអ្វីខ្លះនៅពេលដែលអ្នកមានវិវាទដីធ្លី

ការដាក់ពាក្យបណ្តឹង :

ប្រសិនបើអ្នកមានវិវាទកម្មសិទ្ធិដីធ្លីជាមួយអ្នកដទៃ អ្នកអាចប្តឹងតវ៉ាទៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ។ អ្នកត្រូវតែដាក់ពាក្យបណ្តឹងក្នុងទម្រង់បែបបទមួយ ។ អ្នកអាចទទួលបានបែបបទនៃពាក្យបណ្តឹងពីគណៈកម្មការសុរិយោដី ថ្នាក់ស្រុក ខណ្ឌ ឬ អ្នកអាចដាក់សំណុំបែបបទនៃពាក្យបណ្តឹងដែលអ្នកបានធ្វើដោយខ្លួនឯងក៏បាន ប៉ុន្តែអ្នកត្រូវតែបញ្ចូលនូវរាល់ពត៌មានដែលចាំបាច់ទាំងអស់ ។

អ្នកត្រូវតែដាក់ពាក្យបណ្តឹងដែលបានបំពេញរួចចំនួន ៤ ច្បាប់ ជូនគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ។ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ នឹងចុះលេខលិបណ្តឹងតវ៉ា ចុះហត្ថលេខា និងបោះត្រាលើពាក្យបណ្តឹងរបស់អ្នក ហើយផ្តល់ពាក្យបណ្តឹងដែលបានបំពេញរួចរបស់អ្នកនោះជូនអ្នកវិញ ។ ពាក្យបណ្តឹងមួយច្បាប់ដែលផ្តល់ជូនអ្នកវិញនេះ ជាភស្តុតាងមួយដែលបញ្ជាក់ថាអ្នកបានដាក់ពាក្យបណ្តឹង ។ អ្នកត្រូវទុកពាក្យបណ្តឹងមួយច្បាប់ដែលគណៈកម្មការសុរិយោដីប្រគល់ជូនអ្នកនេះនៅកន្លែងមួយដែលមានសុវត្ថិភាព ។

សេចក្តីជូនដំណឹងរបស់ភាគីផ្សេងៗ :

អ្នកត្រូវតែផ្តល់ពត៌មានអំពីអ្នកផ្សេងទៀតដែលពាក់ព័ន្ធក្នុងវិវាទ ។ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ នឹងផ្តល់ពត៌មានដល់អ្នកផ្សេងៗដែលមានឈ្មោះនៅក្នុងពាក្យបណ្តឹងរបស់អ្នក និងផ្តល់ឱកាសដល់អ្នកទាំងនោះឱ្យផ្តល់ពត៌មានអំពីវិវាទនេះ ។ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ នឹងបិទសេចក្តីជូនដំណឹងមួយច្បាប់នៅលើដីដែលកំពុងមានវិវាទនោះ និងបិទសេចក្តីជូនដំណឹងនោះនៅទីសាធារណៈដែលស្ថិតនៅជិតការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ស្រុក ខណ្ឌ នោះ អាស្រ័យហេតុនេះ អ្នកដែលអាចមានផលប្រយោជន៍នៅក្នុងដីវិវាទអាចដឹងអំពីវិវាទនោះ ។

ការផ្តល់ច្បាប់ចម្លងនៃឯកសារនានារបស់អ្នក :

ប្រសិនបើអ្នកមានឯកសារមួយចំនួនដែលបង្ហាញអំពីសិទ្ធិរបស់អ្នកលើដីវិវាទនោះ ។ អ្នកត្រូវតែផ្តល់ឯកសារទាំងនេះជូនគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ។ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ នឹងថតចម្លងឯកទាំងនេះ ប៉ុន្តែគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវតែប្រគល់ឯកសារច្បាប់ដើមរបស់អ្នកមកឱ្យអ្នកវិញ ។ ដើម្បីជាការទុកចិត្ត អ្នកត្រូវរក្សាទុកឯកសារច្បាប់ដើមរបស់អ្នកទាំងអស់នៅកន្លែងដែលមានសុវត្ថិភាព ។

ការស៊ើបអង្កេតលើវិវាទដីធ្លី

មន្ត្រីមកពីរដ្ឋបាលសុរិយោដីថ្នាក់ស្រុក ខណ្ឌ ម្នាក់នឹងធ្វើការស៊ើបអង្កេតលើវិវាទដីធ្លី ។ មន្ត្រីនោះនឹងពិភាក្សាជាមួយអ្នក និងជាមួយភាគីទាំងអស់ ព្រមទាំងជាមួយអ្នកដទៃៗទៀត ដែលអាចដឹងអំពីរឿងហេតុដែលពាក់ព័ន្ធទៅនឹងដីវិវាទនោះ ។ មន្ត្រីមកពីការិយាល័យរដ្ឋបាលសុរិយោដីថ្នាក់ស្រុក ខណ្ឌ នោះ នឹងប្រមូលនូវរាល់ឯកសារ និងភស្តុតាងផ្សេងៗដែលអាចជួយបង្ហាញឱ្យដឹងអំពីអ្នកដែលជាម្ចាស់ពិតប្រាកដនៃដីវិវាទនោះ ។ ភាគីវិវាទ និងសាក្សី ទាំងអស់ ត្រូវតែជួបពិភាក្សាជាមួយអ្នកស៊ើបអង្កេត ។ ប្រសិនបើអ្នកស៊ើបអង្កេតស្នើឱ្យមានកិច្ចប្រជុំមួយ អ្នកនឹងត្រូវបានតម្រូវឱ្យជួបជាមួយអ្នកស៊ើបអង្កេតនោះ ហើយផ្តល់នូវរាល់ពត៌មានដែលអ្នកបានដឹងអំពីដីនោះ ។ ប្រសិនបើអ្នកខកខានមិនចូលរួមក្នុងកិច្ចប្រជុំជាមួយអ្នកស៊ើបអង្កេត អ្នកអាចនឹងត្រូវបង់ថ្លៃសេវាសំរាប់ការស៊ើបអង្កេតមួយផ្សេងទៀត ។

ការងាររបស់គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ

ក្រោយពីការស៊ើបអង្កេតត្រូវបានបញ្ចប់ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវតែសំរេចអំពីវិធីសាស្ត្រដើម្បីធ្វើការសម្រុះសម្រួលវិវាទនោះ ។ ជាទូទៅ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ នឹងជួយភាគីវិវាទឱ្យធ្វើការសម្រុះសម្រួលវិវាទរបស់ខ្លួន ។ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវតែបញ្ជូនវិវាទទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ដូចក្នុងករណីនានាដូចតទៅនេះ :

១- ភាគីម្ខាងជាអាជ្ញាធរដែលមានឋានៈខ្ពស់

២- មានទំនាស់ផលប្រយោជន៍របស់ប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ

៣- ភាគីមួយក្នុងចំណោមភាគីនានា ទាមទារក្បាលដីច្រើនដែលកាន់កាប់ដោយមនុស្សច្រើននាក់ផ្សេងទៀត

៤- ដីដែលកំពុងមានវិវាទគឺជាដីសាធារណៈរបស់រដ្ឋ

ការជ្រើសរើសអ្នកសម្រុះសម្រួល

ភាគីវិវាទនានានឹងជួបជាមួយប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ហើយធ្វើការជ្រើសរើសយកអ្នកសម្រុះសម្រួល ចំនួន ៣ រូប ។ ប្រសិនបើភាគីវិវាទមិនយល់ស្របលើបញ្ហាថាតើអ្នកណាគួរត្រូវបានជ្រើសរើសឱ្យធ្វើជា

អ្នកសម្រុះសម្រួល ប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ គឺជាអ្នកជ្រើសរើសអ្នកសម្រុះសម្រួល ។ ភាគីវិវាទ និងអ្នកសម្រុះសម្រួល ៣ រូប ដែលបានជ្រើសរើសនោះ នឹងរៀបចំកម្មវិធីសំរាប់ការសម្រុះសម្រួលវិវាទ ។

ការសម្រុះសម្រួល

អ្នកសម្រុះសម្រួលមកពីគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ នឹងជួបរួមគ្នានិងដាច់ដោយឡែក ជាមួយអ្នក ហើយភាគីពាក់ព័ន្ធផ្សេងៗទៀត ដើម្បីពិភាក្សាអំពីវិវាទ និងស្តាប់នូវហេតុផលរបស់គេដើម្បីឱ្យជឿជាក់ថា អ្នកទាំងនោះគឺជាម្ចាស់នៃដីនោះ ។ អ្នកអាចរកមនុស្សម្នាក់ផ្សេងទៀតដើម្បីជួយអ្នកក្នុងអំឡុងពេលនៃការសម្រុះសម្រួល។ មនុស្សម្នាក់ផ្សេងទៀតនេះ ហៅថាអ្នកជំនួយការភាគី គេមិនអាចនិយាយជំនួសអ្នកបានទេ ។ អ្នកជំនួយការភាគីអាចមានសិទ្ធិគ្រាន់តែផ្តល់យោបល់ឱ្យអ្នកតែប៉ុណ្ណោះ ។

អ្នកសម្រុះសម្រួលនឹងមិនអាចសំរេចថាអ្នកណាម្នាក់ជាអ្នកត្រូវ នៅក្នុងវិវាទនេះឡើយ។ ផ្ទុយទៅវិញ អ្នកសម្រុះសម្រួល ត្រូវព្យាយាមជួយអ្នក និងភាគីពាក់ព័ន្ធផ្សេងៗទៀតឱ្យឈានដល់កិច្ចព្រមព្រៀងអំពីថាតើអ្នកណាជាម្ចាស់នៃដីពិតប្រាកដ ឬ អ្នកណាជាអ្នកមានសិទ្ធិចំពោះដីនោះ។ នៅក្នុងការសម្រុះសម្រួលមានតែភាគីវិវាទប៉ុណ្ណោះដែលមានសិទ្ធិធ្វើការសំរេច ឬបង្កើតកិច្ចព្រមព្រៀង ហើយអ្នកសម្រុះសម្រួលមិនអាចបង្ខំភាគីវិវាទឱ្យបង្កើតកិច្ចព្រមព្រៀងបានទេ ។ អ្វីៗដែលអ្នក និងភាគីផ្សេងៗទៀតនិយាយនៅក្នុងការសម្រុះសម្រួល ត្រូវទុកជារឿងផ្ទាល់ខ្លួន និងជារឿង សំងាត់ ហើយនឹងមិនមែនជាផ្នែកមួយនៃរបាយការណ៍ផ្លូវការនៃវិវាទឡើយ ។

ការបង្កើតកិច្ចព្រមព្រៀងក្នុងអំឡុងពេលនៃការសម្រុះសម្រួលនៅ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ

ប្រសិនបើអ្នកបង្កើតកិច្ចព្រមព្រៀងក្នុងអំឡុងពេលនៃការសម្រុះសម្រួល អ្នកសម្រុះសម្រួលនឹងសរសេរកិច្ចព្រមព្រៀងនោះ អ្នកនឹងចុះហត្ថលេខា ឬ ផ្តិតមេដៃលើកិច្ចព្រមព្រៀងនោះ ។ បន្ទាប់មក កិច្ចព្រមព្រៀងនោះនឹងត្រូវផ្ញើទៅការិយាល័យរៀបចំ ដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ឱ្យចាត់វិធានការសមស្របផ្អែកលើកិច្ចព្រមព្រៀងនោះ ។ ការិយាល័យរៀបចំ ដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល អាចមានសិទ្ធិចាត់វិធានការអនុវត្តកិច្ចព្រមព្រៀងរបស់ភាគីតែម្យ៉ាងប៉ុណ្ណោះ។ ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល មិនអាចកែប្រែ ឬ ទុកកិច្ចព្រមព្រៀងរបស់ភាគីចោលឡើយ ។

ប្រសិនបើអ្នកមិនមានលទ្ធភាពសំរេចកិច្ចព្រមព្រៀង

ប្រសិនបើអ្នក និង ភាគីផ្សេងៗទៀតមិនអាចឈានទៅដល់កិច្ចព្រមព្រៀងក្នុងអំឡុងពេលនៃការសម្រុះសម្រួលនៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ វិវាទរបស់អ្នកនឹងត្រូវបញ្ជូនទៅធ្វើការសម្រុះសម្រួលនៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ។ ប្រសិនបើអ្នក និង ភាគីផ្សេងៗទៀតមិនអាចឈានទៅដល់កិច្ចព្រមព្រៀងក្នុងអំឡុងពេលនៃការសម្រុះសម្រួល

នៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង វិវាទរបស់អ្នកនឹងត្រូវបញ្ជូនទៅធ្វើការសម្រុះសម្រួលនៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។ គណៈកម្មការសុរិយោដី ថ្នាក់ជាតិ នឹងធ្វើការសម្រុះសម្រួលមួយផ្សេងទៀត ឬ ប្រហែលជាធ្វើការសំរេចថាអ្នកណាជាម្ចាស់នៃដីវិវាទនោះ ដោយផ្អែកលើពត៌មានដែលប្រមូលបានក្នុងអំឡុងពេលនៃការស៊ើបអង្កេត និងអំឡុងពេលនៃការធ្វើសវនាការជាសាធារណៈរបស់ភាគីវិវាទ ។

សំរាប់ពត៌មានបន្ថែម

ប្រសិនបើអ្នកចង់ដឹងពត៌មានច្រើនទាក់ទងទៅនឹងច្បាប់ភូមិបាល ឬ ដំណើរការនៃការសម្រុះសម្រួល អ្នកអាចសួរកនៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ នៅក្នុងស្រុក ខណ្ឌ របស់អ្នក ឬ នៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និង ភូមិបាលស្រុក ខណ្ឌ នៅក្នុងស្រុក ខណ្ឌ របស់អ្នក ដើម្បីពិនិត្យមើល ច្បាប់ភូមិបាលថ្មីឆ្នាំ ២០០១ គោលការណ៍ណែនាំនានា អនុក្រឹត្យលេខ ៤៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី ប្រកាសលេខ ១១២ ដ.ន.ស/ប្រក ស្តីពីគោលការណ៍ណែនាំ និងនីតិវិធី របស់គណៈកម្មការសុរិយោដី ។

ឧបសម្ព័ន្ធទី ៤/Annex 4: គំរូឆ្លើយតបចំពោះបណ្តឹង/Sample Response to Complaint Form

កំណត់សំគាល់/Note: ចុងបណ្តឹងអាចប្រើប្រាស់ទំរង់បែបបទផ្សេងៗទៀតបាន ប៉ុន្តែត្រូវបញ្ចូលពត៌មានខាងក្រោមនេះ/Respondents may use other forms but must include the information below.

ពត៌មានអំពីចុងបណ្តឹង/Respondent Information			
ឈ្មោះ/Name:	អាយុ/Age:	សញ្ជាតិ/Nationality:	មុខរបរ/Occupation:
ប្តី ឬ ប្រពន្ធ/Spouse:	កូន/Childrend:		
ខេត្ត ក្រុង/Province:	ស្រុក ខណ្ឌ/District:	ឃុំ សង្កាត់/Commune:	
អាស័យដ្ឋានបច្ចុប្បន្ន/Current Address:			
អាស័យដ្ឋានដីដែលមានវិវាទ/dispute Property Address:			

ចុងបណ្តឹងដែលបានកំណត់ឈ្មោះផ្សេងៗទៀត/Other Named Respondents	
ឈ្មោះ/Name:	ពត៌មានសំរាប់ទំនាក់ទំនង/Contact Information (អាស័យដ្ឋាន/Address, លេខទូរស័ព្ទ/Telephone)

សេចក្តីអធិប្បាយទូទៅអំពីវិវាទ (ចុងបណ្តឹង)/General Description of Dispute (Respondent) (សូមភ្ជាប់ទំព័របន្ថែមប្រសិនបើមានពត៌មានចាំបាច់/Attach additional pages as necessary)

ឯកសារបញ្ជាក់ភស្តុតាង (ចុងបណ្តឹង)/Supporting Documents (Respondent) (ថតចម្លងដើម្បីបញ្ចូលទៅក្នុងសំណុំរឿងវិវាទ/Copies to be included in case file)	
១.	៤.
២.	៥.
៣.	៦.

សាក្សីរបស់ចុងបណ្តឹង/Supporting Witnesses (Respondent) (ចម្លើយទាំងឡាយត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿងវិវាទ/Statements to be included in case file)	
ឈ្មោះ/Name:	ពត៌មានសំរាប់ទំនាក់ទំនង/Contect Information (អាស័យដ្ឋាន/Address, លេខទូរស័ព្ទ/Telephone...)

ស្នាមម្រាមដៃរបស់ចុងបណ្តឹង /Respondent's Fingerprints:

ហត្ថលេខារបស់ចុងបណ្តឹង /Respondent's Signature:

____

ទទួលដោយ/Received by: ______________________

ការណីវិវាទលេខ/Case No.: ______________________

កាលបរិច្ឆេទ/Date: ______ / ______ / ______

ត្រាផ្លូវការ/Official Seal

ឧបសម្ព័ន្ធ ៥/Annex 5: គំរូបែបបទនៃការស៊ើបអង្កេត/Investigation Forms

សន្លឹកព័ត៌មានទូទៅ/General Information Sheet

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
Ministry of Land Management, Urban Planning and Construction

ព្រះរាជាណាចក្រកម្ពុជា
KINDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATIONAL RELIGION KING

អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ
General Department of Cadastre and Geography

ទម្រង់បែបបទនៃការស៊ើបអង្កេតវិវាទ
DISPUTE INVESTIGATION FORM

1-លេខសំគាល់ក្បាលដី/Unique parcel reference number (UPRN)[1]

ខេត្ត ក្រុង/Province	ស្រុក ខណ្ឌ/District	ឃុំ សង្កាត់ /Commune	ភូមិ /Village	លេខក្បាលដី/UPRN

២-ទីតាំងដី/ Site of the property:
អាស័យដ្ឋាន/Address:..
ខេត្ត ក្រុង/Province:.......................... ស្រុក ខណ្ឌ/District.............................. ឃុំ សង្កាត់/Commune..
ភូមិ/Village......................... សន្លឹកផែនទី/ Map sheet:.................. ឈ្មោះដី/Name of Land...

៣- ព័ត៌មានលំអិតនៃក្បាលដី/ Parcel data: ៣.១- ទំហំដី/Area:..............................

៣.២- របភាពប្រើប្រាស់ដី/Land use :

លំនៅដ្ឋាន/Residential ☐ ឧស្សាហកម្ម/Industrial ☐ កសិកម្ម/ Agriculture ☐
ដីដែលគ្មានប្រព័ន្ធធារាសាស្ត្រ/Rain-fed Riceland ☐ ដីដែលគ្មានប្រព័ន្ធធារាសាស្ត្រ/Irrigated Riceland ☐ ដីចំការ/Chamkar
ព្រៃសហគមន៍/communal Forest ☐ ព្រៃរបស់រដ្ឋ/ State Forest ☐ ដីសើម/Wetlands
ពាណិជ្ជកម្ម/Commercial ☐ សាសនា/Religious ☐ ផ្សេងៗ/ Other..........

៣.៣- លក្ខណៈនៃការប្រើប្រាស់ : ឯកជន/ Private ☐ កម្មសិទ្ធិរបស់រដ្ឋ/State-owned ☐

៤- ព័ត៌មានលំអិតអំពីសំណង់អចិន្ត្រៃយ៍/Characteristics of permanent buildings:
ចំនួនសំណង់រឹងមាំ Number of permanent buildings:....................

៤.១- ប្រភេទអាគារ/Building type:		៤.២- ដំបូល/Roof		៤.៣- សំភារៈ/Materials:	
ភូមិគ្រឹះ/Detaches	☐	រាប/ Fiat	☐	ឈើ/Wood	☐
ពាក់កណ្ដាលភូមិគ្រឹះ/Semi-Detaches	☐	ក្បឿង Tile	☐	ឈើ និងស្លឹក/Wood and palm leaf	☐
ផ្ទះល្វែង/Flat	☐	ហ្វ៊ីប្រូ/Fiber	☐	ឥដ្ឋ/ Brick	☐
ប្លុកនៃផ្ទះល្វែង/ Block of flats	☐	ស័ង្កសី/Couurgated iron	☐	បេតុង/Concrete	☐
ផ្ទះបន្ទប់លើសសរ/House on pilling	☐	ផ្សេងៗ/ Other.........	☐	ផ្សេងៗ/ Other........................	
ផ្សេងៗ/Other..					

៤.៤- ស្ថានភាពសំណង់/Condition: ថ្មី/New ☐ ចាស់/Old ☐ ចាស់ណាស់/Very old ☐ ផ្សេងៗ/Other.................................

៤.៥- ចំនួនជាន់/Number of floors-floors No:................៤.៦-ឈ្មោះនៃអាគារ (បើសិនជាមាន)/Name of the building:.....................

៥- សេវភាព/Easement:..

អ្នកស៊ើបអង្កេត/Investigator: ______________________

ករណីវិវាទលេខ/Case No.: ______________________

[1] លេខសំគាល់ក្បាលដី/UPRN: កំណត់ចំពោះក្បាលដី ដោយមិនគិតពីស្ថានភាពនៃវិវាទឡើយ/Assigned to all parcels of land, regardless of dispute status.

ឧបសម្ព័ន្ធ ៥/Annex 5: សំណុំបែបបទនៃការស៊ើបអង្កេត/Investigation Forms

សន្លឹកព័ត៌មានទូទៅ/General Information Sheet

៦-ការកំណត់ព្រំប្រទល់នេះទទួលស្គាល់ដោយអ្នកជាប់ព្រំ ដែលមានស្នាមមេដៃ និងលេខក្បាលដីដូចខាងក្រោម/ Boundary demarcations accepted by the adjoining owners with thumbprint and UPRN:

លេខក្បាលដី/UPRN ....លេខក្បាលដី/UPRN ....លេខក្បាលដី/UPR ....

លេខក្បាលដី/UPRN ....លេខក្បាលដី/ UPRN ....

ឈ្មោះ/Name..ឈ្មោះ/Name ....ឈ្មោះ/ Name ....

លេខក្បាលដី/UPRN ....លេខក្បាលដី/UPRN ....លេខក្បាលដី/UPR ....

ឈ្មោះ/ Name ....ឈ្មោះ/ Name ....

លេខក្បាលដី/UPRN ....លេខក្បាលដី/ UPRN ....

ឈ្មោះ/Name......................ឈ្មោះ/Name ....ឈ្មោះ/ Name ....ឈ្មោះ/Name ....

ឈ្មោះ/Name ....ឈ្មោះ/ Name ....

អ្នកស៊ើបអង្កេត/Investigator: ____________________

ករណីកំនត់លេខ/Case No.: ____________________

ឧបសម្ព័ន្ធទី ៥/Annex 5: គំរូបែបបទនៃការស៊ើបអង្កេត/Investigation Form

ព័ត៌មានអំពីអ្នកទាមទារ/Claimant Information

(អ្នកទាមទារត្រូវបំពេញព័ត៌មានទាំងនេះ/To be completed for each claimant)

២-អត្តសញ្ញាណរបស់អ្នកទាមទារ Identification of the Claimant:

	ប្រុស/Man	ស្រី/Woman
អត្តសញ្ញាណប័ណ្ណ/ ID Card		
ឈ្មោះ/Name		
ថ្ងៃខែឆ្នាំកំណើត/Date of birth		
ស្ថានភាពនៃកម្មសិទ្ធិដែលបានប្តឹងទាមទារ/ Claimed Ownership status		
ទីកន្លែងកំណើត/Place of birth		
សញ្ជាតិ/Nationality		
ឈ្មោះឪពុក/Father's name		
ឈ្មោះម្តាយ/Mother's name		
អាស័យដ្ឋានបច្ចុប្បន្ន/Current Address		

៣-ប្រភេទសិទ្ធិនៃទ្រព្យដែលបានប្តឹងទាមទារ/ Kind of property right claimed:

៣.១-ទ្រព្យខាងប្តី/Property of Husband PM ☐ ៣.២- ទ្រព្យខាងប្រពន្ធ/Property of wife PF ☐

៣.៣-ទ្រព្យរួមប្តីប្រពន្ធ/ Common Property BC ☐ ៣.៤-ទ្រព្យលីវ/ Single Property ☐

៣.៥-សហកម្មសិទ្ធិ/Co-ownership ☐ ៣.៦-ទ្រព្យក្រុមហ៊ុន/ Company Property ☐

៣.៧- ទ្រព្យសាធារណៈនៃរដ្ឋ/Public Domain ☐ ៣.៨- ទ្រព្យឯកជននៃរដ្ឋ/Private Domain ☐

៣.៩- ទ្រព្យសមាគមន៍/ Property of Association ☐ ៣.១០- ទ្រព្យសាសនា/Religious Property ☐

៣.១១- ព្រះរាជទ្រព្យ/Property of Crown ☐ ៣.១២-ផ្សេងៗ/Other....................................

៤- ស្ថានភាពផ្លូវច្បាប់ដែលបានប្តឹងទាមទារ/Legal Status claimed:

ដីដែលមានប័ណ្ណកម្មសិទ្ធិ/Title of ownership CI ☐ ដីមានប័ណ្ណកាន់កាប់បណ្តោះអាសន្ន/Temporary title of possession POT ☐

ដីមានប័ណ្ណសំគាល់សិទ្ធិ/ Title of possession ☐

៥- ពត៌មានលំអិតអំពីវិវាទ/Dispute Details:

ទំហំដីវិវាទ/Areas in dispute: ទាំងអស់/All ☐ ផ្នែក/ភាគ(សូមបញ្ជាក់/Specify)... ☐

៥.៤-ទ្រព្យលីវ/ Single Property ☐ ៥.៥-សហកម្មសិទ្ធិ/Co-ownership ☐

៥.៦-ទ្រព្យក្រុមហ៊ុន/ Company Property ☐ ៥.៧- ទ្រព្យសាធារណៈនៃរដ្ឋ/Public Domain ☐

៥.៨- ទ្រព្យឯកជននៃរដ្ឋ/Private Domain ☐ ៥.៩- ទ្រព្យសមាគមន៍/ Property of Association ☐

៥.១០- ទ្រព្យសាសនា/Religious Property ☐ ៥.១១- ព្រះរាជទ្រព្យ/Property of Crown ☐

៥.១២-ផ្សេងៗ/Other....................................

ចម្លើយ/សេចក្តីអធិប្បាយរបស់អ្នកប្តឹង/Claimant's Statement/Explanation

(សូមភ្ជាប់ទំព័របន្ថែមប្រសិនបើមានពត៌មានចាំបាច់/attach additional pages as necessary)

....

....

....

....

....

ឯកសារអមជាភស្តុតាង/Supporting Documents

(សូមថតចម្លង និងភ្ជាប់ជាមួយរបាយការណ៍ការស៊ើបអង្កេត/Copy and attach to investigation report)

១.. ៤..

២.. ៥..

៣.. ៦..

៥-ប្រភពនៃការកាន់កាប់ដី/Source of land tenure:..

អ្នកស៊ើបអង្កេត/Investigator: ____________________

ករណីវិវាទលេខ/Case No.: ____________________

ឧបសម្ព័ន្ធទី ៥/Annex 5: ទំរង់បែបបទនៃការស៊ើបអង្កេត/Investigation Form

អត្ថបទពត៌មានអំពីដើមបណ្តឹង/Claimant Information Sheet

(ដើមបណ្តឹងត្រូវបំពេញទំរង់បែបបទនេះ/To be completed for each claimant)

៦- បន្ទុក : ជួល-បញ្ចាំ/Burden: Lease, Mortgage: ....

៧- ស្នាមមេដៃ ឬ ហត្ថលេខា របស់ដើមបណ្តឹង និងសាក្សីដែលបញ្ជាក់អំពីអត្តសញ្ញាណរបស់ដើមបណ្តឹង [២]/ Thumbprint or signature of the claimant and witnesses attesting to identity of claimants:

ហត្ថលេខា/signature	ហត្ថលេខា/signature	ហត្ថលេខា/signature	ហត្ថលេខា/signature
ប្តី/Husband	ប្រពន្ធ/wife	សាក្សីទី១/first witness	សាក្សីទី ២/second witness
ឈ្មោះ/Name........................	ឈ្មោះ/Name..................	ឈ្មោះ/Name......................	ឈ្មោះ/Name.........

B-អ្នកស៊ើបអង្កេត/Investigator:.. កាលបរិច្ឆេទ/Date............/............../ 200..

ហត្ថលេខា/Singature: ____________________

អ្នកស៊ើបអង្កេត/Investigator: ____________________________

ករណីវិវាទលេខ/Case No.: ____________________________

---

[២] អាចមិនចាំបាច់មានសាក្សីទេ ប៉ុន្តែសាក្សីត្រូវបានបញ្ចូលទៅក្នុងទំរង់បែបបទសេចក្តីព្រាងនេះ ដោយសារតែទំរង់បែបបទសំរាប់សាក្សីមាននៅក្នុងឯកសារនៃការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំដែលជាមូលដ្ឋាននៃទំរង់បែបបទទាំងនេះរួចហើយ ។/Witnesses might not be necessary- they are included on this draft form because spaces for witnesses are present on the sporadic registration documents on which these forms are based.

ឧបសម្ព័ន្ធ ៥/Annex 5: គំរូបែបបទនៃការស៊ើបអង្កេត/Investigation Form

ពត៌មានអំពីចុងបណ្តឹង/Respondent Information Sheet

(ចុងចម្លើយម្នាក់ៗត្រូវបំពេញពត៌មានទាំងនេះ/To be completed for each respondent)

ក- អត្តសញ្ញាណរបស់ចុងបណ្តឹង/IDENTIFICATION OF THE RESPONDENT:

១- លេខសំគាល់ក្បាលដី/Unique parcel reference number (UPRN):

	ប្រុស/Man	ស្រី/Woman
អត្តសញ្ញាណប័ណ្ណ/ ID Card:		
ឈ្មោះ/Name:		
ថ្ងៃខែឆ្នាំកំណើត/Date of birth:		
ស្ថានភាពនៃកម្មសិទ្ធិដែលបានប្តឹងទាមទារ/ Claimed Ownership status:		
ទីកន្លែងកំណើត/Place of birth		
សញ្ជាតិ/Nationality:		
ឈ្មោះឪពុក/Father's name:		
ឈ្មោះម្តាយ/Mother's name:		
អាស័យដ្ឋានបច្ចុប្បន្ន/Current Address:		

៣-ប្រភេទនៃសិទ្ធិលើទ្រព្យដែលបានប្តឹងទាមទារ/ Kind of property right claimed:

- ៣.១-ទ្រព្យខាងប្តី/Property of Husband PM ☐ ៣.២- ទ្រព្យខាងប្រពន្ធ/Property of wife PF ☐
- ៣.៣-ទ្រព្យរួមប្តីប្រពន្ធ/ Common Property BC ☐ ៣.៤-ទ្រព្យលីវ/ Single Property ☐
- ៣.៥-សហកម្មសិទ្ធិ/Co-ownership ☐ ៣.៦-ទ្រព្យក្រុមហ៊ុន/ Company Property ☐
- ៣.៧- ទ្រព្យសាធារណៈរបស់រដ្ឋ/Public Domain ☐ ៣.៨- ទ្រព្យឯកជនរបស់រដ្ឋ/Private Domain ☐
- ៣.៩- ទ្រព្យសមាគមន៍/ Property of Association ☐ ៣.១០- ទ្រព្យសាសនា/Religious Property ☐
- ៣.១១- ព្រះរាជទ្រព្យ/Property of Crown ☐ ៣.១២-ផ្សេងៗ/Other.........................

៤- [illegible] Legal Status Claimed:

មានប័ណ្ណកម្មសិទ្ធិ/Title of ownership CI ☐ មានបណ្ណកាន់កាប់បណ្តោះអាសន្ន/ Temporary title of possession POT ☐

មានបណ្ណសំគាល់សិទ្ធិ/Title of possession ☐

ចម្លើយ/សេចក្តីអធិប្បាយរបស់ចុងបណ្តឹង/Respondent's Statement/Explanation

(សូមភ្ជាប់ជាទំព័របន្ថែមនៅពេលមានពត៌មានចាំបាច់/attach additional pages as necessary)

....
....
....
....
....
....
....

ឯកសារគាំទ្រ/Supporting Documents

(ថតចម្លង និងភ្ជាប់មកជាមួយរបាយការណ៍ស៊ើបអង្កេត/Copy and attach to investigation report)

១.. ៤..
២.. ៥..
៣.. ៦..

៥- ប្រភពនៃការកាន់កាប់ដី/Source of land tenure:...

៦- បន្ទុក : ជួល-បញ្ចាំ Burden- Lease, Mortgage:...

៧-ស្នាមមេដៃ ឬ ហត្ថលេខារបស់ចុងបណ្តឹង និងសាក្សី ដែលបញ្ជាក់ពីអត្តសញ្ញាណរបស់ចុងបណ្តឹង/Thumbprint or signature of the respondent and witnesses attesting to identity of respondents:

ហត្ថលេខា/signature	ហត្ថលេខា/signature	ហត្ថលេខា/signature	ហត្ថលេខា/signature

អ្នកស៊ើបអង្កេត/Investigator: ______________________

ករណីឯកសារលេខ/Case No.: ______________________

ឧបសម្ព័ន្ធទី ៥/Annex 5: គំរូទម្រង់បែបបទនៃការស៊ើបអង្កេត/Investigation Form

អត្តសញ្ញាណនិងព័ត៌មានអំពីចុងចម្លើយ/Respondent Information

(ចុងចម្លើយត្រូវបំពេញពត៌មានទាំងនេះ/To be completed for each respondent)

ប្តី/Husband ប្រពន្ធ/ wife សាក្សីទី១/first witness សាក្សីទី ២/second witness

ឈ្មោះ/Name........................ឈ្មោះ/Name....................ឈ្មោះ/Name..................... ឈ្មោះ/Name...............................

ខ-អ្នកស៊ើបអង្កេត/Investigator:..កាលបរិច្ឆេទ/Date............/............../ 200..

ហត្ថលេខា/Singature: ____________________

អ្នកស៊ើបអង្កេត/Investigator: ____________________

ករណីវិវាទលេខ/Case No.: ____________________

ឧបសម្ព័ន្ធទី ៥/Annex 5: ទំរង់បែបបទនៃការស៊ើបអង្កេត/Investigation Form

ទំរង់បែបបទនៃចម្លើយរបស់សាក្សី/Witness Statement Form

(សាក្សីត្រូវបំពេញទម្រង់បែបបទទាំងនេះ/To be completed for each witness)

ចម្លើយរបស់សាក្សី/Witness Statement

ឈ្មោះ/Name:	ថ្ងៃខែ ឆ្នាំកំណើត/Age:	សញ្ជាតិ/Nationality:	មុខរបរ/Occupation:
ខេត្ត ក្រុង/Province:	ស្រុក/District:	ឃុំ/Commune:	ភូមិ/Village:
អាស័យដ្ឋានបច្ចុប្បន្ន/Current Address:			
កាលបរិច្ឆេទនៃចម្លើយ/Date of Statement: / /	ទីកន្លែង/Location:	អ្នកស៊ើបអង្កេត/Investigator:	

ចម្លើយរបស់សាក្សី/Statement

(សូមភ្ជាប់ទំព័របន្ថែមប្រសិនបើមានពិតមានចាំបាច់/Attach additional pages as necessary)

ស្នាមមេដៃ ឬហត្ថលេខារបស់សាក្សី/Thumbprint or Signature of Witness

ហត្ថលេខា/signature

ឈ្មោះ/Name: ____________________

អ្នកស៊ើបអង្កេត/Investigator: ____________________

ករណីវិវាទលេខ/Case No.: ____________________

ឧបសម្ព័ន្ធទី ៥/Annex 5: គំរូបែបបទនៃការស៊ើបអង្កេត/Investigation Form

របាយការណ៍ស៊ើបអង្កេត/Investigation Report

លទ្ធផលនៃការស៊ើបអង្កេត/Investigation Results	
ករណីវិវាទលេខ/Case No.:	
អាស័យដ្ឋាននៃដីដែលមានវិវាទ/Disputed PRoperty:	
ការអធិប្បាយអំពីទ្រព្យដែលមានវិវាទ/Description of Disputed Property (ការប្រើប្រាស់ដី/Land use. ពត៌មានលំអិតអំពីសំណង់/building characteristics...)	

វិវាទ/ខ្លឹមសារសង្ខេបអំពីលទ្ធផល/Dispute/Findings Summary

(សូមភ្ជាប់ជាទំព័របន្ថែមនៅពេលមានពត៌មានចាំបាច់/Attach additional as necessary)

ឯកសារគាំទ្រ/Supporting documents

១.	៤.
២.	៥.
៣.	៦.

ភស្តុតាងរបស់ភាគី/Party Evidence

(សូមភ្ជាប់ទំព័របន្ថែមនៅពេលមានពត៌មានចាំបាច់/Attach additional pages as necessary)

ឈ្មោះរបស់ភាគី/Party Name:	អាយុ/Age:	សញ្ជាតិ/Nationality:	មុខរបរ/Occupation:
ខេត្ត ក្រុង/Province:	ស្រុក ខណ្ឌ/District:	ឃុំសង្កាត់/Commune:	
អាស័យដ្ឋានបច្ចុប្បន្ន/Current Address:			

ខ្លឹមសារសង្ខេបអំពីភស្តុតាង/សក្ខីកម្មដែលជាការគាំទ្រ/Summary of Supporting Evidence/Testimony

ឯកសារគាំទ្រ/Supporting documents

១.	៤.
២.	៥.
៣.	៦.

អ្នកស៊ើបអង្កេត/Investigator: ____________________

ករណីវិវាទលេខ/Case No.: ____________________

ឧបសម្ព័ន្ធទី ៥/Annex 5: គំរូទម្រង់នៃការស៊ើបអង្កេត/Investigation Forms

របាយការណ៍ស៊ើបអង្កេត/Investigation Report

ឈ្មោះរបស់ភាគី/Party Name:	អាយុ/Age:	សញ្ជាតិ/Nationality:	មុខរបរ/Occupation:
ខេត្ត ក្រុង/Province:	ស្រុក ខណ្ឌ/District:	ឃុំ សង្កាត់/Commune:	
អាសយដ្ឋានបច្ចុប្បន្ន/Current Address:			

ខ្លឹមសារសង្ខេបពីភស្តុតាង/សក្ខីកម្មដែលជាអំណះអំណាង/Summary of Supporting Evidence/Testimony

ឯកសារអំណះអំណាង/Supporting Documents

១.	៤.
២.	៥.
៣.	៦.

ឈ្មោះរបស់ភាគី/Party Name:	អាយុ/Age:	សញ្ជាតិ/Nationality:	មុខរបរ/Occupation:
ខេត្ត ក្រុង/Province:	ស្រុក ខណ្ឌ/District:	ឃុំសង្កាត់/Commune:	
អាសយដ្ឋានបច្ចុប្បន្ន/Current Address:			

ខ្លឹមសារសង្ខេបនៃភស្តុតាង និងសក្ខីកម្មដែលជាអំណះអំណាង/ Summary of Supporting Evidence/Testimony

ឯកសារអំណះអំណាង/Supporting Documents

១.	៤.
២.	៥.
៣.	៦.

អ្នកស៊ើបអង្កេត/Investigator: ____________________

ករណីឯកសារលេខ/Case No.: ____________________

ឧបសម្ព័ន្ធ ៥/Annex 5: ទំរង់បែបបទនៃការស៊ើបអង្កេត/Investigation Forms

របាយការណ៍ស៊ើបអង្កេត/Investigation Report

កំណត់សំគាល់/យោបល់ស្ថាពរ/Final Comments/Notes

ស្នាមមេដៃ/ហត្ថលេខារបស់អ្នកស៊ើបអង្កេត

Investigator Signature/Thumbprint:

រៀបចំដោយ/Prepared by: ____________________

ហត្ថលេខា/Signature

អ្នកស៊ើបអង្កេត/Investigator ____________________

ករណីវាងលេខ/Case No.: ____________________

ឧបសម្ព័ន្ធទី ៦/Annex 6: ទំរង់បែបបទបញ្ចប់រឿងក្តី/Case Disposition Form

ទំព័រ..............នៃ................../Page..........................of....................

ព័ត៌មានអំពីវិវាទ/Dispute Information	
ករណីវិវាទលេខ/Case No.:	
អាស័យដ្ឋាននៃដីដែលមានវិវាទ/Disputed Property Address:	

ព័ត៌មានអំពីភាគីវិវាទ/Party Information			
ឈ្មោះរបស់ភាគី/Party Name:	អាយុ/Age:	សញ្ជាតិ/Nationality:	មុខរបរ/Occupation:
ប្តី ឬប្រពន្ធ/Spouse:	កូន/Children:		
ខេត្ត ក្រុង/Province:	ស្រុក ខណ្ឌ/District:	ឃុំ សង្កាត់/Commune:	
អាស័យដ្ឋានបច្ចុប្បន្ន/Current Address:			
ឈ្មោះរបស់ភាគី/Party Name:	អាយុ/Age:	សញ្ជាតិ/Nationality:	មុខរបរ/Occupation:
ប្តី ឬប្រពន្ធ/Spouse:	កូន/Children:		
ខេត្ត ក្រុង/Province:	ស្រុក ខណ្ឌ/District:	ឃុំ សង្កាត់/Commune:	
អាស័យដ្ឋានបច្ចុប្បន្ន/Current Address:			
ឈ្មោះរបស់ភាគី/Party Name:	អាយុ/Age:	សញ្ជាតិ/Nationality:	មុខរបរ/Occupation:
ប្តី ឬប្រពន្ធ/Spouse:	កូន/Children:		
ខេត្ត ក្រុង/Province:	ស្រុក ខណ្ឌ/District:	ឃុំ សង្កាត់/Commune:	
អាស័យដ្ឋានបច្ចុប្បន្ន/Current Address:			

នៅក្នុងបញ្ហានៃការបោះបង្គោលបណ្តោះអាសន្ននៃករណីវិវាទលេខ : ______________________ ភាគីវិវាទបានជួប និង ពិភាក្សាអំពីបណ្តឹងនិងការបដិសេធ ។ ជាលទ្ធផលនៃកិច្ចប្រជុំនេះ ភាគីវិវាទបានសំរេចនូវកិច្ចព្រមព្រៀងដោយពេញចិត្តទៅវិញទៅមកដូចដែលបានអធិប្បាយខាងក្រោម ។ កិច្ចព្រមព្រៀងនេះ ធ្វើការដោះស្រាយវិវាទលើដីដែលបានប្តឹងទាមទារដោយអនុលោមតាមច្បាប់ភូមិបាល ឆ្នាំ ២០០១ ។ ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ត្រូវធ្វើការចុះបញ្ជីដីនេះ ស្របតាមកិច្ចព្រមព្រៀងនេះ ។

ភាគីវិវាទសំរេចកិច្ចព្រមព្រៀងនេះដោយយុត្តិធម៌ និង សមធម៌ ដោយគ្មានការបង្ខិតបង្ខំ ការអសមត្ថភាពរបស់អ្នកសម្រុះសម្រួល ឬ អំពើពុករលួយឡើយ ។ ភាគីវិវាទយល់ថា ខ្លួនពុំមានកាតព្វកិច្ចសំរេចកិច្ចព្រមព្រៀងទេ ហើយតាមរយៈការចុះហត្ថលេខា ឬផ្តិតមេដៃលើកិច្ចព្រមព្រៀងនេះ មានន័យថាទទួលយកលក្ខខ័ណ្ឌខាងក្រោម ។

In the matter of Land Titling Case No.: ______________________, the disputing parties have met and discussed the claim and objection. As a result of this meeting the parties have reached a mutually satisfactory agreement, as described below. In accordance with the Land Law 2001, the agreement resolves the dispute over the claimed piece of land. The District/Khan Office of LMUPC administration shall register the land in accordance with this agreement.

The parties reach this agreement fairly and equitably, without coercion, conciliator incompetence, or corruption. The parties understand that they are under no obligation to reach an agreement, and by signing or thumbprinting this agreement, accept the terms below.

សេចក្តីអធិប្បាយអំពីកិច្ចព្រមព្រៀង/Description of Agreement (សូមភ្ជាប់ទំព័របន្ថែមនៅពេលមានពត៌មានចាំបាច់/Attach additional pages as necessary)

ឧបសម្ព័ន្ធ ៦/Annex 6: ទំរង់បែបបទបញ្ចប់រឿងក្តី/Case Disposition Form

ទំព័រ..............នៃ................./Page..........................of....................

ឯកសារភ្ជាប់មកជាមួយ/Attached Documents	
១.	៤.
២.	៥.
៣.	៦.

ហត្ថលេខា/ស្នាមមេដៃរបស់អ្នកសម្រុះសម្រួល
Conciliator Signatures/Thumbprints:

(ហត្ថលេខា/Signature) (ហត្ថលេខា/Signature) (ហត្ថលេខា/Signature)

ឈ្មោះ/Name: ______________ ឈ្មោះ/Name: ______________ ឈ្មោះ/Name: ______________

ហត្ថលេខា/ស្នាមមេដៃរបស់ភាគីវិវាទ/Party Signatures/Thumbprints:

(សូមភ្ជាប់ទំព័របន្ថែមប្រសិនបើមានពត៌មានចាំបាច់/Attach additional pages as necessary)

(ហត្ថលេខា/Signature) (ហត្ថលេខា/Signature) (ហត្ថលេខា/Signature)

ឈ្មោះ/Name: ______________ ឈ្មោះ/Name: ______________ ឈ្មោះ/Name: ______________

ទទួលដោយ/Received by: ______________

ករណីវិវាទលេខ/Case No.: ______________

កាលបរិច្ឆេទ/Date: ____/____/____

ត្រាផ្លូវការ/Official Seal

ឧបសម្ព័ន្ធទី ៧/Annex 7: របាយការណ៍នៃសម្រុះសម្រួល/Conciliation Report

ទំព័រ......................នៃ...................../Page...........of................

(ភាគីត្រូវបំពេញសំណុំបែបបទនេះប្រសិនបើមិនអាចសំរេចដល់កិច្ចព្រមព្រៀង/To be completed if parties do not reach an agreement)

ព័ត៌មាននៃករណីវិវាទ/Dispute Information	
ករណីវិវាទលេខ/Case No.:	
អាស័យដ្ឋាននៃដីដែលមានវិវាទ/Dispute Property Address:	
ខ្លឹមសារសង្ខេបនៃវិវាទ/Summary of Party's Position (សូមភ្ជាប់ទំព័របន្ថែមប្រសិនបើមានពត៌មានចាំបាច់/Attach additional pages as necessary)	

ព័ត៌មានអំពីភាគីវិវាទ/Party Information (សូមភ្ជាប់ទំព័របន្ថែមប្រសិនបើមានពត៌មានចាំបាច់/Attach additional pages as necessary)			
ឈ្មោះរបស់ភាគី/Party Name	អាយុ/Age :	សញ្ជាតិ/Nationality:	មុខរបរ/Occupation:
ខេត្ត ក្រុង/Province:	ស្រុក ខណ្ឌ/District:	ឃុំ សង្កាត់/Commune:	ភូមិ/Village:
អាស័យដ្ឋានបច្ចុប្បន្ន/Current Address:			
ខ្លឹមសារសង្ខេបអំពីស្ថានភាពរបស់ភាគីវិវាទ/Summary of Party's Position (សូមភ្ជាប់ទំព័របន្ថែមប្រសិនបើមានពត៌មានចាំបាច់/Attach additional pages as necessary)			

ឈ្មោះរបស់ភាគី/Party Name	អាយុ/Age :	សញ្ជាតិ/Nationality:	មុខរបរ/Occupation:
ខេត្ត ក្រុង/Province:	ស្រុក ខណ្ឌ/District:	ឃុំ សង្កាត់/Commune:	
អាស័យដ្ឋានបច្ចុប្បន្ន/Current Address:			
ខ្លឹមសារសង្ខេបអំពីស្ថានភាពរបស់ភាគីវិវាទ/Summary of Party's Position (សូមភ្ជាប់ទំព័របន្ថែមប្រសិនបើមានពត៌មានចាំបាច់/Attach additional pages as necessary)			

ករណីវិវាទលេខ/Case No.: ________________

ឧបសម្ព័ន្ធទី ៧/Annex 7: របាយការណ៍សម្រុះសម្រួល/Conciliation Report

ទំព័រ......................នៃ...................../Page...................of...................

(ភាគីវិវាទត្រូវបំពេញសំណុំបែបបទនេះប្រសិនបើពុំសម្រេចដល់កិច្ចព្រមព្រៀង/To be completed if parties do not reach an agreement)

ឈ្មោះរបស់ភាគី/Party Name:	អាយុ/Age :	សញ្ជាតិ/Nationality:	មុខរបរ/Occupation:
ខេត្ត ក្រុង/Province:	ស្រុក ខណ្ឌ/District:	ឃុំ សង្កាត់/Commune:	ភូមិ/Village:
អាស័យដ្ឋានបច្ចុប្បន្ន/Current Address:			

ខ្លឹមសារសង្ខេបអំពីស្ថានភាពរបស់ភាគីវិវាទ/Summary of Party's Position

(សូមភ្ជាប់ទំព័របន្ថែមប្រសិនបើមានពតិមានចាំបាច់/ Attach additional pages as necessary)

ករណីវិវាទលេខ/Case No.: ____________________

ឧបសម្ព័ន្ធទី ៧/Annex 7: របាយការណ៍សម្រុះសម្រួល/Conciliation Report

ទំព័រ......................នៃ...................../Page...................of...................

(ភាគីវិវាទត្រូវបំពេញសំណុំបែបបទនេះប្រសិនបើពុំសំរេចដល់កិច្ចព្រមព្រៀង/To be completed if parties do not reach an agreement)

ខ្លឹមសារសង្ខេបអំពីការសម្រុះសម្រួល/យោបល់របស់អ្នកសម្រុះសម្រួល/Conciliation Summary/Conciliator Comments (សូមភ្ជាប់ទំព័របន្ថែមប្រសិនបើមានពតិមានចាំបាច់/ Attach additional pages as necessary)

ឯកសារភ្ជាប់មកជាមួយ/Attached Documents	
១.	៤.
២.	៥.
៣.	៦.

ស្នាមមេដៃរបស់អ្នកសម្រុះសម្រួល/Conciliator Thumbprint/Signatures:

រៀបចំដោយ/Prepared by: ____________ ហត្ថលេខា/Signature

អ្នកសម្រុះសម្រួលផ្សេងៗទៀត/Other Conciliators: ____________ ហត្ថលេខា/Signature

____________ ហត្ថលេខា/Signature

រៀបចំដោយ/Prepared by: ____________

ករណីវិវាទលេខ/Case No.: ____________

កាលបរិច្ឆេទ/Date: ______/______/______

ត្រាផ្លូវការ/Official Seal

ឧបសម្ព័ន្ធ ៨/Annex 8: គំរូរបាយការណ៍ប្រចាំខែ/Sample Monthly Report

ត្រូវដាក់ជូនដោយគណៈកម្មការសុរិយោដី/To be submitted by Cadastral Commissions

គណៈកម្មការសុរិយោដី/ Cadastral Commission:

☐ ថ្នាក់ស្រុក/District:.............................. ☐ ថ្នាក់ខេត្ត ក្រុង/ Province:.............................

☐ ថ្នាក់ជាតិ/ National:......................................

ខែ/Month:..

កាលបរិច្ឆេទនៃការដាក់/Date Filed:....../.............../..........................

រៀបចំដោយ/Prepared by:.........:..

ប្រធានគណៈកម្មការ/Commission Chief:..

ស្ថិតិទូទៅ/General Statistics:

ករណីវិវាទថ្មីដែលបានដាក់ជូន/ទទួល/New Cases Filed/Received:..........................

ករណីវិវាទដែលបានសម្រុះសម្រួល និងដោះស្រាយរួច/Cases Conciliated and Resolved: ....

ករណីវិវាទដែលមិនទាន់បានដោះស្រាយ/មិនទាន់បានដោះស្រាយរួច/Cases Unresolved/Outstanding:..........................

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ /ខេត្ត ក្រុង/ DKCC/PMCC:

ករណីវិវាទដែលបានបញ្ជូន/Cases Forwarded:..........................

គណៈកម្មការសុរិយោដីថ្នាក់ជាតិ/ NCC:

ករណីវិវាទដែលបានសំរេច/Cases Decided:..........................

សេចក្តីសំរេចដែលបានប្តឹងតវ៉ាទៅតុលាការ/Decisions Appealed:..........................

ពត៌មានលំអិតអំពីដីវិវាទ/Land Details:

ភេទដី/Land Type	ករណីវិវាទដែលបានដាក់ជូន/New Cases Filed	ករណីវិវាទដែលបានដោះស្រាយ/ Cases Resolved	ករណីវិវាទដែលបានសំរេចដោយគណៈកម្មការសុរិយោដីថ្នាក់ជាតិ/Cases Decided (NCC only)	ករណីវិវាទដែលបានបញ្ជូន/ដែលបានប្តឹងតវ៉ាទៅតុលាការ/ Cases Forwarded/ Appealed	ករណីវិវាទដែលមិនទាន់ដោះស្រាយ/ Cases Outstanding[3]
លំនៅដ្ឋាន/ Residential					
ឧស្សាហកម្ម/ Industrial					
កសិកម្ម/ Agricultural					
ដែលគ្មានប្រព័ន្ធធារាសាស្ត្រ/ rigated Riceland					
ដែលមានប្រព័ន្ធធារាសាស្ត្រ/ Rain-ed Riceland					
ចំការ/ Chamkar					

ពត៌មានលំអិតអំពីវិវាទ/TDispute Details:

ត្រាផ្លូវការ/Official Seal

រៀបចំដោយ/Prepared by:.....................................

កាលបរិច្ឆេទ:/Date:...

---

[3] ករណីវិវាទដែលមិនទាន់បានដោះស្រាយរួចនិយាយសំដៅទៅលើករណីទាំងឡាយដែលស្ថិតនៅក្រោមការពិចារណានៅឡើយពីខែមុនៗ. ការគិតនេះមិនរួមបញ្ចូលករណីនានា ដែលបានដាក់ ឬបានទទួលក្នុងអំឡុងពេលនៃខែធ្វើរបាយការណ៍ ។

ដីព្រៃរបស់សហគមន៍/Communal Forest					
ព្រៃរបស់រដ្ឋ/ State Forest					
ដីសើម/ Wetlands					
ដីពាណិជ្ជកម្ម/Commercial					
ដីសាសនា/Religious					
ផ្សេងៗ/Other					

ព័ត៌មានលំអិតអំពីវិវាទ/Dispute Details[4]:

ប្រភេទនៃករណីវិវាទ/Dispute Type	ករណីវិវាទថ្មីដែលបានដាក់ជូន /New Cases Filed	ករណីវិវាទដែលបានដោះស្រាយរួច/Cases Resolved	ករណីវិវាទដែលបានសំរេចដោយគណៈកម្មការសុរិយោដីថ្នាក់ជាតិ/ Cases Decided (NCC only)	ករណីវិវាទដែលបានបញ្ជូន/ ដែលបានប្តឹងតវ៉ាទៅតុលាការ/ Cases Forwarded/ Appealed	ករណីវិវាទដែលមិនទាន់ដោះស្រាយរួច/ Cases Outstanding
ពាក់ព័ន្ធនឹងមន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាល ក្រសួង/ Involves High-Ranking Military/ Gov't Officials					
ភាគីពីរ/Two Party					
ច្រើនភាគី/Multi-Party					
វិវាទរវាងសមាជិកក្នុងគ្រួសារ/ Inter-family					

ត្រាផ្លូវការ/Official Seal

រៀបចំដោយ/Prepared by:....................................

កាលបរិច្ឆេទ/Date:..

[4] ស្ថិតិបែបនេះអាចមានសារៈប្រយោជន៍សំរាប់គោលបំណងនៃការស្រាវជ្រាវ ប៉ុន្តែវាមិនទាន់ច្បាស់លាស់នៅឡើយថាតើគណៈកម្មការសុរិយោដីនឹងមានសមត្ថភាពប្រមូលទិន្នន័យបែបនេះដែរឬទេ ។

ឧបសម្ព័ន្ធទី ៩/ANNEX 9

មាត្រា ២៥១.-/Article 251

ជនណាដែលបានក្លែងប័ណ្ណក្នុងគោលបំណងយកទៅប្រើប្រាស់ជាផ្លូវការ ទោះជាក្នុងរូបភាពអ្វីក៏ដោយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ដល់ ៥ (ប្រាំ) ឆ្នាំ ។

Any person who falsifies a title with the intent to make an official use of it, regardless of its form, shall be subject to imprisonment from one (1) to five (5) years.

មាត្រា ២៥២.-/Article 252

ជនណាដែលបានបំភាន់មន្ត្រីសុរិយោដីក្នុងការបំពេញបេសកកម្ម ឬបំភាន់អាជ្ញាធរក្នុងការចុះបញ្ជីដីត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០០.០០០ (ប្រាំសែន) រៀល ដល់ ៣០០០.០០០ (បីលាន) រៀល ឬ/និងដាក់ពន្ធនាគារពី ១ (មួយ) ខែ ដល់ ៦ (ប្រាំមួយ) ខែ ។

Any person who misleads or deceives Cadastral Administration officials in the exercise of their tasks or the authorities in registration of land shall be punishable by a fine from 500,000 (five hundred thousand) Riel to 3,000,000 (three million) Riel and/or imprisonment from of 1 (one) month to 6 (six) months.

មាត្រា ២៦៣.-/Article 263:

អាជ្ញាធរមានសមត្ថកិច្ចដែលព្រងើយកន្តើយ ឬបណ្តោយឱ្យសាមញ្ញជនប្រព្រឹត្តដោយរំលោភសិទ្ធិរបស់កម្មសិទ្ធិករ របស់ភាគី ឬរបស់អ្នកកាន់កាប់ដោយសន្តិភាពត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០០០.០០០ (មួយលាន) រៀល ដល់ ១០.០០០.០០០ (មួយលាន) រៀល ដល់ ១០.០០០០.០០០ (ដប់លាន) រៀល និងត្រូវទទួលទោសរដ្ឋបាលថែមទៀត ។

The authority, who ignores or allows private individuals to act wrongfully against the rights of owners~~, possessors, or peaceful~~ occupants, shall be subject to a fine from one million (1,000,000) Riel to ten million (10,000,000) Riel and shall be subject to administrative sanctions.

មាត្រា ២៦៤.-/Article 264;

ការរំលោភធ្វើឡើងដោយមន្ត្រីសុរិយោដីត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ដល់ ៥.០០០.០០០ (ដប់លាន) រៀល និងត្រូវទទួលទោសរដ្ឋបាលថែមទៀត ។

រាប់បញ្ចូលជាការរំលោភ ការផ្តល់ទិន្នន័យជាផ្លូវការខុស ការចេញប័ណ្ណកម្មសិទ្ធិខុស ការបិទបាំងហ៊ីប៉ូតែកឬបន្ទុកផ្សេងៗ ការបោះគោលព្រំដីខុសដោយចេតនា និងរាល់ការធ្វេសប្រហែសក្នុងការធ្វើលេខាចារិកលើឯកសារសុរិយោដី ។

Any abuse committed by cadastral officials shall be fined from one million (1,000,000) Riles to five million (5,000,000) Riel and shall be subject to administrative sanctions.

Such abuse includes the delivery of false official data, the delivery of false titles to property, concealment of mortgages or other charges, intentional deceptive demarcation and any negligence in the inscription of cadastral documents.

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខៈ 260...... សប្រក.កសក

រាជធានីភ្នំពេញ.ថ្ងៃទី 12 ខែ ឧសភា ឆ្នាំ២០០២

សេចក្តីប្រកាស

ស្តីពី

តំបន់អភិរក្សជីវៈចំរុះ " សីមា " ក្នុងព្រៃសម្បទាន ក្រុមហ៊ុនសាមលីញអន្តរជាតិ នៅ ខេត្តមណ្ឌលគីរី_ក្រចេះ

ដោយផ្អែកតាមលទ្ធផលចុះសិក្សាស្រាវជ្រាវរបស់នាយកដ្ឋាន រុក្ខា-ប្រមាញ់ សហការជាមួយអង្គការសមាគមអភិរក្សសត្វព្រៃប្រចាំកម្ពុជា WILDLIFE CONSERVATION SOCIETY (WCS) ក្នុងព្រៃសម្បទានក្រុមហ៊ុនសាមលីញអន្តរជាតិនៅខេត្តមណ្ឌលគីរី-ក្រចេះ ចាប់តាំងពីឆ្នាំ២០០០រហូតដល់បច្ចុប្បន្នបានបង្ហាញយ៉ាងច្បាស់ថា តំបន់ព្រៃសម្បទាននេះមានសក្តានុពលខ្ពស់សំរាប់ការអភិរក្សជីវៈចំរុះ ។ ប៉ុន្តែទន្ទឹមនឹងភាពសម្បូរបែបនៃសក្តានុពលធនធានសត្វព្រៃ ជីវៈចំរុះត្រូវបានទទួលការគំរាមកំហែងយ៉ាងខ្លាំងក្លាបណ្តាលមកពី ការប្រមាញ់សត្វព្រៃ ការប្រមូលផល-អនុផលព្រៃឈើហួសកំរិត ការកាប់រានដីព្រៃដោយអនាធិបតេយ្យ ។

ដោយមើលឃើញការចាំបាច់ និង តួនាទីដ៏មានសារៈសំខាន់នៃការអភិរក្សជីវៈចំរុះ " សីមា " នៅក្នុងព្រៃសម្បទានក្រុមហ៊ុនសាមលីញអន្តរជាតិខេត្តមណ្ឌលគីរី-ក្រចេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ចេញសេចក្តីប្រកាស ដូចតទៅៈ

១-តំបន់អភិរក្សជីវៈចំរុះ " សីមា " ដែលមានផ្ទៃដីចំនួន ៣០៥.៤៤០ហិកតា នៅក្នុងព្រៃសម្បទានក្រុមហ៊ុនសាមលិញអន្តរជាតិខេត្តមណ្ឌលគីរី-ក្រចេះ ដើម្បីរៀបចំផែនការគ្រប់គ្រងរយៈពេលវែង ដូចមានផែនទីភ្ជាប់ជាឧបសម្ព័ន្ធ ជាប្រព័ន្ធខ្សែព្រំបិទកំណត់ដោយបណ្តាចំណុចគោល ដែលមាននិយាមកា : A1(702280, 1334410) , B1(708170, 1334500) , A2B2(738020, 1358890), A3(739800, 1366720) , B3(730130, 1374550) , A4(729960, 1399270) , B4(711970, 1387210) , A5(706380, 1394770) , B5(702350, 1389500) , A6(676760, 1386750) , B6(692900, 1382650) , A7(652820, 1359220) , B7(682300, 1376200) , A8(658180, 1345560) , B8(701000, 1357600) , B9(705870, 1348780) ។

២-ហាមឃាត់ដាច់ខាតរាល់សកម្មភាពកាប់រានដីព្រៃឈើ ការកាប់រំលំដើមឈើដើម្បីប្រមូលអនុផលព្រៃឈើ និង ការប្រមាញ់សត្វព្រៃ តាមបទប្បញ្ញត្តិច្បាប់ ។

៣-តំបន់អភិរក្សជីវៈចំរុះ " **សីមា** " ក្នុងព្រៃសម្បទានក្រុមហ៊ុនសាមលីញអន្តរជាតិនៅខេត្តមណ្ឌលគិរី-ក្រចេះ អាចធ្វើការកែប្រែតាមការចាំបាច់ ផ្អែកលើលទ្ធផលពតិមានវិទ្យាសាស្ត្រ និង ស្ថានភាពជាក់ស្តែងនៅពេលអនាគត ។

៤-តំបន់អភិរក្សជីវៈចំរុះ " **សីមា** " នេះ មិនប៉ះពាល់ដល់ដំណើរការគ្រប់គ្រង និង ការប្រមូលផលពីព្រៃសម្បទានរបស់ក្រុមហ៊ុនសាមលីញអន្តរជាតិទេ ។

៥-ការរៀបចំ និង ការប្រព្រឹត្តទៅនៃតំបន់ជីវៈចំរុះ " **សីមា** " នេះ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋាន រុក្ខា-ប្រមាញ់ សហការជាមួយក្រុមហ៊ុនព្រៃសម្បទានសាមលីញអន្តរជាតិ និង មានការបែងចែកភារកិច្ចដូចតទៅៈ

-នាយកដ្ឋាន រុក្ខា-ប្រមាញ់ មានភារកិច្ចធ្វើការរៀបចំ និង គ្រប់គ្រងតំបន់អភិរក្សជីវៈចំរុះ " **សីមា** " ដោយធានានូវការអភិវឌ្ឍន៍ធនធានធម្មជាតិប្រកបដោយនិរន្តភាព និង ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងតំបន់នោះ ។

-ក្រុមហ៊ុនព្រៃសម្បទានសាមលិញអន្តរជាតិ មានតួនាទីបង្កលក្ខណៈងាយស្រួលសហការ ឧបត្ថម្ភដល់ដំណើរការខាងលើ និង ចូលរួមចាត់វិធានការទប់ស្កាត់ និង លុបបំបាត់នូវគ្រប់រូបភាពអនាធិបតេយ្យក្នុងតំបន់អភិរក្សជីវៈចំរុះ " **សីមា** " នេះ ឱ្យមានប្រសិទ្ធភាពខ្ពស់បំផុត ។

ក្រោយពីទទួលសេចក្តីប្រកាសនេះ គ្រប់អង្គភាពនៅថ្នាក់កណ្តាល ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទខេត្តមណ្ឌលគិរី និង ខេត្តក្រចេះ ត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយ និង ខិតខំអនុវត្តសេចក្តីប្រកាសនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់បំផុត ។

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

ជ័ន្ទ-សារុន

កន្លែងទទួល

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងបរិស្ថាន
-ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់
-ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
-សាលាខេត្តមណ្ឌលគិរី
-សាលាខេត្តក្រចេះ
-ក្រុមហ៊ុនព្រៃសម្បទានដែលមានការពាក់ព័ន្ធ
-ឯកសារ-កាលប្បវត្តិ

តំបន់អភិរក្សជីវៈចំរុះ "សីមា" ក្នុងព្រៃសម្បទានក្រុមហ៊ុនសាមលីញអន្តរជាតិ ខេត្តមណ្ឌលគិរី_ក្រចេះ



សញ្ញាសំគាល់

- ភូមិសំខាន់ៗ
- ព្រំដែនប្រទេសកម្ពុជា-វៀតណាម
- ព្រំប្រទល់ខេត្ត
- ព្រំប្រទល់ស្រុក
- ផ្លូវសំខាន់ៗ
- តំបន់ស្នូល : ១៩៥.០០០ ហាត
- តំបន់អភិរក្ស ៣០៥.៤៤០ ហាត
- ដែនជំរកសត្វព្រៃ

ប្រភេទព្រៃ

- ព្រៃស្រោង ៩១.៤៧៤ ហាត
- ព្រៃស្រោង លាយល្បោះ ៦៤.៤៧១ ហាត
- ព្រៃល្បោះ ១០៥.៩៥១ ហាត
- ព្រៃគម្ពោត ២៧.៤៥០ ហាត
- វាលស្មៅ ១០.៨០៣ ហាត
- ព្រៃកាប់ចំការ ៥.៦៥២ ហាត

ប្រព័ន្ធភូមិសាស្ត្រ

- បញ្ចុះបែងភាគប្រឹបពីជា	យូ ធី អឹម
- តំបន់	៤៨
- កំណត់បណ្តាញប្រឹបពិភាគ	ឥណ្ឌា១៩៦០
- ប្រឹបពីរាងពងក្រពើ	អេវើរេស
- បណ្តាញក្រឡាចត្រង្គ	១០ គីឡូម៉ែត្រ



បានឃើញ និង ឯកភាព

រាជធានីភ្នំពេញ ថ្ងៃទី 12 ខែ ... ឆ្នាំ ២០០២

រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

ចាន់_សារុន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និង សាសនា

លេខ......០៣.........ធ.ធ.សណណន

សេចក្ដីណែនាំ

ស្ដីពី

ការរៀបចំពិធីបុណ្យកាន់បិណ្ឌ ភ្ជុំបិណ្ឌ និងកឋិនទាន

យោងសារាចរណែនាំលេខ ១០ សរណន ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០២ របស់រាជរដ្ឋាភិបាលកម្ពុជា ស្ដីពីការរៀបចំបុណ្យកាន់បិណ្ឌ ភ្ជុំបិណ្ឌ និងកឋិនទាន ។

បុណ្យកាន់បិណ្ឌ ភ្ជុំបិណ្ឌ និងកឋិនទាន ក្នុង ពស ២៥៤៦ នេះ ត្រូវបានប្រារព្ធឡើងចំពេលដែលរាជរដ្ឋាភិបាលបាននិងកំពុងយកចិត្តទុកដាក់អនុវត្តយ៉ាងសកម្មគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។

* ឆ្នាំនេះបុណ្យកាន់បិណ្ឌ នឹងប្រព្រឹត្តទៅពីថ្ងៃ ១រោច ដល់ថ្ងៃ ១៤រោច ខែ ភទ្របទ ត្រូវនឹងថ្ងៃទី ២២ ខែ កញ្ញា ដល់ថ្ងៃទី ៥ ខែ តុលា ឆ្នាំ ២០០២ ហើយថ្ងៃ ១៥រោច ជាថ្ងៃភ្ជុំបិណ្ឌ ។ ឯបុណ្យកឋិនទាន ជាបុណ្យពុទ្ធប្បញ្ញត្តិចាប់ផ្ដើមពីថ្ងៃ ១រោច ខែអស្សុជ ដល់ថ្ងៃ ១៥ កើត ខែ កត្តិក ត្រូវនឹងថ្ងៃទី ២២ ខែ តុលា ដល់ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០២ ដែលពុទ្ធសាសនិកកម្ពុជាតែងបានប្រារព្ធធ្វើជាប់ជាប្រពៃណីរៀងរហូតមកនៅគ្រប់វត្តអារាមទូទាំងប្រទេស ។

ដើម្បីញុំាងអោយពិធីបុណ្យខាងលើប្រព្រឹត្តទៅបានល្អប្រសើរប្រកបដោយបរិយាកាសសប្បាយរីករាយ ធានាបានសាមគ្គីភាព មិត្តភាព និងសុវត្ថិភាព ក្រសួងធម្មការ និងសាសនា សូមណែនាំដល់មន្ទីរធម្មការ និងសាសនាគ្រប់ខេត្ត ក្រុង និងអង្គភាពពាក់ព័ន្ធដូចខាងក្រោម ÷

១-បុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌ ជាបុណ្យប្រពៃណីជាតិដ៏សំខាន់របស់ពុទ្ធសាសនិកខ្មែរគ្រប់រូប ។ ពិធីនេះប្រារព្ធឡើងដើម្បីឧទ្ទិសកុសលជូនដល់វិញ្ញាណក្ខ័ន្ធ នៃអ្នកមានគុណទាំងឡាយ មានមាតាបិតា ជីដូនជីតា គ្រូឧបជ្ឈាយាចារ្យ បុព្វបុរសជាតិជាដើម និងបងប្អូនជនរួមជាតិទាំឡាយ ដែលបានលាចាកលោកនេះទៅកាន់លោកខាងមុខ ។ម្យ៉ាងទៀត ពិធីនេះជាឱកាសបានជួបជុំឪពុកម្ដាយ បងប្អូន ញាតិមិត្ត សាច់សាលោហិតដែលបានរស់នៅ និងរស់នៅទីផ្សេងៗគ្នា និងអាចស្វែងយល់បានពីសុខទុក្ខ ការងាយស្រួល និងការលំបាកក្នុងជីវភាពរស់នៅទៅវិញទៅមក ព្រមទាំងបង្កើនបាននូវសាមគ្គីភាពដ៏ទូលំទូលាយផង ។

២-មន្ទីរធម្មការ និងសាសនាខេត្ត-ក្រុង ត្រូវផ្សព្វផ្សាយ និងណែនាំដល់ លោកអាចារ្យ គណកម្មការគ្រប់វត្តឱ្យរៀបចំបោសសំអាតវត្តអារាម និងបូជនីយដ្ឋាន ស្តូប កន្លែងតម្កល់អដ្ឋិធាតុបងប្អូនជនរួមជាតិដែល បានបាត់បង់ជីវិតក្នុងរបបប្រល័យពូជសាសន៍ ព្រមទាំងរៀបចំពិធីបង្សុកូលឧទ្ទិសកុសលជូនដល់វិញ្ញាណក្ខន្ធបុព្វបុរសដែលបានពលីក្នុងបុព្វហេតុជាតិ មាតុភូមិ និងជនរួមជាតិយើងតាមប្រពៃណីព្រះពុទ្ធសាសនា ។

៣-ក្នុងពិធីបុណ្យកាន់បិណ្ឌ ១៥ ថ្ងៃ សូមព្រះសង្ឃជាធម្មកថិកសម្ដែងធម្មទេសនា អំពីមង្គល ៣៨ ប្រការ និងបរាភវសូត្រទាំង ១២ គាថា ដោយបកស្រាយអត្ថន័យ និងខ្លឹមសារធម៌ឱ្យបានទូលំទូលាយ គួបផ្សំនឹងប្រយោជន៍ទាំង៤ យ៉ាងសំដៅកែប្រែជីវភាពខាងសេដ្ឋកិច្ច វប្បធម៌ របស់ពុទ្ធសាសនិក ដើម្បីកសាងជីវភាពបច្ចុប្បន្នប្រកបដោយសុភមង្គលពិតប្រាកដ ។

៤-កឋិនទាន គឺជាកាលទានពិសេសក្នុងពុទ្ធសាសនាដែលក្នុង ១២ ខែ ធ្វើបានតែ ២៩ ថ្ងៃប៉ុណ្ណោះ ដើម្បីឱ្យកុសល

ផលបុណ្យ និងអនិសង្សដែលកើតឡើងអំពីបុណ្យកឋិនទាននេះបានល្អប្រសើរ សូមពុទ្ធសាសនិកអ្នកផ្តើមបុណ្យ និងអ្នកចូលរួមត្រូវធានាដល់រូបភាព និងខ្លឹមសារកឋិនទានឱ្យបានត្រឹមត្រូវ តាមពុទ្ធប្បញ្ញត្តិ និងពុទ្ធានុញ្ញាត អ្នកមានសទ្ធាធ្វើកឋិនទានគួរធ្វើតាមធនធាននិងលទ្ធភាពរបស់ខ្លួនដែលមាន ។ ឯការឃោសនារៃអង្គាសគឺត្រូវធ្វើតែក្នុងមូលដ្ឋានរបស់ខ្លួន ហាមឃាត់ចំពោះអ្នកដែលឆ្លៀតយកបុណ្យកឋិនទានធ្វើជាអាជីវកម្មដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ។

ចំពោះអ្នកផ្តួចផ្តើមដង្ហែអង្គកឋិនទាន ត្រូវប្រុងប្រយ័ត្ននិងត្រួតពិនិត្យមើលឱ្យបានគ្រប់ជ្រុងជ្រោយ នូវក្មេងស្ទាវដែលចូលរួមដង្ហែអង្គកឋិន ព្រោះអាចមានជនមិនសុចរិតបន្លំចូលបង្កសកម្មភាពមិនល្អនាំឱ្យមានទំនាស់រវាងក្រុមមួយទៅក្រុមមួយ ធ្វើឱ្យខូចរបៀបរៀបរយ និងតម្លៃបុណ្យកឋិនទានរបស់ពុទ្ធបរិស័ទយើង ។ ជាមួយនេះដែរត្រូវធ្វើការណែនាំ និងអប់រំយុវជន យុវនារី កុមារា កុមារី ដែលចូលរួមដង្ហែអង្គកឋិនទានដ៏ឧត្តុងឧត្តមនេះ ចេះធ្វើខ្លួនឱ្យស័ក្តិសមជាកូនចៅរបស់ពុទ្ធសាសនិកពិតប្រាកដ ដោយមិនបង្កសកម្មភាពនាំឱ្យប៉ះពាល់ដល់កិត្តិយស សេចក្តីថ្លៃថ្នូររបស់ព្រះពុទ្ធ សាសនា ដូចជា ការគប់ស្បោងទឹក ជះទឹក គប់កាកអំពៅ គប់ផ្លែឈើ និងគប់ដោយវត្ថុរឹងផ្សេងៗ ធ្វើ ឱ្យខូចរបៀបរៀបរយសណ្តាប់ធ្នាប់សង្គម និងអាចឈានទៅរកគ្រោះថ្នាក់ដោយអំពើលេងសើចគ្មានរបៀបនេះ ម្យ៉ាងទៀតសូមអស់លោកម្ចាស់ទានប្រធានបុណ្យមេត្តាចាប់អារម្មណ៍ ឱ្យបានខ្ពស់ ការធ្វើដំណើរទាំងផ្លូវគោក ទឹក គឺការឡើងរថយន្ត ឡើងកាណូត ទូក ។ល។ គួរត្រួតពិនិត្យឱ្យបានត្រឹមត្រូវតាមទម្ងន់របស់យានជំនិះមិនឱ្យឡើងប្រជ្រៀតគ្នាយកតែឈ្នះដៃ ធ្វើឱ្យមានការលិចកាណូត ទូក បាក់ទ្រុងរថយន្ត ។ល។ អាចបណ្តាលឱ្យមានគ្រោះថ្នាក់ដល់ជីវិតពុទ្ធបរិស័ទយើងទៀតផង ។

❋ រាល់ផលទានដែលកើតឡើងដោយពិធីបុណ្យទាំង ២ ខាងលើមានម្ហូបអាហារ នំចំណីជាដើម គប្បីចែករំលែកជូនដល់បងប្អូនក្រីក្រ ជនពិការ កុមារកំព្រា តាមលទ្ធភាពរបស់វត្តនីមួយៗ ជាពិសេសសម្ភារៈ ថវិកា ត្រូវមានការគ្រប់គ្រង និងប្រើប្រាស់ឱ្យបានត្រឹមត្រូវ សមហេតុផល ជៀសវាងការបាត់បង់ និងបង្កឱ្យមានទៅជាទំនាស់ផ្សេងៗរហូតដល់បែកបាក់សាមគ្គីភាពគ្នានិងគ្នា ។

នាយកមន្ទីរធម្មការ និងសាសនាគ្រប់ខេត្ត-ក្រុង ត្រូវសហការជាមួយព្រះមេគណ អនុគណ ចៅអធិការ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ក្នុងការរក្សាសុវត្ថិភាពជូនប្រជាជន និងត្រូវបង្កលក្ខណៈងាយស្រួលប្រគេនព្រះសង្ឃ និងជូនប្រជាជនពុទ្ធបរិស័ទឱ្យបានចូលរួម ក្នុងពិធីបុណ្យខាងលើប្រកបដោយសោមនស្សរីករាយតាមលទ្ធភាពរៀងៗខ្លួន ។

ក្រសួងធម្មការ និងសាសនាសង្ឃឹមថា លោកនាយកមន្ទីរធម្មការ ខេត្ត-ក្រុង ព្រះមេគណ អនុគណ ចៅអធិការវត្ត និងអង្គភាពពាក់ព័ន្ធគ្រប់ថ្នាក់ផ្សព្វផ្សាយសេចក្តីណែនាំនេះ អោយបានទូលំទូលាយ និងចាត់តាំងអនុវត្តសេចក្តីណែនាំនេះទទួលបានលទ្ធផលល្អប្រសើរ សមតាមប្រពៃណីរបស់ជាតិយើង ។៕

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០២

រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

Samondea

ជា_សាវឿន

<u>ចម្លងជូន</u>

-សម្តេចព្រះសង្ឃរាជទាំងពីរគណៈ
-ខុទ្ទកាល័យព្រះមហាក្សត្រ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័ន ខេត្ត-ក្រុង
" ដើម្បីជ្រាប-និងជូនជ្រាប "
-ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ
-អភិបាលគ្រប់ខេត្ត-ក្រុង
-ព្រះមេគណគ្រប់ខេត្ត-ក្រុង
" ដើម្បីសហការអនុវត្ត "
-ឯកសារកាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និង សាសនា

លេខ.....៤៣៦..........ធ.ធ.ស

សេចក្តីសំរេច

ស្តីពីការអនុញ្ញាតឱ្យកសាងវត្តថ្មីឈ្មោះថា "មង្គលសុវណ្ណគិរី"
នៃគណៈមហានិកាយ ភូមិតាម៉ៅ ឃុំស្រក ស្រុកកំពង់សៀម ខេត្តកំពង់ចាម

រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១១៩៨ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា.

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី.

-បានឃើញព្រះរាជក្រមលេខ នស.រកម០១៩៦-១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា.

-បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងធម្មការ និងសាសនា.

យោងតាមចំណារឯកភាពរបស់អភិបាល ខេត្ត កំពង់ចាម លេខ ២៤៧៦ កច ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០២.

-យោងតាមចំណាររបស់ប្រធានមន្ទីរធម្មការ និងសាសនា ខេត្តកំពង់ចាម លេខ ៦១ មធកច ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០០២.

-យោងតាមចំណាររបស់អភិបាលស្រុក កំពង់សៀម លេខ ១២៦ កពស ចុះថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០២.

-តាមសំណើសុំរបស់ ពុទ្ធបរិស័ទ និងមេឃុំ ស្រក លេខ ៣៨ ឃស ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០២.

សំរេច

ប្រការមួយៈ អនុញ្ញាតឱ្យកសាងវត្តថ្មី ឈ្មោះ "**វត្តមង្គលសុវណ្ណគិរី**" នៃគណៈមហានិកាយ ដែលស្ថិតនៅភ្នំក្របាម ភូមិតាម៉ៅ ឃុំស្រក ស្រុកកំពង់សៀម ខេត្តកំពង់ចាម ដោយមានក្បាច់រចនា ជាប្រពៃណីវប្បធម៌របស់ជាតិ ។

ប្រការពីរ : វត្តថ្មីនេះ ត្រូវដាក់ប្រគេនព្រះសង្ឃ និងជូនពុទ្ធបរិស័ទគោរពប្រតិបត្តិ និង ធ្វើបុណ្យទានឱ្យបានត្រឹមត្រូវ តាមពុទ្ធបញ្ញត្តិ និងពុទ្ធានុញ្ញាត និងប្រពៃណីពុទ្ធសាសនា ព្រមទាំងច្បាប់របស់រដ្ឋឱ្យបានល្អប្រសើរ និងរីកចំរើន ។

ប្រការបី : ខុទ្ទកាល័យ អគ្គនាយកដ្ឋានធម្មការ នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុមន្ទីរធម្មការ និងសាសនា ខេត្តកំពង់ចាម អង្គភាពពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ និងអាចារ្យ- គណៈកម្មការវត្ត ត្រូវអនុវត្តសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។៚

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០២

រដ្ឋមន្ត្រី

ជា-សាវឿន

ចម្លងជូន ៖

-សម្តេចព្រះសង្ឃរាជគណៈមហានិកាយ
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
"*ដើម្បីជ្រាប-ជូនជ្រាប*"
-រាជកិច្ច "ដើម្បីចុះផ្សាយ"
-សាលាខេត្តកំពង់ចាម
-អភិបាលស្រុកកំពង់សៀម
-ដូចប្រការបី
"*ដើម្បីសហការអនុវត្ត*"
ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកិច្ចការនារី និង អតីតយុទ្ធជន

លេខ ..281.....ក ក ន អ /ប្រក

ប្រកាស

ស្តីពីការទទួលយកទីតាំងមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មព្យាបាល ដោយចលនាភ្នំពេញ មណ្ឌលម៉ាស្សាមៃទេព និងក្របខ័ណ្ឌមន្ត្រីរាជការ

***

រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងអតីតយុទ្ធជន

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២ នស/៩៤ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ០៦/នស/៩៤ចុះថ្ងៃទី៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ អនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- យោង លិខិតលេខ ១៩០ សកបយ ចុះថ្ងៃទី២៤ ខែ កក្កដា ឆ្នាំ ២០០២ របស់ក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

សម្រេច

ប្រការ១ : ទទួលយកមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មព្យាបាលដោយចលនាភ្នំពេញ ក្របខ័ណ្ឌមន្ត្រីរាជការចំនួន ១១នាក់ ចលនទ្រព្យ និងអចលនទ្រព្យ នៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា អោយស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ។

ប្រការ២ : ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗរបស់មន្ត្រីរាជការដែលមានរាយនាមក្នុងតារាងឧបសម្ព័ន្ធនៃប្រកាសនេះត្រូវបើកបន្តនៅក្រសួងកិច្ចការនារី និងអតីតយុទ្ធជន បន្ទាប់ពីមានវិញ្ញាបនប័ត្រផ្តាច់ប្រាក់បៀវត្សពីអង្គភាពចាស់ ។

ប្រការ៣ : អគ្គាធិការដ្ឋាន អគ្គនាយកដ្ឋានទាំងពីរ នាយកខុទ្ទកាល័យ នាយកដ្ឋានរដ្ឋបាល-បុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ប្រធានមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មព្យាបាលដោយចលនាភ្នំពេញ និងមន្ត្រីរាជការដូចមានរាយនាមក្នុងតារាងឧបសម្ព័ន្ធនៃប្រកាសនេះ ត្រូវទទួលភារកិច្ចអនុវត្តឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។៚

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០០២

រដ្ឋមន្ត្រី

មូរ-សុខហួរ

ចម្លងជូន
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
  "ដើម្បីជ្រាបជាពត៌មាន"
- ដូចប្រការ៣ "ដើម្បីអនុវត្ត"
- ឯកសារ "កាលប្បវត្តិ"

តារាងឧបសម្ព័ន្ធនៃប្រកាសលេខ 281 កកនអ/ប្រក ចុះថ្ងៃទី 20 ខែ 08 ឆ្នាំ ២០០២ ស្តីពីការទទួលយកមន្ត្រីរាជការចំនួន ១១នាក់ អោយស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន

*****

ល.រ	នាមត្រកូល,នាមខ្លួន	ភេទ	ថ្ងៃ.ខែ.ឆ្នាំកំណើត	ឋានៈ តួនាទី	ផ្សេងៗ
១	ទាវ សំអុល	ប	១៣-០១-៦៩	អនុប្រធានការិយាល័យ	
២	ឡេង ច័ន្ទបូរិទ្ធ	ប	០៥-១០-៦៦	លេខាធិការ	
៣	អ៊ុន សំអាន	ប	១៨-១២-៧០	លេខាធិការ	
៤	សរ សិទ្ធី	ស	១៣-១០-៦៧	លេខាធិការ	
៥	ប្រាក់ ថាវភារី	ស	០៣-១១-៦៨	លេខាធិការ	
៦	នៅ មុំ	ស	០៦-០៤-៧៤	លេខាធិការ	
៧	សុខ ហង្សរី	ស	២៨-១១-៦៩	លេខាធិការ	
៨	គុប សារឿន	ស	០៨-១០-៤៨	ភ្នាក់ងាររដ្ឋបាល	
៩	ផូ អេងស៊ន	ស	១០-១១-៥០	ភ្នាក់ងាររដ្ឋបាល	
១០	វ៉ាន់ ង៉ា	ស	១១-០១-៥៣	ភ្នាក់ងាររដ្ឋបាល	
១១	អ៊ឹម ជឿន	ប	០៥-០៤-៤៩	ភ្នាក់ងាររដ្ឋបាល	

រាជធានីភ្នំពេញ,ថ្ងៃទី 20 ខែ 08 ឆ្នាំ២០០២

រដ្ឋមន្ត្រី

មុំ-សុខហួរ

រាជធានីភ្នំពេញ,ថ្ងៃទី 20 ខែ សីហា ឆ្នាំ ២០០២

ប្រធាននាយកដ្ឋានរដ្ឋបាល-បុគ្គលិក

សេនាក់ : ភិរាធន